ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

## មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន

# សៀវភៅណែនាំបង្រៀន

## អំពី

# សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ

## កម្រិតមធ្យមសិក្សាបឋមភូមិ




នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
ខែមករា ឆ្នាំ២០២៤

**Design and Layout:** Graphic Roots/2024

**Illustrations:** UNICEF Cambodia/2024Pisey Chan

Permission to reproduce any part of this publication is required.

**Please contact:**

**The Ministry of Education, Youth and Sport**
#80, Norodom Blvd. Phnom Penh, Kingdom of Cambodia
Telephone: +855 23 219 285
Email: info@moeys.gov.kh
www.moeys.gov.kh

Phnom Penh, 2024

# មាតិកា


សេចក្ដីផ្ដើម ៦

ជំពូក ១ ខ្លឹមសារមេរៀន ៩

មេរៀនទី ១

អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល ១០

មេរៀនទី ២

ឥទ្ធិពលអវិជ្ជមាននៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ២៦

មេរៀនទី ៣

អាកប្បកិរិយា ហានិភ័យ និងគ្រោះថ្នាក់នៃការកេងប្រវ័ញ្ច ផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ៣១

មេរៀនទី ៤

វិធានសុវត្ថិភាពអនឡាញ និងការឆ្លើយតបការកេងប្រវ័ញ្ច ផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ៤៦

មេរៀនទី ៥

ការរាយការណ៍ និងស្វែងរកជំនួយគាំទ្រសមស្រប ៥៥

ជំពូក ២ លំនាំនៃការបង្រៀន និងវាយតម្លៃ ៦៤

ឧបសម្ព័ន្ធ ១៖ សារសុវត្ថិភាពអនឡាញ ៦៨

ឧបសម្ព័ន្ធ ២៖ ករណីសិក្សា ៧១

ឧបសម្ព័ន្ធ ៣៖ ការឈ្វេងយល់ពីច្បាប់និងទោសបញ្ញត្តិ ៧៤

ឧបសម្ព័ន្ធ ៤៖ តំណភ្ជាប់ និងធនធានសិក្សាបន្ថែម ៧៥

# គណៈកម្មការអភិវឌ្ឍប្រធានបទសិក្សា

## គណៈកម្មការត្រួតពិនិត្យ

| | |
|---|---|
| ឯកឧត្តមបណ្ឌិត **អ៊ឹម កុច** | រដ្ឋលេខាធិការ |
| ឯកឧត្តម **អ៊ុង ជិនណា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ |
| លោក **រ័ត្ន សារ៉ា** | ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **នួន វណ្ណាសឿន** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **សំលៀង សីលា** | នាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីកុមារ (APLE) |
| លោកស្រី **អ៊ុង កល្យាណា** | មន្រ្តីកិច្ចការពារកុមារ អង្គការយូនីសេហ្វ (UNICEF) |

## ក្រុមការងារបច្ចេកទេស

| | |
|---|---|
| លោក **នួន វណ្ណាសឿន** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **សំលៀង សីលា** | នាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីកុមារ |
| លោកស្រី **អ៊ុង កល្យាណា** | មន្រ្តីកិច្ចការពារកុមារ អង្គការយូនីសេហ្វ |
| លោក **អ៊ុំ ច័ន្ទតារា** | អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| លោក **ប៊ូ បូលីដែន** | អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| លោក **ឃាង ឧត្តិន** | ប្រធានការិយាល័យនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| កញ្ញា **ម៉ៅ ណាវី** | ប្រធានការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក **ផេង វិមាន** | អនុប្រធានការិយាល័យនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **ផុក ចាន់ថុល** | អនុប្រធានការិយាល័យនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **នូ មុនីសេដ្ឋា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| លោក **មាស ជុតិមា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក **ផូ សុវណ្ណា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| លោកស្រី **អ៊ិត ចណ្ណា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| លោក **ជា យុទ្ធី** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| កញ្ញា **រស់ ចាន់អម៉ា** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |

## ការីកុំព្យូទ័រ

| | |
|---|---|
| លោក **ហេង សំរិទ្ធិរង្សី** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោក **ទ៉ា សុខលីន** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោកស្រី **សាំង ស៊ីថា** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| លោកស្រី **វ៉ែន ទ៉ាន់ដេត** | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |

# បុព្វកថា

ស្របពេលនឹងភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល ឱកាសដែលនាំឱ្យមានការកេងប្រវ័ញ្ចកុមារលើប្រព័ន្ធអនឡាញបានកើតមានឡើង និងក្លាយជាទម្រង់ថ្មីៗ ដែលកំពុងរីករាលដាលនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតទៅនឹងឧបករណ៍ឌីជីថល បានផ្ដល់នូវអត្ថប្រយោជន៍ជាច្រើនផ្នែកសង្គម និងសេដ្ឋកិច្ច ទន្ទឹមនឹងនេះ ក៏បានបង្កនូវហានិភ័យចំពោះអ្នកប្រើប្រាស់ ជាពិសេសកុមារ និងយុវជន តាមរយៈការចូលរួមសកម្មភាពក្នុងបណ្ដាញទំនាក់ទំនងសង្គមនានា។ វិសាលភាពនៃការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតនេះ បានបង្កលក្ខណៈកាន់តែងាយស្រួល និងឆាប់រហ័សដល់អ្នកប្រើប្រាស់ ក្នុងការទទួលបានសម្ភារៈពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ។

គ្រោះថ្នាក់និងហានិភ័យនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគឺជាកង្វល់របស់អ្នកអប់រំ និងអ្នកពាក់ព័ន្ធចំពោះអ្នកប្រើប្រាស់ ជាពិសេសកុមារជាអ្នកងាយរងគ្រោះបំផុត។ ការរៀបចំឯកសារណែនាំបង្រៀនស្ដីពី**សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ** ជួយដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា និងអ្នកពាក់ព័ន្ធផ្សេងៗ បានយល់ដឹងកាន់តែច្បាស់អំពីការកេងប្រវ័ញ្ចកុមារគ្រប់ទម្រង់ ជាពិសេសលើប្រព័ន្ធអនឡាញ ដែលអ្នកប្រើប្រាស់អ៊ីនធឺណិតចាំបាច់ត្រូវមានចំណេះដឹង និងឥរិយាបថប្រកបដោយសុវត្ថិភាព ព្រមទាំងសុខុមាលភាព បញ្ចៀសបាននូវគ្រោះថ្នាក់ ព្រមទាំងហានិភ័យផ្សេងៗដែលអាចកើតមានលើកុមារ។

ឯកសារណែនាំបង្រៀនស្ដីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ ត្រូវបានរៀបចំឡើងដើម្បីធានា និងជំរុញឱ្យអ្នកពាក់ព័ន្ធបង្កើនការយកចិត្តទុកដាក់ក្នុងការគាំពារកុមារ ដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធអនឡាញ ព្រមទាំងកុមារមិនទាន់ប្រើប្រាស់ផងដែរ។

ឯកសារណែនាំបង្រៀននេះ ជាវិធានការមួយដ៏សំខាន់ក្នុងការចូលរួមទប់ស្កាត់ហានិភ័យ និងគ្រោះថ្នាក់មួយចំនួនពាក់ព័ន្ធនឹងមាតិកាអនឡាញ និងសកម្មភាពខុសច្បាប់ ដែលឧក្រិដ្ឋជនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ជាមធ្យោបាយ ដូចជាការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូនរូបភាពឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ដូច្នេះយើងរួមគ្នា គោរពសិទ្ធិជាមូលដ្ឋាន និងឧត្តមប្រយោជន៍របស់កុមារ ដើម្បីឱ្យកុមារក្លាយជាធនធានមនុស្សដ៏មានសក្ដានុពលក្នុងការអភិវឌ្ឍជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដ៏ស្មោះចំពោះបុគ្គលិកអប់រំ និងអង្គការ Global Partnership End Violence Against Children ( GPEVAC ) និង UNICEF Australia ដែលបានផ្ដល់ការគាំទ្រថវិកា ព្រមទាំង UNICEF Cambodia និងអង្គការ APLE Cambodia ដែលបានផ្ដល់ជាបច្ចេកទេសក្នុងការកសាងឯកសារណែនាំបង្រៀនដ៏មានសារៈសំខាន់នេះ សម្រាប់អនុវត្តនៅកម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីកសាងមូលធនមនុស្សប្រកបដោយសុខុមាលភាព។

ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿជាក់ និងសង្ឃឹមថាសិស្សគ្រប់រូបបានរៀនសូត្រពីការរក្សាសុវត្ថិភាពលើប្រព័ន្ធអនឡាញប្រកបដោយប្រសិទ្ធភាព និងមានទំនួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ៤ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំជាដំណើរការអនន្តភាពបើរៀបដំណើរការខុសនាំឱ្យអន្តរាយអនាគតរបស់អ្នកសិក្សា។ វិស័យបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលបាននិងកំពុងរីកលូតលាស់សាយភាយគ្រប់ទីកន្លែង និងគ្រប់ផ្នែកនៃការអភិវឌ្ឍសង្គម។ ស្របពេលមានភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល ឱកាសដែលនាំឱ្យមានការកេងប្រវ័ញ្ចកុមារលើប្រព័ន្ធអនឡាញក៏ត្រូវបានកើតមានឡើង និងក្លាយជាទម្រង់ថ្មីមួយ ដែលកំពុងរីករាលដាលនៅលើពិភពលោករួមទាំងប្រទេសកម្ពុជាផងដែរ។ ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតទៅ និងឧបករណ៍ឌីជីថល ដូចជា កុំព្យូទ័រ ទូរសព្ទឆ្លាតវៃ ឬឧបករណ៍ដទៃទៀតបានផ្តល់នូវអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន ទន្ទឹមនឹងនោះ ក៏បានបង្កនូវហានិភ័យចំពោះកុមារ និងយុវជន ដែលជាអ្នកប្រើប្រាស់តាមរយៈការចូលរួមសកម្មភាពក្នុងបណ្តាញទំនាក់ទំនងសង្គមនានា។ វិសាលភាពនៃការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត បានបង្កលក្ខណៈកាន់តែងាយស្រួល និងឆាប់រហ័សដល់អ្នកប្រើប្រាស់ ក្នុងការទទួលបានសម្ភារៈពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ។

ការរៀបចំការសិក្សាស្តីពី **សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ** ជាប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើននៃមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានដែលត្រូវបង្រៀន និងរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិស្របតាមកម្មវិធីសិក្សាជាតិមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ មុខវិជ្ជានេះត្រូវបានប្រមូលផ្តុំខ្លឹមសារការបង្រៀន និងរៀនតាមគំរូពីរគឺគំរូសង្គម និងគំរូអាជីពហើយប្រធានបទសិក្សានេះអនុវត្តតាមគំរូសង្គមដែលមាន ៥មេរៀន ស្មើនឹង ១៥ម៉ោងសិក្សា ហើយត្រូវបង្រៀននៅថ្នាក់ទី៧ សម្រាប់ឆមាសទី១ នៃឆ្នាំសិក្សា។

ខ្លឹមសារមេរៀននៅក្នុងឯកសារនេះនឹងជួយដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា និងអ្នកពាក់ព័ន្ធផ្សេងៗបានយល់ដឹងកាន់តែច្បាស់អំពីការកេងប្រវ័ញ្ចកុមារគ្រប់ទម្រង់លើប្រព័ន្ធអនឡាញ សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត ហានិភ័យដែលអាចកើតមានលើកុមារនៅពេលប្រើប្រាស់ យន្តការរាយការណ៍ពីសកម្មភាពរំលោភបំពាន និងវិធីការពារប្រកបដោយសុវត្ថិភាពសុខុមាលភាពនៅពេលប្រើប្រាស់អ៊ីនធឺណិត។

ឯកសារណែនាំបង្រៀនស្តីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញនេះត្រូវបានរៀបចំឡើងឆ្លើយតបនឹងនិន្នាការវិវត្តន៍នៃបច្ចេកវិទ្យាដើម្បីធានា និងជំរុញឱ្យអ្នកពាក់ព័ន្ធបង្កើនការយកចិត្តទុកដាក់ក្នុងការគាំពារកុមារដែលបាន និងកំពុងប្រើប្រាស់ប្រព័ន្ធអនឡាញ ព្រមទាំងកុមារមិនទាន់ប្រើប្រាស់ផងដែរ។

ឯកសារនេះ ជាវិធានការមួយដ៏សំខាន់ក្នុងការចូលរួមទប់ស្កាត់ហានិភ័យ និងគ្រោះថ្នាក់មួយចំនួនពាក់ព័ន្ធនឹងមាតិកា និងសកម្មភាពខុសច្បាប់ ដែលឧក្រិដ្ឋជនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ជាមធ្យោបាយប្រព្រឹត្តបទល្មើស ដូចជាការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូនរូបភាព

ឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ដូច្នេះ យើងរួមគ្នាគោរពសិទ្ធិជាមូលដ្ឋាន និង ឧត្តមប្រយោជន៍របស់កុមារ ដើម្បីឱ្យកុមារក្លាយជាធនធានមនុស្សដ៏មានសក្ដានុពលក្នុងការអភិវឌ្ឍជាតិ។

ក្រុមការងាររៀបចំ និងចងក្រងឯកសារណែនាំបង្រៀននេះ សង្ឃឹមថា គ្រប់គ្រឹះស្ថានមធ្យមសិក្សាទាំងអស់ នឹងអនុវត្តការបង្រៀនឯកសារនេះ នៅកម្រិតថ្នាក់ទី៧ សម្រាប់ឆមាសទី១ នៃឆ្នាំសិក្សា និងរង់ចាំទទួលនូវការកែលម្អក្នុងន័យស្ថាបនា ស្របតាមការវិវត្តនៃបច្ចេកវិទ្យាឌីជីថល។

**សូមអរគុណ**

# សេចក្តីផ្តើម

ស្របពេលដែលវិបត្តិកូវីដ-១៩ កំពុងរាតត្បាតទូទាំងពិភពលោក ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កាន់តែមានសារៈសំខាន់ក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយគ្រប់បញ្ហា រួមទាំងការសិក្សាអប់រំរបស់កុមារ និងយុវជនទាំងនៅទីក្រុង ទាំងជនបទ ដែលធ្វើឱ្យវិស័យបច្ចេកវិទ្យាព័ត៌មាននេះ រឹតតែទទួលបាននូវការពេញនិយមសម្រាប់ទំនាក់ទំនង និងអភិវឌ្ឍន៍គ្រប់វិស័យ។ ទោះបីជាយ៉ាងនេះក្តីការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន ក៏មានជ្រុងអវិជ្ជមានមួយចំនួន ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ខុសគោលដៅនិងដោយមានការជ្រៀតចូលពីក្រុមឧក្រិដ្ឋជនឆ្លៀតឱកាសទាញយកផលប្រយោជន៍ដោយខុសច្បាប់ និងប្រាសចាកពីគន្លង សីលធម៌ និងការអភិវឌ្ឍ ដោយបង្កើតឱ្យមានការកេងប្រវ័ញ្ច និងឧក្រិដ្ឋកម្មគ្រប់រូបភាព រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាល និងបង្កហានិភ័យខ្ពស់ដល់កុមារនៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ។

ការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ជាបញ្ហាសកល និងកំពុងបង្កហានិភ័យដល់កុមារគួរឱ្យព្រួយបារម្ភ។ នាឆ្នាំ២០២០ របាយការណ៍របស់មជ្ឈមណ្ឌលជាតិសម្រាប់កុមារបាត់ខ្លួន និងកេងប្រវ័ញ្ច (NCMEC) របស់សហរដ្ឋអាមេរិក បានបង្ហាញពីចំនួនករណីនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដែលកើនឡើងដល់ជាង ២១.៧លានករណី ក្នុងនោះជនល្មើសភាគច្រើនជាមនុស្សដែលកុមារមិនស្គាល់។ ទន្ទឹមគ្នានេះ របាយការណ៍របស់សមាគមបណ្តាញរាយការណ៍បន្ទាន់អន្តរជាតិ (INHOPE) ឆ្នាំ២០២០ បានបង្ហាញថា ៧៦%នៃកុមាររងគ្រោះពីរូបភាពរំលោភបំពានផ្លូវភេទមានអាយុចន្លោះពី ៣ ទៅ ១៣ឆ្នាំ និង១% ជាកុមារមានអាយុចន្លោះពី ០ ទៅ ២ឆ្នាំ ក្នុងនោះ ៩៣% ជាក្មេងស្រី ។

ដោយឡែក នៅកម្ពុជា មិនទាន់មានទិន្នន័យផ្លូវការជាក់លាក់បញ្ជាក់ពីទំហំនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញនៅឡើយទេ ប៉ុន្តែតាមរយៈការរាយការណ៍ពីសាធារណជនមកកាន់សមត្ថកិច្ច និង បណ្តាញរាយការណ៍តាមអ៊ីនធឺណិត (Internet Hotlines) ជាមធ្យមមានចំនួនរាយការណ៍ជាង ១៥០ករណី ក្នុងមួយឆ្នាំៗ ដែលជាករណីសង្ស័យទាក់ទងនឹងការលួងលោមកុមារតាមអនឡាញ ការផលិត និងចែកចាយ សម្ភារៈអាសអាភាសកុមារ និងការគំរាមខាងផ្លូវភេទជាដើម។ យោងតាមការសិក្សាស្រាវជ្រាវស្តីពីការវិភាគស្ថានភាពដំបូងនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) បង្ហាញថា ប្រមាណ ៦០%នៃកុមារកម្ពុជាដែលបានចូលរួមក្នុងដំណើរការអង្កេតត្រូវបានរាយការណ៍ថា ធ្លាប់បានជួបប្រទះហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញ នៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត ដូចជាការលួងលោមក្នុងគោលបំណងផ្លូវភេទ និងការបង្ខំឱ្យផ្ញើរូបអាក្រាតរបស់កុមារជាដើម។

ឆ្លើយតបនឹងបញ្ហាខាងលើ ពិភពលោក ក៏ដូចជាប្រទេសកម្ពុជាបានកំពុងយកចិត្តទុកដាក់ និងរួមកម្លាំងគ្នាដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ នៅក្នុងបរិបទនៃការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT) និងកំណើននៃការប្រើប្រាស់កម្ពុជាបានបោះជំហានទៅមុខក្នុងការប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ និងខិតខំប្រឹងប្រែងធ្វើឱ្យកាន់តែប្រសើរឡើងនូវសុវត្ថិភាពអ៊ីនធឺណិត ដើម្បីផ្តល់បរិយាកាសឌីជីថលវិជ្ជមាន និងប្រកបដោយសុវត្ថិភាព ដល់អ្នកប្រើប្រាស់ ជាពិសេសកុមារ ដែលជាអ្នកប្រើប្រាស់យ៉ាងសកម្ម រួមទាំងការប្រើប្រាស់សម្រាប់ការសិក្សាអប់រំរបស់ពួកគេទាំងនៅទីក្រុង និងជនបទដែលធ្វើឱ្យវិស័យបច្ចេកវិទ្យាព័ត៌មានមួយនេះរឹតតែទទួលបាននូវការពេញនិយមសម្រាប់ទំនាក់ទំនង និងអភិវឌ្ឍន៍គ្រប់វិស័យ។ ក្រោមការឆ្លើយតបជាសកលរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកល (WePROTECT) ដែលបានចុះហត្ថលេខាក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងអាប៊ុយដាប៊ី នៃសហភាពអារ៉ាប់រួម កាលពីឆ្នាំ២០១៥ ដែលមានក្រសួងមហាផ្ទៃ ជាអ្នកសម្របសម្រួល។ សេចក្តីថ្លែងការណ៍សកលនេះ បានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) ដែលកម្ពុជាបានទទួលយកមកបញ្ចូលក្នុងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញឆ្នាំ២០២១-២០២៥នេះកម្ពុជាក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ (PathFinding Country) កាលពីថ្ងៃទី១២ខែ កញ្ញា ឆ្នាំ២០១៩ និងបានរៀបចំផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញផងដែរ។ លើសពីនេះទៀត ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមអនុម័តសេចក្តីថ្លែងការណ៍រួមរបស់សមាគមអាស៊ាននាកិច្ចប្រជុំកំពូលនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវដល់រដ្ឋជាសមាជិកអាស៊ានទាំងអស់ឱ្យប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងសមាគមអាស៊ានពីការកេងប្រវ័ញ្ច និងរំលោភបំពានលើប្រព័ន្ធអនឡាញ។

បច្ចុប្បន្ន អំពើរុកកួនឆាឆៅបានកើតមានស្ទើរគ្រប់ទីកន្លែង តួយ៉ាងនៅសាលារៀន កន្លែងធ្វើការក្នុងសហគមន៍ ឬទីកន្លែងផ្សេងៗ ដែលប្រព្រឹត្តដោយបុគ្គល ឬក្រុមមនុស្ស ក្នុងគោលដៅដាក់សម្ពាធផ្លូវចិត្តដល់ជនរងគ្រោះ ដើម្បីទាញយកផលប្រយោជន៍ឬបង្កឱ្យមានភាពវឹកវរក្នុង សហគមន៍ និងសង្គម។ ដោយសារភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាអំពើរុកកួនឆាឆៅបានពង្រីកវិសាលភាពដោយប្រើប្រាស់បច្ចេកវិទ្យានិងអ៊ីនធឺណិតជាមធ្យោបាយផ្តោតលើជនរងគ្រោះ។

តាមរយៈរបាយការណ៍របស់អង្គការមូលនិធិសម្រាប់កុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNICEF) ឆ្នាំ២០២០ បានបង្ហាញថាយុវជនកម្ពុជាដែលមានអាយុចន្លោះពី ១៥ឆ្នាំ ដល់ ២៥ឆ្នាំ ប្រមាណ ៨៥.៧% កំពុងជួបបញ្ហានៃការរុកកួនឆាឆៅដោយប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណិតក្នុង

ពេលដែលចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាមានប្រមាណ ៩.៧ លាននាក់ (៦០% នៃចំនួនប្រជាជនសរុប)។ លើសពីនេះក្នុងរបាយការណ៍ស្រាវជ្រាវរបស់ "Cambodia Education" បង្ហាញពីស្ថិតិនៃផលប៉ះពាល់កើតឡើងដោយអំពើរុកកួនឆាឆៅ (Bully) ដូចខាងក្រោម៖

- កុមារ និងយុវជនកម្ពុជាប្រមាណ ១៦០ ០០០នាក់ បានបោះបង់ការសិក្សា
- ក្នុងនោះមានយុវជនថ្នាក់វិទ្យាល័យ ប្រមាណ ១៤% បានព្យាយាមធ្វើអត្តឃាត
- ការចាកចេញពីផ្ទះ ចូលរួមសង្គមងងឹត ពេស្យាចារ និងអំពើល្មើសច្បាប់ផ្សេងៗ
- លើសពីនេះ មានផលប៉ះពាល់ជាច្រើនទៀត ដែលកើតឡើងដោយអំពើរុកកួនឆាឆៅនេះ។

ដើម្បីចូលរួមប្រយុទ្ធប្រឆាំងអំពើរុកកួនឆាឆៅដូចបានរៀបរាប់ខាងលើ ក្រៅពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល អាណាព្យាបាល គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន គឺជាបុគ្គលសំខាន់ ដែលទាមទារឱ្យមានការចូលរួមប្រយុទ្ធប្រឆាំងអំពើរុកកួនឆាឆៅមកលើកុមារ និងយុវជន ដែលជាធនធានមនុស្សសម្រាប់សង្គមជាតិ។

ឯកសារណែនាំបង្រៀនស្តីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ ចែកជា ២ជំពូក គឺជំពូក១ បង្ហាញពីខ្លឹមសារមេរៀនចំនួន ៥សំខាន់ៗដែលនាំឱ្យសិស្សស្គាល់នូវបញ្ញត្តិ និងពាក្យគន្លឹះមួយចំនួននៃបច្ចេកវិទ្យាឌីជីថល ឥទ្ធិពលអវិជ្ជមាន អាកប្បកិរិយានិងហានិភ័យ ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ យន្តការរាយការណ៍ និងវិធីស្វែងរកជំនួយ និងការកំណត់សំណួរបញ្ចប់មេរៀន (ជាសំណួរឆ្លុះបញ្ចាំង សំណួរប្រតិបត្តិ និងស្រាវជ្រាវបង្កើតជាគម្រោងផ្សព្វផ្សាយ)។ ជំពូក២ លំនាំនៃបង្រៀន និងរៀនមានបរិយាយអំពីគោលវិធីបង្រៀនសិស្សមជ្ឈមណ្ឌល សកម្មភាពតាមវិធីសាស្ត្របង្រៀន លំនាំវាយតម្លៃ និងការដាក់ពិន្ទុ។

ក្នុងដំណើរការបង្រៀននិងរៀននៃមេរៀននីមួយៗ សិស្សត្រូវរៀបចំកម្រងសំណួរ ចុះប្រមូលព័ត៌មាន វិភាគព័ត៌មាន រៀបចំផែនការ និងផ្សព្វផ្សាយផែនការដល់មូលដ្ឋាន (ក្នុងសាលារៀន សហគមន៍) រួចវាយតម្លៃ និងចងក្រងជាឯកសារស្នាដៃ សម្រាប់ដាក់ក្នុងបណ្ណាល័យ។

សិស្សត្រូវសាកសួរ និងប្រមូលព័ត៌មានអំពីសិស្សក្នុងសាលារៀន តើមានប៉ុន្មាននាក់មានទូរសព្ទប្រើ? ប៉ុន្មាននាក់មានទូរសព្ទឆ្លាតវៃ? ប៉ុន្មាននាក់ធ្លាប់ជួបប្រទះបទពិសោធន៍មិនល្អលើប្រព័ន្ធអនឡាញ ត្រូវបានគេលួងលោម កេងប្រវ័ញ្ច បៀតបៀន រុកកួនឆាឆៅ តាមគ្រប់ទម្រង់អនឡាញ និងផ្ទាល់? សិស្សលើកជាសំណូមពរ ឬសំណើអន្តរាគមន៍ផ្សេងៗ ដាក់ជូននាយកសាលា និងអាជ្ញាធរដែនដី។

សិស្សត្រូវធ្វើបទបង្ហាញរបកគំហើញនេះ ក្នុងសាលារៀន និងនៅតាមសហគមន៍តាមលំនាំនៃការរៀនបំណិនជីវិត។

# ជំពូក ១

## ខ្លឹមសារមេរៀន

មេរៀនទី ១

# អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល

**រយៈពេល៖ ០៣ ម៉ោងសិក្សា**

## បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សអាច៖

- រៀបរាប់បានពីពាក្យគន្លឹះ អត្ថប្រយោជន៍ និងសុវត្ថិភាពការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល
- អនុវត្តនូវវិធានចាំបាច់នានាដើម្បីរក្សាកេរ្តិ៍ឈ្មោះ ឯកជនភាព និងសុវត្ថិភាពពីគ្រោះថ្នាក់នៃការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល
- មានទម្លាប់ប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថលប្រកបដោយភាពឆ្លាតវៃ សេចក្តីគោរព ការទទួលខុសត្រូវ និងសុវត្ថិភាព។



អ្នកប្រើប្រាស់អ៊ីនធឺណិត បានកើនឡើងរហូតដល់ ៥.១៦ ពាន់លាននាក់ ឬ៦៤.៤% នៃចំនួនប្រជាជន សរុបនៅទូទាំងពិភពលោក គិតត្រឹមខែមករាឆ្នាំ២០២៣ (យោងគេហទំព័រ www.datare_portal.com) ក្នុងនោះ មានអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមសកម្មចំនួន ៤.៧៦ ពាន់លាននាក់ ឬស្មើនឹង ៥៩.៤% នៃចំនួនប្រជាជនសរុបនៅទូទាំងពិភពលោក។ យោងតាមស្ថិតិរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (www.itu.int) ឆ្នាំ២០២០ បង្ហាញថា ៧១% នៃចំនួនកុមារ និងយុវជនអាយុពី ១៥ ទៅ ២៤ឆ្នាំ សរុបនៅទូទាំងពិភពលោក បាននិងកំពុងប្រើប្រាស់អ៊ីនធឺណិត។

នៅក្នុងប្រទេសកម្ពុជា ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត បានកើនឡើងដល់ ១១.៣៧ លាននាក់ ឬ ៦៧.៥% នៃចំនួនប្រជាជនសរុប គិតត្រឹមខែមករា ឆ្នាំ២០២៣ ដែលមានកំណើនជាង ៦.៧% ធៀបនឹងឆ្នាំ២០២២។ ត្រឹមខែមករា ឆ្នាំ២០២៣ មានអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media) សរុបចំនួន១០.៩៥លាននាក់ ឬ៦៥%នៃចំនួនប្រជាជនសរុប ក្នុងនោះស្រីចំនួន ៤៥% និងប្រុសចំនួន ៥៥%។ បន្ថែមពីនេះ ៨៨% នៃចំនួនអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម មានអាយុ១៨ឆ្នាំឡើង។

បច្ចេកវិទ្យាអ៊ីនធឺណិតបានផ្តល់ឱ្យអ្នកប្រើប្រាស់នូវធនធាន និងឱកាសដ៏សម្បូរបែបសម្រាប់ការអប់រំ សិក្សាស្រាវជ្រាវ ច្នៃប្រតិដ្ឋ ចែករំលែក ភ្ជាប់ទំនាក់ទំនង លេងកម្សាន្ត និងធ្វើអាជីវកម្មប្រកបដោយភាពងាយស្រួលដល់ជីវិតប្រចាំថ្ងៃ។

បច្ចេកវិទ្យាអ៊ីនធឺណិតក៏ជាផ្នែកមួយ ដែលជួយជំរុញធនធានមនុស្ស ឱ្យក្លាយជាម្ចាស់នៃធម្មជាតិ បំពេញតម្រូវការ និងចិញ្ចឹមជីវិត។ មនុស្សជាច្រើនកំពុងប្រើប្រាស់បច្ចេកវិទ្យាក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ដូចជាការប្រើប្រាស់ឧបករណ៍ឌីជីថល ឬអេឡិចត្រូនិក ដូចជា កុំព្យូទ័រ ទូរសព្ទឆ្លាតវៃ ឧបករណ៍តាមដានសុខភាពទូរទស្សន៍ឆ្លាតវៃប្រព័ន្ធត្រួតពិនិត្យកាមេរ៉ាសុវត្ថិភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត និងកម្មវិធីអនឡាញដ៏សម្បូរបែប។

បច្ចេកវិទ្យាអ៊ីនធឺណិត និងឧបករណ៍ឌីជីថល កំពុងវិវត្តឥតឈប់ឈរទៅតាមការប្រែប្រួលផ្នែកវិទ្យាសាស្ត្រ និងតម្រូវការរបស់មនុស្សនាំឱ្យមានការបង្កើតនូវបច្ចេកវិទ្យាឧបករណ៍ និងកម្មវិធីថ្មីៗជាច្រើន។

## ពាក្យគន្លឹះ

**អ៊ីនធឺណិត** (Internet) គឺជាបណ្តាញសកលដ៏ធំទូលាយមួយដែលតភ្ជាប់កុំព្យូទ័រឬឧបករណ៍ឌីជីថលរាប់ពាន់លានជាមួយគ្នាដោយអនុញ្ញាតឱ្យមនុស្សទូទាំងពិភពលោកចូលដំណើរការ និងចែករំលែកព័ត៌មានតាមរយៈគេហទំព័រ និងកម្មវិធី(Apps)។ អ៊ីនធឺណិតមានលក្ខណៈពិសេសជាច្រើនដែលកុមារអាចទាញយកប្រយោជន៍បាននៅពេលប្រើប្រាស់ត្រឹមត្រូវ និងមានការណែនាំពី ឪពុកម្តាយ អាណាព្យាបាល និងមនុស្សជុំវិញខ្លួន។ ការប្រើប្រាស់អ៊ីមែល ការលេងហ្គេមអនឡាញ ការមើលវីដេអូ និងការបង្កើតទំនាក់ទំនងសង្គម អាចធ្វើឡើងបានតាមរយៈការប្រើប្រាស់អ៊ីនធឺណិត ឧបករណ៍ឌីជីថល និងកម្មវិធីអនឡាញ។

**អនឡាញ (Online)** សំដៅដល់ការភ្ជាប់ឧបករណ៍ឌីជីថលទៅនឹងបណ្ដាញអ៊ីនធឺណិតដែលអនុញ្ញាតឱ្យឧបករណ៍ទាំងនោះចូលប្រើប្រាស់កម្មវិធី ឬធនធាននៅលើអនឡាញបាន។ នៅពេលដែលអ្នកនៅលើអនឡាញ មានន័យថាអ្នកបានភ្ជាប់ឧបករណ៍ឌីជីថលរបស់អ្នកទៅនឹងអ៊ីនធឺណិត ដើម្បីធ្វើអ្វីមួយនៅលើអនឡាញ។

**បច្ចេកវិទ្យាឌីជីថល** (Digital Technology) សំដៅដល់បច្ចេកវិទ្យាអេឡិចត្រូនិកដែលត្រូវបានគេបង្កើតឡើង និងប្រើប្រាស់ដើម្បីរក្សាទុក ធ្វើដំណើរការ(បំប្លែង និងវិភាគទិន្នន័យ) បញ្ជូន និងបង្ហាញព័ត៌មាន។ បច្ចេកវិទ្យាឌីជីថលបានផ្លាស់ប្ដូរទិដ្ឋភាពផ្សេងៗនៃជីវិតរបស់អ្នកដូចជាការស្រាវជ្រាវ ទំនាក់ទំនង ការកម្សាន្តការធ្វើអាជីវកម្ម និងការអប់រំ។ បច្ចេកវិទ្យាឌីជីថលមានដូចជាកុំព្យូទ័រ ទូរសព្ទឆ្លាតវៃ កម្មវិធីអ៊ីនធឺណិតនិងប្រព័ន្ធផ្សព្វផ្សាយឌីជីថលជាច្រើនទៀត។ ពិភពឌីជីថលក៏បានផ្ដល់នូវឱកាសសម្រាប់ការតភ្ជាប់ ច្នៃប្រតិដ្ឋបង្កើតមធ្យោបាយដ៏សម្បូរបែបក្នុងការប្រាស្រ័យទាក់ទងគ្នា និងការទទួលបានព័ត៌មាន។




**មាតិកា (Content)** សំដៅដល់អ្វីៗទាំងអស់ដែលអ្នកអាចមើលឃើញ អាន ទស្សនា ស្ដាប់ នៅលើអ៊ីនធឺណិត ឬកម្មវិធីអនឡាញ ដូចជាគេហទំព័រ Google YouTube Facebook ។ល។ មាតិកាត្រូវបានគេបង្ហោះ ចែករំលែកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័រផ្សេងៗទៀត។ មាតិកាមានច្រើនសន្ធឹកសន្ធាប់ណាស់ ប៉ុន្តែមិនមែនអ្វីៗគ្រប់យ៉ាងគឺសុទ្ធតែសមរម្យ ឬមានសុវត្ថិភាពសម្រាប់កុមារនោះទេ។





**ថ្នាលបច្ចេកវិទ្យា (Platform)** សំដៅដល់ទីកន្លែងដែលអ្នកតភ្ជាប់អ៊ីនធឺណិត អាចចូលទៅប្រើប្រាស់ ដើម្បីស្វែងរក និងចែករំលែកព័ត៌មានមាតិកា បញ្ជូនសារ ឬភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃពីចម្ងាយ។ ថ្នាលបច្ចេកវិទ្យារួមមានបណ្ដាញទំនាក់ទំនងសង្គមកម្មវិធីផ្ញើសារ និងហ្គេមអនឡាញ ជាដើម។

**គេហទំព័រ (Website)** គឺជាបណ្ដុំនៃទំព័របណ្ដាញដែលមានផ្ទុកមាតិកាផ្សេងៗ។ វាត្រូវបានកំណត់អត្តសញ្ញាណសម្គាល់ដោយឈ្មោះជាទូទៅថា (Domain Name) នៅលើម៉ាស៊ីនបម្រើ (Server) ដែលមានគេហទំព័រយ៉ាងហោចណាស់មួយ។ ជាធម្មតាគេហទំព័របង្ហាញពីប្រធានបទ ក្នុងគោលបំណងជាក់លាក់ដូចជាគេហទំព័រព័ត៌មាន គេហទំព័រអប់រំ គេហទំព័ររូបភាព ឬ វីដេអូ គេហទំព័រពាណិជ្ជកម្ម គេហទំព័រកម្សាន្ត ជាដើម។

**តំណភ្ជាប់ (Link)** នៅក្នុងបរិបទនៃប្រព័ន្ធព័ត៌មានវិទ្យា សំដៅដល់មធ្យោបាយ ឬបណ្ដាញតភ្ជាប់រវាងឯកសារនៅលើបណ្ដាញអ៊ីនធឺណិត។នៅពេលដែលអ្នកចុចលើតំណភ្ជាប់កុំព្យូទ័រឬទូរសព្ទរបស់អ្នកនឹងចូលទៅកាន់អាសយដ្ឋានគេហទំព័រហើយបង្ហាញអ្នកនូវទំព័រដែលតំណភ្ជាប់នោះនាំឆ្ពោះទៅ។តំណភ្ជាប់មួយចំនួនចាប់ផ្តើមដោយ 'https://' និងអាចត្រូវបានគេចែករំលែកតាមគេហទំព័រការផ្ញើអ៊ីមែល ឬកម្មវិធីបណ្ដាញទំនាក់ទំនងសង្គម។

## ២. អត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិត



អ៊ីនធឺណិតបានផ្លាស់ប្តូររបៀបដែលអ្នកធ្វើទំនាក់ទំនងការចែករំលែកនិងទទួលបានព័ត៌មាន។ វាមានសក្តានុពលដ៏ធំមហិមាក្នុងការធ្វើឱ្យជីវិតរបស់អ្នកកាន់តែល្អប្រសើរ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានប្រសិនបើអ្នកយល់ពីរបៀបប្រើប្រាស់វាដោយឆ្លាតវៃ។ លើសពីនេះអ៊ីនធឺណិតបានក្លាយជាធនធានដែលមិនអាចខ្វះបាន និងផ្តល់ឱ្យកុមារនូវលទ្ធភាពចូលទៅកាន់ពិភពនៃព័ត៌មាន និងចំណេះដឹងដ៏មានប្រយោជន៍ និងឱកាសសម្រាប់ការរៀនសូត្រស្រាវជ្រាវ ច្នៃប្រតិដ្ឋ ចែករំលែក ភ្ជាប់ទំនាក់ទំនង ការកម្សាន្តសម្រាប់ជីវិតប្រចាំថ្ងៃ។ បច្ចុប្បន្ន អ៊ីនធឺណិតបានក្លាយជាបច្ចេកវិទ្យា ឬមធ្យោបាយ ដ៏មានឥទ្ធិពល និងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់រួមមានដូចខាងក្រោម៖

**សកម្មភាពទី១៖ បង្កើតផ្ទាំងរូបភាពបច្ចេកវិទ្យាអ៊ីនធឺណិត**

ការងារក្រុម៖ ចូរគូរផ្ទាំងរូបភាពអំពីអត្ថប្រយោជន៍របស់បច្ចេកវិទ្យាអ៊ីនធឺណិត ដោយប្រើប្រាស់ពណ៌ រូបភាព និងអត្ថបទ។ បន្ទាប់មក បង្ហាញផ្ទាំងរូបភាព និងពន្យល់ពីអត្ថន័យរូបភាពដែលអ្នកបានគូររួចដល់ក្រុមដទៃ។

## ២.១ ការសិក្សា

បច្ចេកវិទ្យាអ៊ីនធឺណិតបាននាំមកនូវអត្ថប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ការអប់រំ ស្រាវជ្រាវ និងការរុករកតាមវិធីផ្សេងៗគ្នាជាច្រើន រួមមានដូចជា៖

- ❖ ការទទួលបានព័ត៌មាន៖ អ៊ីនធឺណិតផ្តល់ភាពងាយស្រួលដល់ការចូលប្រើប្រាស់ព័ត៌មានដ៏សម្បូរបែប ក្នុងការសិក្សាស្រាវជ្រាវ ស្វែងរកព័ត៌មាន ឬចំណេះដឹងអំពីប្រធានបទជាច្រើន ដូចជា បណ្ណាល័យឌីជីថល និងគេហទំព័រអប់រំ ដែលជួយបង្កើនដល់ការសិក្សារៀនសូត្រ និងគាំទ្រដល់ការអភិវឌ្ឍចំណេះដឹង និងជំនាញ។
- ❖ ការសិក្សាតាមអនឡាញ៖ បច្ចេកវិទ្យាអ៊ីនធឺណិតផ្តល់នូវបទពិសោធន៍រៀនតាមអនឡាញដល់អ្នកដែលអាចសិក្សាជាមួយអ្នកអប់រំ និងអ្នកជំនាញមកពីជុំវិញពិភពលោកតាមរយៈការប្រជុំជាវីដេអូ ជាដើម។ ទាំងនេះជួយជំរុញការចែករំលែកចំណេះដឹង ការយល់ដឹងពីវប្បធម៌ផ្សេងៗ និងការផ្លាស់ប្តូរគំនិត និងបទពិសោធន៍ល្អៗ។
- ❖ ទស្សនៈវិស័យសកល និងការរុករក៖ តាមរយៈអ៊ីនធឺណិតអ្នកអាចស្វែងយល់ពីទស្សនៈ និងវប្បធម៌ចម្រុះ ហើយពួកគេអាចភ្ជាប់ទំនាក់ទំនងជាមួយបុគ្គលមកពីមជ្ឈដ្ឋានផ្សេងៗចូលមើលព័ត៌មាន និងព្រឹត្តិការណ៍ជាសកល។ ទាំងនេះជួយពង្រីកការយល់ដឹងរបស់ពួកគេ និងលើកទឹកចិត្តឱ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីពិភពលោក។

## ២.២ ការស្រាវជ្រាវ និងច្នៃប្រតិដ្ឋ

បច្ចេកវិទ្យាអ៊ីនធឺណិតជួយសម្រួលដល់ការស្រាវជ្រាវ និងការច្នៃប្រតិដ្ឋបានយ៉ាងល្អប្រសើរ។ អ្នកស្រាវជ្រាវអាចប្រើប្រាស់ព័ត៌មានជាច្រើនដូចជាមូលដ្ឋានទិន្នន័យបណ្ណាល័យឌីជីថល កាលិកបត្រ និងទិនានុប្បវត្តិ ដើម្បីសិក្សាប្រកបដោយភាពងាយស្រួល។ អ្នកស្រាវជ្រាវអាចស្វែងរកការសិក្សាពីមុនៗ ដូចជា របកគំហើញនិងការបោះពុម្ពផ្សាយដ៏មានប្រយោជន៍ជាច្រើន។ ការទទួលបានចំណេះដឹងដ៏សម្បូរបែបនេះ ជួយឱ្យអ្នកស្រាវជ្រាវបង្កើតថ្មីដោយពឹងផ្អែកលើធនធានដែលមានស្រាប់ ទទួលបានការយល់ដឹងបន្ថែម និងបន្តធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត។

## ២.៣ ការភ្ជាប់ទំនាក់ទំនង

ជាមួយនឹងបច្ចេកវិទ្យាអ៊ីនធឺណិត អ្នកអាចភ្ជាប់ទំនាក់ទំនងទៅកាន់មិត្តភក្តិ ក្រុមគ្រួសារ និងអ្នកដទៃបានភ្លាមៗ និងឆាប់រហ័ស តាមរយៈការប្រើអ៊ីមែល ប្រព័ន្ធផ្សព្វផ្សាយសង្គម ឬកម្មវិធីផ្ញើសារ ដើម្បីសន្ទនាក្នុងពេលតែមួយ និងចែករំលែកព័ត៌មាន ឬមាតិកា យ៉ាងទូលំទូលាយ។

អ៊ីនធឺណិតអនុញ្ញាតឱ្យអ្នកអាចធ្វើការសន្ទនាទល់មុខគ្នាជាមួយមនុស្សដែលនៅឆ្ងាយតាមរយៈការហៅជាវីដេអូ ដោយប្រើកម្មវិធីអនឡាញ ដូចជា Messenger Instagram Viber Telegram WhatsApp Zoom GoogleMeet FaceTime WeChat ជាដើម ដែលអាចឱ្យអ្នកមើលឃើញ និងស្តាប់ឮគ្នាទៅវិញទៅមក ដូចស្ថិតនៅក្នុងកន្លែងតែមួយ។ កម្មវិធីទាំងនោះមានប្រយោជន៍ជាច្រើនជាពិសេសសម្រាប់រក្សាទំនាក់ទំនងជាមួយមនុស្សជាទីស្រឡាញ់ដែលរស់នៅឆ្ងាយ។

វេទិកាបណ្ដាញទំនាក់ទំនងសង្គម ដូចជា Facebook Instagram TikTok Snapchat Discord អនុញ្ញាតឱ្យអ្នកភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ គ្រួសារ និងបង្កើតមិត្តថ្មី ដែលអ្នកអាចចែករំលែកព័ត៌មានថ្មីៗ រូបភាព និងវីដេអូ ហើយទទួលបានមតិយោបល់ និងការចូលចិត្តពីអ្នកដទៃ។

អ៊ីនធឺណិតអនុញ្ញាតឱ្យអ្នកចូលរួមសហគមន៍អនឡាញជាមួយមនុស្សដែលមានចំណាប់អារម្មណ៍ ឬចំណង់ចំណូលចិត្តស្រដៀងគ្នា។ អ្នកអាចភ្ជាប់ជាមួយមនុស្សម្នាក់ ឬជាក្រុមដែលមានគំនិតដូចគ្នា សួរសំណួរ និងរៀនពីគ្នាទៅវិញទៅមក ហើយជួយអ្នកបង្កើតទំនាក់ទំនងកាន់តែល្អជាមួយអ្នកដទៃ ទោះបីជាអ្នកមិនធ្លាប់ជួបពួកគេដោយផ្ទាល់ក៏ដោយ។

## ៣. សិទ្ធិកុមារក្នុងបរិស្ថានឌីជីថល




សព្វថ្ងៃនេះ កុមារចំណាយពេលកាន់តែច្រើននៅលើអ៊ីនធឺណិត ដូច្នេះហើយសិទ្ធិឌីជីថលរបស់ពួកគេត្រូវតែទទួលបានការគោរព។ សិទ្ធិឌីជីថលរបស់កុមាររួមបញ្ចូលទាំងការចូលប្រើមាតិកាការទទួលបានព័ត៌មានដែលសមស្របតាមអាយុរបស់ពួកគេ ការការពារឯកជនភាព ទិន្នន័យផ្ទាល់ខ្លួន ការការពារពីគ្រោះថ្នាក់ ឬអំពើកេងប្រវ័ញ្ចលើអ៊ីនធឺណិត ការអប់រំដែលរួមបញ្ចូលអន្តរកម្ម និងជំនាញឌីជីថល ព្រមទាំងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ដោយគ្មានការរើសអើង។

### ៣.១ សិទ្ធិចូលប្រើប្រាស់មាតិកា និងទទួលបានព័ត៌មាន

កុមារមានសិទ្ធិទទួលបានព័ត៌មាន ឬចូលប្រើប្រាស់មាតិកាអនឡាញដែលសមស្របនឹងអាយុ និងដំណាក់កាលនៃការអភិវឌ្ឍរបស់ពួកគេ ដែលមាតិកាទាំងនេះអាចជួយពួកគេរៀន និងអភិវឌ្ឍខ្លួន។ គេហទំព័រ និងកម្មវិធីអនឡាញគួរតែផ្តល់នូវមាតិកា ដែលមានសុវត្ថិភាព ការអប់រំនិងសមរម្យសម្រាប់កុមារព្រោះអាចជួយការពារពួកគេពីមាតិកាមិនសមរម្យ ឬមាតិកាដែលអាចបង្កគ្រោះថ្នាក់។

## ៣.២ សិទ្ធិទទួលបានការការពារឯកជនភាព និងអត្តសញ្ញាណ

កុមារមានសិទ្ធិឯកជនភាព និងការការពារព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ នៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត។ ទិន្នន័យផ្ទាល់ខ្លួន និងអត្តសញ្ញាណឌីជីថលរបស់កុមារ ត្រូវបានការពារពីការប្រើប្រាស់ខុស ការកេងប្រវ័ញ្ចដោយបុគ្គល ឬក្រុមណាមួយ ក្នុងគោលបំណងផ្ទាល់ខ្លួន ឬពាណិជ្ជកម្ម ឬការគំរាមកំហែងផ្សេងទៀត។

- ព័ត៌មានផ្ទាល់ខ្លួន៖ ដូចនៅក្នុងពិភពពិតដែរ កុមារមានសិទ្ធិរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេជាឯកជននៅពេលកំពុងប្រើប្រាស់អ៊ីនធឺណិត។ ព័ត៌មានផ្ទាល់ខ្លួនរួមមានដូចជាឈ្មោះ អាយុ អាសយដ្ឋានសាលារៀនលេខទូរសព្ទ និងរូបថតរបស់ពួកគេ ដែលមិនគួរការចែករំលែកនៅលើអ៊ីនធឺណិត ដើម្បីការពារឯកជនភាព និងសុវត្ថិភាព។

- ការយល់ព្រមនិងការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន៖ កុមារមានសិទ្ធិគ្រប់គ្រងលើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងផ្តល់ការយល់ព្រមសម្រាប់ការប្រើប្រាស់ព័ត៌មានទាំងនោះ។ គេហទំព័រ កម្មវិធី និងវេទិកាអនឡាញ គួរតែស្នើសុំការអនុញ្ញាតមុនពេលប្រមូល ប្រើប្រាស់ ឬចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ។ កុមារ រួមជាមួយនឹងឪពុកម្តាយឬអាណាព្យាបាលរបស់ពួកគេគួរតែមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តអំពី របៀបដែលព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានប្រើប្រាស់ដោយកម្មវិធីអនឡាញ។

- ដានឌីជីថល ៖ សកម្មភាពអនឡាញតែងបន្សល់ទុកដានឌីជីថល ដូច្នេះអ្វីៗដែលកុមារបង្ហោះ ចែករំលែកឬបញ្ចេញមតិអាចមើលឃើញដោយអ្នកដទៃហើយអាចមានផលវិបាករយៈពេលវែង។ កុមារគួរត្រូវបានលើកទឹកចិត្តឱ្យគិតមុនពេលពួកគេចែករំលែក ដើម្បីជួយការពារឯកជនភាព និងកេរ្តិ៍ឈ្មោះរបស់ពួកគេ។

## ៣.៣ សិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់ ឬអំពើកេងប្រវ័ញ្ចលើអ៊ីនធឺណិត

កុមារត្រូវរួចផុតពីការគំរាមកំហែង បន្លំ ឆបោក លួងលោម ញុះញង់ រំលោភបំពាន និងអាកប្បកិរិយាដែលអាចបង្កគ្រោះថ្នាក់ផ្សេងទៀតនៅលើអ៊ីនធឺណិត។ កុមារមានសិទ្ធិទទួលបានការការពារពីការផលិត ចែកចាយ លក់ដូររូបភាពអាសអាភាស សម្ភារៈរំលោភបំពានផ្លូវភេទ មាតិកាហិង្សា និងការកេងប្រវ័ញ្ចគ្រប់រូបភាពលើប្រព័ន្ធអនឡាញ។

ការការពារឯកជនភាពរបស់កុមារនៅលើអ៊ីនធឺណិតក៏ជាផ្នែកមួយ នៃការការពារពួកគេពីការគំរាមកំហែងតាមអ៊ីនធឺណិតផងដែរ។ មាតាបិតា អាណាព្យាបាល និងវេទិកាអនឡាញគួរតែចាត់វិធានការដើម្បីធានាសុវត្ថិភាពលើអ៊ីនធឺណិតរបស់កុមារដូចជាការកំណត់ឯកជនភាពការត្រួតពិនិត្យសកម្មភាពអនឡាញ និងការអប់រំកុមារអំពីវិធានសុវត្ថិភាពដែលគួរអនុវត្តលើអនឡាញ។

### ៣.៤ សិទ្ធិបញ្ចេញមតិ និងការគោរពឯកជនភាព

កុមារមានសិទ្ធិចូលរួម និងបញ្ចេញមតិយោបល់លើបញ្ហាផ្សេងៗដែលអាចជះឥទ្ធិពល ( ទាំងវិជ្ជមាន និងអវិជ្ជមាន ) ដល់ពួកគេ។ នៅពេលមានអាយុ និងសមត្ថភាពសមស្រប កុមារមានសិទ្ធិចូលរួមចំណែក និងចែករំលែកមាតិកានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបង្ហាញពីភាពច្នៃប្រតិដ្ឋ បទពិសោធន៍កង្វល់ និងភាពជាបុគ្គលរបស់ពួកគេ។

នៅពេលមាតាបិតាអាណាព្យាបាលកុមារបុគ្គលិកអប់រំ និងសង្គមទាំងមូលមានការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិកុមារក្នុងបរិស្ថានឌីជីថលទាំងនោះពួកគេកាន់តែអាចជួយគាំទ្រ និងផ្តល់សិទ្ធិអំណាចដល់កុមារឱ្យទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងជួយការពារសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញបានកាន់តែប្រសើរ។

## ៤. វេទិកាអនឡាញ

វេទិកា ឬកម្មវិធីអនឡាញជាច្រើនត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ រួមមានដូចជាវេទិកាបណ្តាញទំនាក់ទំនងសង្គមកម្មវិធីផ្ញើសារតាមអនឡាញហ្គេមអនឡាញកម្មវិធីផ្សាយផ្ទាល់ជាដើម។ វេទិកានិងកម្មវិធីអនឡាញជាច្រើនកំពុងពេញនិយម ជាពិសេសក្នុងចំណោមកុមារ និងក្មេងវ័យជំទង់រួមមានដូចជា៖

### ៤.១ វេទិកាបណ្តាញទំនាក់ទំនងសង្គម



ជាកម្មវិធីដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ ចែករំលែក រៀនអ្វីៗដែលថ្មី មើលវីដេអូ បង្ហាញពីភាពច្នៃប្រតិដ្ឋ ការកម្សាន្ត ។ល។ វេទិកាបណ្តាញទំនាក់ទំនងសង្គម រួមមានដូចជា៖

**Instagram៖** កម្មវិធីនេះអនុញ្ញាតឱ្យអ្នកចែករំលែករូបភាព និងវីដេអូពីទូរសព្ទឆ្លាតវៃរបស់អ្នកជាមួយអ្នកដទៃ។ វាជាកម្មវិធីដែលពេញនិយមសម្រាប់កុមារ និងក្មេងវ័យជំទង់ ដោយ សារតែសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ ទទួលបានបច្ចុប្បន្នភាពអំពីអ្វីកំពុងកើតឡើង និងបង្ហោះមាតិកាប្រកបដោយភាពច្នៃប្រតិដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ Instagram ក៏អាចបង្កហានិភ័យនៃការគំរាមកំហែងតាមអ៊ីនធឺណិតទំនាក់ទំនងមិនសមរម្យពីមនុស្សចម្លែក និងការប្រៀបធៀបខ្លួនឯងទៅនឹងអ្នកដទៃ ជាដើម។

**YouTube** ជាវេទិកាដែលអ្នកអាចមើល បង្កើត និងចែករំលែកមាតិកាវីដេអូ ស្ទើរតែគ្រប់ប្រធានបទ ហើយវាផ្តល់អត្ថប្រយោជន៍ដល់ការអប់រំ និងគំនិតច្នៃប្រតិដ្ឋជាច្រើន។ ប៉ុន្តែមិនខុសពីវេទិកាដទៃទេ វាក៏អាចបង្កហានិភ័យនៃការជួបប្រទះមាតិកាមិនសមរម្យ ដែលអាចជះឥទ្ធិពលអវិជ្ជមាន ការគំរាមកំហែង និងការធ្លាក់ទឹកចិត្តជាដើម។

**TikTok** ជាកម្មវិធីដែលបានដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៦ និងទទួលបានប្រជាប្រិយភាពក្នុងចំណោមកុមារនិងក្មេងវ័យជំទង់។អ្នកអាចប្រើកម្មវិធីនេះដើម្បីបង្កើតនិងចែករំលែក វីដេអូជាមួយតន្ត្រីប្រកបដោយភាពច្នៃប្រតិដ្ឋ និងរីករាយសកម្មភាពបែបកំប្លែង ការប្រកួតប្រជែងនិងមាតិកាផ្សេងទៀត ជាមួយអ្នកប្រើប្រាស់ដទៃនៅលើ TikTok។ ទោះជាយ៉ាងណាក៏ដោយ TikTok ក៏អាចបង្កហានិភ័យជុំវិញមាតិកាមិនសមរម្យ បញ្ហាឯកជនភាព និងការវក់ដែលអាចកើតមាន ដោយសារមានការរចនាដ៏ទាក់ទាញរបស់កម្មវិធីនេះ និងមាតិកាដែលគេបង្ហោះចែករំលែក។

**Snapchat** ជាវេទិកាដែលអនុញ្ញាតឱ្យអ្នកចែករំលែករូបភាព វីដេអូ និងអត្ថបទដែលនឹងរលប់បាត់ទៅវិញក្នុងរយៈពេលដ៏ខ្លី។ វត្តមានរយៈពេលដ៏ខ្លីរបស់មាតិកាដែលបានបង្ហោះបានទាក់ទាញចិត្តកុមារ និងក្មេងវ័យជំទង់ជាច្រើនឱ្យប្រើកម្មវិធីនេះព្រោះពួកគេយល់ថាវាជាវេទិកាដែលមានលក្ខណៈឯកជន។ ទោះបីកម្មវិធីនេះមានភាពវិជ្ជមានច្រើនក្តីក៏ដោយ វាក៏នៅតែអាចបង្កហានិភ័យដល់អ្នកប្រើប្រាស់ជុំវិញមាតិកាមិនសមរម្យ និងមិនផ្តោតអារម្មណ៍លើការងារសាលា ឬការងារផ្ទះដោយសារការប្រើប្រាស់ច្រើនលើសលប់ពេក។

## ៤.២ កម្មវិធីផ្ញើសារតាមអនឡាញ




ជាកម្មវិធីដែលអ្នកប្រើប្រាស់អាចប្រាស្រ័យទាក់ទងគ្នា ឬចែករំលែកមាតិកាដែលមានលក្ខណៈឯកជន តាមរយៈការផ្ញើសារជាអត្ថបទ សម្លេង រូបថត វីដេអូ ឬរូបភាពផ្សាយផ្ទាល់។ កម្មវិធីទាំងនេះរួមមាន ដូចជា Messenger Telegram WhatsApp Line Viber ជាដើម។ ដោយសារកម្មវិធីទាំងនេះអនុញ្ញាត ឱ្យអ្នកប្រើប្រាស់ភ្ជាប់ទំនាក់ទំនងគ្នាបានដោយផ្ទាល់ វាអាចបង្កហានិភ័យទាក់ទងនឹងមាតិកាមិនសមរម្យ ការបង្កើតទំនាក់ទំនងជាមួយមនុស្សប្លែកមុខ ការចែករំលែកព័ត៌មានផ្ទាល់ខ្លួន ឬរូបភាពមានលក្ខណៈឯកជនជាដើម។

## ៤.៣ កម្មវិធីហ្គេមអនឡាញ

ជាកម្មវិធីដែលត្រូវបានបង្កើតឡើងសម្រាប់ការកម្សាន្តប្រកបដោយភាពច្នៃប្រតិដ្ឋហើយមានសមត្ថភាព អាចឱ្យអ្នកប្រើប្រាស់ម្នាក់ ឬច្រើននាក់ចូលរួមលេងជាមួយគ្នា និងអាចជជែកគ្នាពីចម្ងាយ ព្រមទាំងអាចចែករំលែកវីដេអូផ្សាយផ្ទាល់បានផងដែរ។ កម្មវិធីហ្គេមជាច្រើនបានបង្កើតឡើង ដើម្បីជួយកុមារអភិវឌ្ឍជំនាញមូលដ្ឋានមួយចំនួនរួមមានការដោះស្រាយបញ្ហា ច្នៃប្រតិដ្ឋ និងបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ ដែលមានចំណាប់អារម្មណ៍ប្រហាក់ប្រហែលគ្នា។ កម្មវិធីទាំងនេះមានដូចជា Minecraft Rocket League ABCMouse Funbrain PBS Kids...។



កម្មវិធីហ្គេមមួយចំនួនអាចធ្វើឱ្យកុមារប្រឈមនឹងមាតិកាមិនសមរម្យ ដែលអាចជាបង្កើតទំនាក់ទំនង នាំឱ្យបង្កជាគ្រោះថ្នាក់ ទទួលរងការគំរាមកំហែង ឬធ្លាក់ក្នុងល្បិចលួងលោមឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទជាដើម។ ឪពុកម្តាយ អាណាព្យាបាលគួរវាយតម្លៃ និងត្រួតពិនិត្យកម្មវិធីហ្គេម ដើម្បីធានាថាកម្មវិធីមានភាពសមស្របនឹងអាយុ និងជាតម្រូវការអប់រំរបស់កូន។

**សកម្មភាពទី២៖ បំផុសគំនិតអំពីវេទិកាអនឡាញ**

ចូរអ្នកលើកអំពីហ្គេមអនឡាញណាមួយ ដែលអ្នកចូលចិត្ត និងបរិយាយអំពីគុណសម្បត្តិ និងគុណវិបត្តិនៃហ្គេមនោះ?

## ៤.៤ កម្មវិធីផ្សាយផ្ទាល់តាមអនឡាញ

វេទិកាផ្សាយផ្ទាល់តាមអនឡាញ អនុញ្ញាតឱ្យអ្នកបង្កើតមាតិកាផ្សាយវីដេអូផ្ទាល់ឱ្យអ្នកដទៃចូលមើលពីចម្ងាយក្នុងពេលតែមួយ។ វេទិកាផ្សាយផ្ទាល់ដ៏ពេញនិយមមួយចំនួនរួមមាន YouTube Live Twitch Facebook Bingo Live Telegram Live Steam និង Instagram Live ជាដើម។ បើទោះជាកម្មវិធីផ្សាយផ្ទាល់ទាំងនេះអាចជាមធ្យោបាយដ៏រីករាយមួយសម្រាប់កុមារ និងក្មេងវ័យជំទង់ ក្នុងការបញ្ចេញមតិ និងរក្សាទំនាក់ទំនងជាមួយអ្នកដទៃ ក៏អាចបង្កឱ្យមានហានិភ័យដែលអ្នកគួរតែដឹង។ អ្នកមើលអាចបង្ហោះមតិមិនសមរម្យ ក្នុងអំឡុងពេលផ្សាយ ហើយអ្នកបង្កើតមាតិកាអាចប្រឈមនឹងការគំរាមកំហែង ឬការរុកកួនឆាឆៅជាដើម។ មាតិកាដែលផ្សាយបន្តផ្ទាល់ក៏ពិបាកក្នុងការត្រួតពិនិត្យផងដែរ នៅពេលដែលបង្ហោះចេញទៅ។

**សកម្មភាពទី៣៖ បំផុសគំនិតអំពីវេទិកាអនឡាញ**

ការងារក្រុម៖ ចូរពិភាក្សាអំពីហានិភ័យដែលអាចកើតមានទាក់ទងនឹងវេទិកាអនឡាញណាមួយ (Facebook Instagram TikTok Telegram Line...) និងផ្តល់គន្លឹះសម្រាប់រក្សាសុវត្ថិភាពនៅពេលប្រើប្រាស់វា។ ចូរសរសេរគំនិតរបស់អ្នកនៅលើក្តារខៀន ឬផ្ទាំងក្រដាសធំ។ បន្ទាប់មកចាត់តំណាងក្រុមឡើងធ្វើបទបង្ហាញ។

## ៥. កេរ្តិ៍ឈ្មោះ ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន និងសុវត្ថិភាពលើប្រព័ន្ធអនឡាញ

### ៥.១ កេរ្តិ៍ឈ្មោះនៅលើអនឡាញ

កេរ្តិ៍ឈ្មោះអនឡាញរបស់អ្នកចាប់ផ្ដើមបង្កើតឡើងនៅពេលអ្នកប្រើប្រាស់អ៊ីនធឺណិត និងបណ្ដាញទំនាក់ទំនងសង្គមដូច្នេះអ្នកគួរតែបន្តរក្សាកេរ្តិ៍ឈ្មោះនេះឱ្យបានល្អ។ ខាងក្រោមគឺជាវិធីមួយចំនួនដែលអ្នកគួរអនុវត្ត ដើម្បីរក្សាកេរ្តិ៍ឈ្មោះអនឡាញដ៏ល្អរបស់អ្នក៖

- ពិនិត្យមើលបណ្ដាញទំនាក់ទំនងសង្គម និងគណនីអនឡាញរបស់អ្នក ដើម្បីជានាភាពត្រឹមត្រូវ និងកែតម្រូវព័ត៌មានណាដែលត្រូវធ្វើបច្ចុប្បន្នភាព ឬមិនត្រឹមត្រូវអំពីខ្លួនអ្នក។
- លុបមាតិកាចាស់ៗ ដែលមិនត្រឹមត្រូវពីចំណង់ចំណូលចិត្តបច្ចុប្បន្នរបស់អ្នក។
- បង្ហោះតែមាតិកាណាដែលវិជ្ជមាន ត្រឹមត្រូវ មានប្រយោជន៍ និងឆ្លុះបញ្ចាំងពីការពិត។
- ពិនិត្យមើលលើមាតិកា ឬរូបភាពណាដែលអ្នកដទៃបានភ្ជាប់ ( Tag ) អ្នកចូល ហើយអ្នកមិនចង់បង្ហាញជាសាធារណៈ ដូច្នេះអ្នកត្រូវដកភ្ជាប់ ( Tag ) ចេញដោយខ្លួនឯង ឬស្នើសុំឱ្យអ្នកបង្ហោះលុប ឬកែសម្រួល។
- ពិនិត្យមើលព័ត៌មាន អ្នកសរសេរ ឬប្រភពព័ត៌មាន មុននឹងជឿថាវាជាការពិត។
- គិតពីទស្សនៈផ្សេងៗគ្នាជុំវិញពីបញ្ហាចៀសវាងការប្រកាន់យកតែមតិខ្លួនឯងដោយផ្អែកលើប្រភពតែមួយ។ ចៀសវាងការផ្សព្វផ្សាយ ឬចែករំលែកមាតិកា ដោយមិនបានផ្ទៀងផ្ទាត់ត្រឹមត្រូវ។ វាយតម្លៃ និងផ្ទៀងផ្ទាត់ប្រភពផ្សេងៗឱ្យបានច្រើនមុននឹងចែករំលែកព័ត៌មាននោះ។
- រាយការណ៍អំពីមាតិកាដែលបង្កគ្រោះថ្នាក់ ឬខុសច្បាប់ទៅកាន់អាជ្ញាធរ ឬអ្នកធ្វើការពាក់ព័ន្ធនៅពេលអ្នកជួបប្រទះមាតិកាទាំងនោះ។

### ៥.២ ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន

ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនតាំងពីការចាប់ផ្ដើមប្រើប្រាស់ដំបូង ជួយបង្កើនសុវត្ថិភាពលើប្រព័ន្ធអនឡាញរបស់អ្នកសម្រាប់ពេលអនាគត។ អ្នកត្រូវដឹងថា អ្វីជាព័ត៌មានផ្ទាល់ខ្លួនដែលមិនគួរចែករំលែក និងហានិភ័យដែលអាចកើតឡើងពីការចែករំលែកព័ត៌មានផ្ទាល់ខ្លួនច្រើនលើសលប់។ ព័ត៌មានទាំងនេះរួមមាន៖ ឈ្មោះពេញ ថ្ងៃ ខែ ឆ្នាំ កំណើត អាសយដ្ឋានលេខទូរសព្ទសាលារៀនទម្លាប់ប្រចាំថ្ងៃទ្រព្យសម្បត្តិបងប្អូនជាដើម។



ខាងក្រោមនេះជាគន្លឹះមួយចំនួនដែលអ្នកគួរអនុវត្តដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក នៅលើអនឡាញ៖

- ចូរកំណត់ឯកជនភាពឱ្យបានត្រឹមត្រូវលើឧបករណ៍និងគណនីអនឡាញទាំងអស់ដើម្បីកំណត់អ្នកអាចចូលមើលឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ។
- ពិនិត្យ និងលាក់ព័ត៌មានផ្ទាល់ខ្លួន និងអត្តសញ្ញាណរបស់អ្នកដែលមិនចាំបាច់ត្រូវបង្ហាញ។ ប្រើឈ្មោះហៅក្រៅ ឬអក្សរកាត់ជំនួសឱ្យការដាក់ឈ្មោះពេញ។
- គិតពិចារណាមុនពេលចែករំលែក ឬបង្ហោះរូបភាពណាដែលអ្នកពេញចិត្តជាមួយនរណាម្នាក់ដែលអ្នកស្គាល់ប៉ុណ្ណោះ។
- បិទមុខងារកំណត់ភូមិសាស្ត្រនៅលើឧបករណ៍ ដើម្បីចៀសវាងការបង្ហាញទីតាំង។
- រាយការណ៍អំពីការគំរាមកំហែងតាមអ៊ីនធឺណិតមតិមិនសមរម្យ ឬទំនាក់ទំនងពីជនប្លែកមុខភ្លាមៗទៅកាន់ឪពុកម្ដាយ អាណាព្យាបាល គ្រូបង្រៀន ឬនរណាម្នាក់ដែលអ្នកទុកចិត្ត។
- ត្រូវប្រុងប្រយ័ត្នចំពោះការចែករំលែកលេខសម្ងាត់ ឬព័ត៌មានរសើប សូម្បីតែជាមួយមិត្តភក្តិ។
- ត្រូវចងចាំថា នៅពេលអ្នកបង្ហោះអ្វីមួយលើប្រព័ន្ធអនឡាញ អ្នកពិបាកក្នុងការដកចេញវិញ ឬគ្រប់គ្រងវា។

វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវពិនិត្យមើលគោលការណ៍ឯកជនភាពទាំងនេះឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់អាស្រ័យលើកម្មវិធី ឬវេទិកាដែលអ្នកកំពុងប្រើប្រាស់។ ការសន្ទនាដោយបើកចំហនិងប្រកាន់ខ្ជាប់នូវទម្លាប់ប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព គឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការរក្សាភាពជាពលរដ្ឋឌីជីថលប្រកបដោយការទទួលខុសត្រូវ។

## ៥.៣ មាតិកា និងប្រវត្តិរូបក្លែងក្លាយ

នៅលើអ៊ីនធឺណិត មាតិកាជាច្រើនមិនត្រូវបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ មុននឹងបង្ហោះផ្សព្វផ្សាយ ហើយមាតិកាមួយចំនួនត្រូវបានគេប្រឌិតឡើង ដើម្បីបន្លំ បំភាន់ការពិត ឬបោកបញ្ឆោត។ ដូចគ្នានេះដែរ ប្រវត្តិរូប (Profile)មួយចំនួននៅលើអនឡាញ ត្រូវបានគេក្លែងបន្លំ ក្នុងគោលបំណងទុច្ចរិត ដូច្នេះហើយអ្នកគួរមានសមត្ថភាពក្នុងការកំណត់ថាមាតិកាព័ត៌មាន ឬប្រវត្តិរូបណាដែលមិនពិតឬក្លែងក្លាយ។ ការប្រុងប្រយ័ត្ន និងយល់ដឹងអំពីគណនីក្លែងក្លាយអាចជួយការពារអ្នកពីហានិភ័យដែលបង្កឡើងដោយគណនីក្លែងក្លាយ ដូច្នេះសមត្ថភាពនេះ គឺជាបំណិនដ៏សំខាន់មួយសម្រាប់អ្នកក្នុងការប្រើបច្ចេកវិទ្យាឌីជីថល។ ខាងក្រោមគឺជា វិធីសាស្ត្រមួយចំនួន ដើម្បីសម្គាល់ដឹងថា គណនីណាមួយអាចមិនពិត ឬក្លែងក្លាយ៖

- ចូរពិនិត្យអាយុរបស់គណនី៖ គណនីដែលទើបបង្កើតថ្មី ឬគណនីដែលបង្ហោះតិចតួចបំផុត គួរត្រូវសង្ស័យ។
- ពិនិត្យរូបថតប្រវត្តិរូប (Profile Picture)៖ រូបភាពពីអ៊ីនធឺណិត រូបថ្លុក ឬរូបភាពដែលមើលទៅល្អឥតខ្ចោះពេកទំនងជាក្លែងក្លាយ រកមើលភាពមិនស៊ីគ្នានៃពន្លឺ ផ្ទៃខាងក្រោយ ឬគុណភាពរូបភាព។
- ពិនិត្យមើលព័ត៌មានបង្ហោះចែករំលែក ៖ កំហុសវេយ្យាករណ៍ ភាពមិនច្បាស់លាស់ និងទូទៅពេកការពិពណ៌នាវិជ្ជមានហួសហេតុ អាចបង្ហាញពីលក្ខណៈក្លែងក្លាយ។
- វិភាគពីទំនាក់ទំនង៖ តើចំនួនមិត្តភក្តិ និងអ្នកតាមមើល (Followers) សមហេតុផលទេ? តិចពេក ឬច្រើនពេកមិនធម្មតា។
- ពិនិត្យមើលការបង្ហោះដដែលៗ៖ អ្នកប្រើប្រាស់ពិតប្រាកដមានទំនោរបង្ហោះមាតិកាប្លែកៗ ការបង្ហោះរូបថតដែលបានចម្លង ឬកែច្នៃឡើងវិញច្រើនដង អាចចង្អុលជាតម្រុយនៃគណនីក្លែងក្លាយ។
- យកចិត្តទុកដាក់លើការប្រាស្រ័យទាក់ទង៖ តើបុគ្គលនោះចៀសវាងឆ្លើយសំណួរដោយផ្ទាល់ ឬផ្តល់ការឆ្លើយតបមិនច្បាស់លាស់ទេ? អ្នកក្លែងបន្លំច្រើនតែគេចវេសពីការសន្ទនា។

## ៥.៤ ការដាក់លេខសម្ងាត់

ការដាក់លេខសម្ងាត់នៅលើឧបករណ៍ និងគណនីប្រើប្រាស់កម្មវិធីអនឡាញអាចជួយបង្កើនសុវត្ថិភាពអនឡាញរបស់អ្នកបាន។



ក) លេខសម្ងាត់ខ្លាំង៖ ជាលេខសម្ងាត់ដែលធ្វើឱ្យគេលំបាកទាយ និងលួចចូលប្រើប្រាស់ឧបករណ៍ ឬគណនីអនឡាញរបស់អ្នកបាន។ ជាទូទៅលេខសម្ងាត់ដែលខ្លាំងបង្កើតឡើងដោយការលាយបញ្ចូលគ្នារវាងតួអក្សរ លេខ និងនិមិត្តសញ្ញា។ ឧទាហរណ៍៖ Iw2S_b$f$3

ខ) លេខសម្ងាត់មធ្យម៖ ជាលេខសម្ងាត់ដែលមិនងាយស្រួលទាយដោយកម្មវិធីមេរោគ ឬកម្មវិធីលួចចូលប្រើប្រាស់ ក៏ប៉ុន្តែអាចនឹងទាយបានដោយនរណាម្នាក់ដែលស្គាល់អ្នក។ ឧទាហរណ៍៖ Do4rok11

គ) លេខសម្ងាត់ខ្សោយ៖ ជាលេខសម្ងាត់ដែលបង្កើតឡើងដោយការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន ដូចជា ថ្ងៃខែឆ្នាំកំណើត ឈ្មោះសត្វចិញ្ចឹម លេខរៀង លេខទូរសព្ទ ជាដើម។ លេខសម្ងាត់ប្រភេទនេះអាចងាយគេបំបែកបាន ឬទាយដឹងដោយនរណាម្នាក់ដែលស្គាល់អ្នក។

ឧទាហរណ៍៖ 12345678 ឬ sokhom83

គន្លឹះមួយចំនួនខាងក្រោមអាចជួយអ្នកបង្កើតលេខសម្ងាត់ដ៏រឹងមាំបាន៖

- បង្កើតលេខសម្ងាត់ដែលមានយ៉ាងតិច ៨ខ្ទង់ រួមមានអក្សរ (បើជាអក្សរឡាតាំង គួរមានអក្សរតូច និងធំ) លេខ និងនិមិត្តសញ្ញាបញ្ចូលគ្នា។ លេខសម្ងាត់កាន់តែវែង កាន់តែប្រសើរ។
- បង្កើតលេខសម្ងាត់ដោយវិធីដែលងាយចងចាំសម្រាប់អ្នក ដូច្នេះអ្នកមិនចាំបាច់កត់វាទុកកន្លែងណាមួយ។
- ផ្លាស់ប្តូរលេខសម្ងាត់ឱ្យបានញឹកញាប់ឬរៀងរាល់៩០ថ្ងៃឬនៅពេលដែលសង្ស័យថាមានគេលួចយក ឬដឹងលេខសម្ងាត់របស់អ្នក។

អ្នកមិនគួរបង្កើត និងប្រើប្រាស់លេខសម្ងាត់ដោយវិធីដូចខាងក្រោម៖

- ប្រើលេខសម្ងាត់ជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខរៀង លេខទូរសព្ទ អាសយដ្ឋាន ពាក្យសាមញ្ញ ឬទម្រង់ដែលគេអាចទាយបានយ៉ាងងាយ។
- ប្រើលេខសម្ងាត់តែមួយសម្រាប់គណនីច្រើនពីព្រោះនៅពេលដែលគណនីមួយត្រូវបានគេលួចចូលប្រើ វាអាចប៉ះពាល់ដល់គណនីផ្សេងទៀត។
- ចែករំលែកលេខសម្ងាត់ជាមួយអ្នកដទៃ ក្រៅពីឪពុកម្តាយរបស់អ្នក។
- កត់លេខសម្ងាត់ទុកកន្លែងណាមួយដែលនរណាម្នាក់អាចរកឃើញ។

ប្រសិនបើអ្នកមានអារម្មណ៍មិនទុកចិត្តលើគណនីណាមួយ អ្នកគួរជឿជាក់លើអារម្មណ៍របស់ខ្លួន ហើយគួរធ្វើការផ្លាស់ប្តូរលេខសម្ងាត់ភ្លាម។

## ៦. សំណួរឆ្លុះបញ្ចាំង និងសកម្មភាពប្រតិបត្តិ

### សំណួរឆ្លុះបញ្ចាំង

១) តើបណ្តាញទំនាក់ទំនងសង្គម ផ្តល់នូវគុណសម្បត្តិយ៉ាងដូចម្តេចខ្លះ?

២) ចូររៀបរាប់អំពីគុណវិបត្តិបណ្តាលមកពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)។

៣) ចូររៀបរាប់ពីគន្លឹះសំខាន់ៗ ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនៅលើអនឡាញ។

## សកម្មភាពប្រតិបត្តិ៖

រៀបចំសកម្មភាពយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារក្នុងបរិស្ថានឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយភាពឆ្លាតវៃ សេចក្តីគោរព ការទទួលខុសត្រូវ និងសុវត្ថិភាព។ គ្រូបែងចែកសិស្សជាក្រុមៗ ដោយផ្តល់ឱ្យក្រុមនីមួយៗនូវកិច្ចការជាក់លាក់ ដើម្បីរៀបចំយុទ្ធនាការដោយផ្តោតលើចំណុចសំខាន់ដូចខាងក្រោម៖

១. តើយុទ្ធនាការរបស់អ្នកនឹងផ្តោតលើខ្លឹមសារអ្វី?

២. តើមានសារអ្វីខ្លះ ដែលអ្នកនឹងផ្សព្វផ្សាយ?

៣. តើអ្នកនឹងកំណត់ក្រុមគោលដៅប្រភេទណា នៅកន្លែងណា?

៤. តើអ្នកនឹងផ្សព្វផ្សាយសារទាំងនោះដោយរបៀបណា?

៥. តើអ្នកគួរប្រើវេទិកាអ្វីខ្លះសម្រាប់យុទ្ធនាការនេះ? (បណ្តាញទំនាក់ទំនងសង្គម ការជួបជុំនៅសហគមន៍ ជាដើម)

# មេរៀនទី ៣ ឥទ្ធិពលអវិជ្ជមាននៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

**រយៈពេល៖ ០២ ម៉ោងសិក្សា**

## បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សអាច៖

- រៀបរាប់បានពីគុណវិបត្តិនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
- អនុវត្តវិធានបង្ការខ្លួនពីផលប៉ះពាល់នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការរស់នៅប្រចាំថ្ងៃ ផ្លូវកាយ និងផ្លូវចិត្ត
- ផ្លាស់ប្តូរទម្លាប់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាព និងការប្រុងប្រយ័ត្ន។



ការរស់នៅបែបស្ងប់ស្ងាត់



ការសិក្សាធ្លាក់ចុះ



ការរំខាន និងការថយចុះនៃផលិតភាព



អន្តរទំនាក់ទំនងសង្គមចុះខ្សោយ

បច្ចេកវិទ្យាត្រូវបានបង្កើតឡើង ដើម្បីបំពេញតម្រូវការរបស់មនុស្សជាតិនាយុគសម័យឌីជីថល និង ឧស្សាហូបនីយកម្ម។ ការប្រើប្រាស់បច្ចេកវិទ្យាមានសារៈសំខាន់ក្នុងការកែលម្អដំណើរការ សេដ្ឋកិច្ច សង្គមវប្បធម៌ ការអប់រំ និងការស្រាវជ្រាវ។ វាបានជួយសម្រួលដល់ការរក្សាសន្តិសុខ កិច្ចសហការ ការពង្រឹងអំណាចទំនាក់ទំនង សុខភាព សុវត្ថិភាព ការច្នៃប្រតិដ្ឋ និងការការពារបរិស្ថាន។ ទន្ទឹមនឹង គុណសម្បត្តិយ៉ាងច្រើននេះការប្រើប្រាស់បច្ចេកវិទ្យា ក៏មានគុណវិបត្តិ និងអាចបង្កផលវិបាកជាច្រើន។ មេរៀននេះនឹងផ្តោតលើការស្វែងយល់ពីផលប៉ះពាល់អវិជ្ជមានមួយចំនួននៃការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថល និងលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ។

## ១. គុណវិបត្តិរបស់បច្ចេកវិទ្យាឌីជីថល

ក្នុងយុគសម័យឌីជីថលសព្វថ្ងៃនេះ កុមារកំពុងធំលូតលាស់ឡើងក្នុងពិភពបច្ចេកវិទ្យាដ៏សម្បូរបែប។ ខណៈពេលដែលបច្ចេកវិទ្យាទាំងនេះផ្តល់អត្ថប្រយោជន៍ជាច្រើន យើងទទួលស្គាល់ថា វាអាចបង្កផល ប៉ះពាល់អវិជ្ជមានលើសុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ។

គុណវិបត្តិនៃការប្រើប្រាស់បច្ចេកវិទ្យាភាគច្រើនអាចបណ្តាលមកពីការប្រើប្រាស់ច្រើនលើសលប់មិន បានត្រឹមត្រូវ ឬដោយខ្វះការយល់ដឹង ការប្រុងប្រយ័ត្ន និងការគិតគូពីគុណតម្លៃរបស់វា។ គុណវិបត្តិទាំង នោះអាចរួមមានដូចជា៖

- **ការរំខានដល់អ្នកប្រើប្រាស់៖** ការប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាច្រើនលើសលប់ពេក អាចរំខាន ដល់ការផ្តោតអារម្មណ៍ ទំនាក់ទំនងអន្តរបុគ្គល ឬសកម្មភាពប្រចាំថ្ងៃផ្សេងទៀត។
- **ហានិភ័យពាក់ព័ន្ធការលួចអត្តសញ្ញាណ និងការបោកប្រាស់តាមប្រព័ន្ធអនឡាញ៖** បច្ចេកវិទ្យា បានធ្វើឱ្យការចែករំលែក និងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនកាន់តែងាយស្រួល។ ដូច្នេះហើយ ការប្រើប្រាស់អ៊ីនធឺណិត ឬកម្មវិធីអនឡាញ តែងតែប្រឈមនឹងហានិភ័យ ដែលអាចបង្ក គ្រោះថ្នាក់ដល់អ្នកប្រើប្រាស់តាមរយៈ ការក្លែងបន្លំ ការបោកបញ្ឆោត ការចម្លងមេរោគកុំព្យូទ័រ ការផ្សាយពាណិជ្ជកម្មបោកប្រាស់ការស្នើសុំទិន្នន័យផ្ទាល់ខ្លួន ការលួចចូលប្រើប្រាស់ ជាដើម។ ហានិភ័យទាំងនេះអាចធ្វើឱ្យទិន្នន័យផ្ទាល់ខ្លួន ឬព័ត៌មានអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ត្រូវ បានគេលួចប្រើប្រាស់ដោយខុសច្បាប់ឬចែករំលែកដោយគ្មានការអនុញ្ញាតដែលអាចប៉ះពាល់ ដល់បញ្ហាសុវត្ថិភាពនិងសន្តិសុខផ្ទាល់ខ្លួន។
- **ហានិភ័យពាក់ព័ន្ធសុវត្ថិភាពលើអ៊ីនធឺណិត៖** កុមារអាចប្រឈមចំពោះហានិភ័យផ្សេងៗលើ អ៊ីនធឺណិត ដូចជាការគំរាមកំហែងតាមអ៊ីនធឺណិត មាតិកាមិនសមរម្យ ជនរំលោភបំពានតាម អ៊ីនធឺណិត និងការបង្កើតទំនាក់ទំនងជាមួយមនុស្សមិនធ្លាប់ស្គាល់។ ជាមួយនឹងភាពអនាមិក ដែលផ្តល់ដោយអ៊ីនធឺណិតបុគ្គលមួយចំនួនអាចមានអាកប្បកិរិយាបង្កការឈឺចាប់ ឬបៀតបៀន ដែលនាំឱ្យប៉ះពាល់ផ្លូវចិត្តដល់អ្នកផ្សេងទៀត។

## ២. ផលប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃ



- **ការរស់នៅបែបស្ងប់ស្ងាត់៖** បច្ចេកវិទ្យាដូចជាទូរសព្ទឆ្លាតវៃ និងកុំព្យូទ័រ ជារឿយៗជំរុញឱ្យអ្នកប្រើប្រាស់មានរបៀបរស់នៅស្ងប់ស្ងាត់ ពីព្រោះពួកគេទំនងជាចំណាយពេលចូលរួមក្នុងសកម្មភាពអនឡាញដូចជាជជែកកម្សាន្តលើអនឡាញតាមដានប្រព័ន្ធផ្សព្វផ្សាយសង្គម ឬលេងវីដេអូហ្គេមដែលនាំឱ្យមានការធ្វើលំហាត់ប្រាណតិចនិងបង្កើនហានិភ័យផ្នែកសុខភាព។



- **ការរំខាន និងការថយចុះនៃផលិតភាព៖** ការប្រើប្រាស់បច្ចេកវិទ្យាជាប្រចាំអាចជាប្រភពនៃការរំខានពីព្រោះការជូនដំណឹង (Notification) របស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីកម្សាន្តតាមអនឡាញអាចបង្វែរការយកចិត្តទុកដាក់របស់យើង ដែលនាំឱ្យថយចុះនូវការផ្តោតលើកិច្ចការការសិក្សាឬផលិតភាពជាទូទៅប្រចាំថ្ងៃ។



- **អន្តរទំនាក់ទំនងសង្គមចុះខ្សោយ៖** ខណៈពេលដែលបច្ចេកវិទ្យាផ្តល់មធ្យោបាយងាយស្រួលក្នុងការទំនាក់ទំនង ការពឹងផ្អែកខ្លាំងពេកលើវេទិកាឌីជីថលអាចរំខានដល់អន្តរទំនាក់ទំនងដោយផ្ទាល់ ឬទល់មុខគ្នា។ អ្នកប្រើប្រាស់អាចកាន់តែជក់ចិត្តលើវត្តមានរបស់ពួកគេនៅលើអ៊ីនធឺណិត ដែលនាំឱ្យមានការកាត់បន្ថយការភ្ជាប់ទំនាក់ទំនងផ្ទាល់ខ្លួន។



- **ការសិក្សាធ្លាក់ចុះ៖** ការប្រើប្រាស់បច្ចេកវិទ្យាច្រើនលើសលប់ពេកអាចនាំឱ្យភ្លេចគិតដល់ការសិក្សា ការអានសៀវភៅ និងការពន្យល់ណែនាំពីគ្រូ ជាហេតុនាំឱ្យការសិក្សាមានការថយចុះ។ ការពឹងផ្អែកលើឧបករណ៍បច្ចេកវិទ្យាច្រើនពេកអាចនាំឱ្យមានទម្លាប់សិក្សាមិនល្អ និងបង្កើតអាកប្បកិរិយាខ្ជិលគិត។

## ៣. ផលប៉ះពាល់លើសុខភាពផ្លូវកាយ និងផ្លូវចិត្ត

ការចំណាយពេលវេលាច្រើនហួសហេតុនៅមុខអេក្រង់ទូរសព្ទ កុំព្យូទ័រ កុំព្យូទ័របន្ទះ (Tablet) និងទូរទស្សន៍ អាចមានបញ្ហាដល់សុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដូចជា៖

- **កាត់បន្ថយសកម្មភាពរាងកាយ៖** ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាច្រើនពេកអាចបង្កគ្រោះថ្នាក់ដល់សុខភាពផ្លូវកាយរបស់អ្នកប្រើប្រាស់។ មានន័យថា នៅពេលយើងកាន់តែប្រើការធ្វើសកម្មភាពរាងកាយកាន់តែតិច។ បញ្ហាមួយទៀត គឺការលេងហ្គេម ដែលធ្វើឱ្យយើងទទួលយកអាហារសម្រន់ជំនួសឱ្យអាហារត្រឹមត្រូវ។ លើសពីនេះនៅពេលដែលយើងចំណាយពេលច្រើននៅពីមុខអេក្រង់ យើងនឹងមានពេលតិចជាងមុន ឬលែងចង់ទៅលេងនៅខាងក្រៅដូចជាការលេងកីឡា ឬការហាត់ប្រាណ ជាដើម។ យូរៗទៅទម្លាប់ទាំងនោះអាចនាំឱ្យឡើងទម្ងន់ខុសប្រក្រតី និងបង្កជាជំងឺផ្សេងៗជាច្រើន។
- **ភ្នែក៖** ការសម្លឹងមើលអេក្រង់ក្នុងរយៈពេលយូរអាចបណ្ដាលឱ្យមានភាពតានតឹងក្នុងភ្នែក ការមើលឃើញមិនច្បាស់ និងឈឺក្បាល។
- **ការរំខានដល់ដំណេក៖** ការប៉ះពាល់យូរទៅនឹងពន្លឺពណ៌ខៀវ ដែលបញ្ចេញដោយអេក្រង់ក៏អាចរំខានដល់ដំណេកផងដែរ។ ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកមុនពេលចូលគេងអាចរំខានដល់ ដំណេក ដោយសារការទប់ស្កាត់ការផលិតមេឡាតូនីន។ គុណភាពនៃការគេងមិនល្អអាចនាំឱ្យមានបញ្ហាសុខភាពផ្សេងៗ រួមទាំងការអស់កម្លាំង ការថយចុះមុខងារខួរក្បាល និងហានិភ័យនៃជំងឺរ៉ាំរ៉ៃ។
- **ផ្លូវចិត្ត៖** ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលច្រើនពេក ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម អាចជាចំណែកមួយប៉ះពាល់ដល់សុខភាពផ្លូវចិត្តដូចជា ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ និងការឱ្យតម្លៃខ្លួនឯងទាប។
- **ការចុះខ្សោយនៃខួរក្បាល៖** ការពឹងផ្អែកខ្លាំងលើឧបករណ៍ឌីជីថលសម្រាប់កិច្ចការដូចជាការរំលឹកការចងចាំ ការដោះស្រាយបញ្ហា និងការគិតប្រកបដោយការត្រិះរិះ អាចកាត់បន្ថយសមត្ថភាពនៃការយល់ដឹងរបស់ខួរក្បាល ដូចជាការច្នៃប្រតិដ្ឋ និងការរក្សាការចងចាំ ជាដើម។

## ៤. ផលប៉ះពាល់លើទំនាក់ទំនង

ការប្រើប្រាស់អ៊ីនធឺណិតមិនមែនជារឿងអាក្រក់នោះទេ ប៉ុន្តែការចំណាយពេលច្រើនលើអ៊ីនធឺណិតអាចបង្កផលប៉ះពាល់ដល់អន្តរទំនាក់ទំនងសង្គម និងបញ្ហាទំនាក់ទំនងផ្សេងទៀតដូចខាងក្រោម៖

- **ការកាត់បន្ថយពេលវេលាផ្ទាល់ខ្លួន៖** ការប្រើប្រាស់អ៊ីនធឺណិតច្រើនពេក អាចប៉ះពាល់ដល់ជីវិតផ្ទាល់ខ្លួន និងពេលវេលាជាមួយគ្រួសារ ដោយសារតែការផ្ដោតលើឧបករណ៍អេឡិចត្រូនិកលើសលប់ពេក។

- **ភាពឯកោក្នុងសង្គម៖** ការចំណាយពេលវេលាច្រើនពេកលើឧបករណ៍ឌីជីថលអាចនាំទៅរកភាពឯកោក្នុងសង្គម និងកាត់បន្ថយអន្តរទំនាក់ទំនងសង្គមដោយផ្ទាល់ជាមួយមនុស្សនៅជុំវិញខ្លួន ដែលមានសារៈសំខាន់សម្រាប់សុខុមាលភាពផ្លូវចិត្ត និងរក្សាទំនាក់ទំនងល្អ។
- **ការញៀន និងពឹងផ្អែកលើបច្ចេកវិទ្យា៖** ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលច្រើនពេកអាចនាំឱ្យមានការញៀន ដូចជាជំងឺញៀនអ៊ីនធឺណិត ឬការញៀនហ្គេម ជាដើម។ នេះអាចបណ្ដាលឱ្យមានការធ្វេសប្រហែសការទទួលខុសត្រូវ ការថយចុះផលិតភាព និងរោគសញ្ញានៃការតានតឹង (Stress) នៅពេលមិនបានប្រើ។

## ៥. សំណួរឆ្លុះបញ្ចាំង និងសកម្មភាពប្រតិបត្តិ

### សំណួរឆ្លុះបញ្ចាំង

១- តើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងមួយថ្ងៃ ០៨ ម៉ោង មានផលប៉ះពាល់អ្វីខ្លះ?

២- ហេតុអ្វីបានជាការប្រើប្រាស់ទូរសព្ទច្រើន អាចបង្កឱ្យមានអំពើហិង្សា?

៣- ហេតុអ្វីបានជាការប្រើប្រាស់ទូរសព្ទច្រើនអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត?

### សកម្មភាពប្រតិបត្តិ

ចូរប្អូនសរសេររបាយការណ៍ ពីការប្រើប្រាស់ទូរសព្ទប្រចាំថ្ងៃរបស់ប្អូន រួចឆ្លុះបញ្ចាំងពីឥទ្ធិពលអវិជ្ជមាន ទៅលើការសិក្សា និងសុខភាព របស់ប្អូន។

**សម្គាល់៖** - ចំនួនម៉ោងសរុប លើការប្រើប្រាស់ទូរសព្ទ ក្នុងមួយថ្ងៃ ព្រឹក? ថ្ងៃត្រង់? យប់?...

- មើលមាតិកាអ្វីខ្លះ? តើមានប្រយោជន៍ដល់ការសិក្សា និងការរស់នៅដែរឬទេ?

មេរៀនទី ៣

# អាកប្បកិរិយា ហានិភ័យ និងគ្រោះថ្នាក់នៃការកេងប្រវ័ញ្ច ផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ

**រយៈពេល៖ ០៥ ម៉ោងសិក្សា**

## បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សអាច៖

- រៀបរាប់បានពីប្រភេទហានិភ័យ និងទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញបានត្រឹមត្រូវ។
- កំណត់បានពីសកម្មភាពដែលនាំឱ្យមានហានិភ័យ និងកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត។
- មានស្មារតីប្រុងប្រយ័ត្ន និងដោះស្រាយបញ្ហាដែលកើតឡើងចំពោះខ្លួនទាន់ពេលវេលាប្រកបដោយការទទួលខុសត្រូវ។



ខណៈដែលបច្ចេកវិទ្យាកាន់តែរីកចម្រើន សុវត្ថិភាពលើប្រព័ន្ធអនឡាញគឺជាកត្តាកង្វល់ដ៏សំខាន់របស់អ្នកប្រើប្រាស់ និងអ្នកធ្វើការពាក់ព័ន្ធ។ គ្រោះថ្នាក់ដែលអាចកើតមាននៅលើអ៊ីនធឺណិត បណ្ដាលមកពីកត្តាជាច្រើន រួមទាំងអាកប្បកិរិយារបស់អ្នកប្រើប្រាស់ផងដែរ។ នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីអាកប្បកិរិយាលើប្រព័ន្ធអនឡាញ ហានិភ័យ និងគ្រោះថ្នាក់ក្នុងទម្រង់នីមួយៗ ព្រមទាំងវិធីសាស្ត្រការពារខ្លួនពីហានិភ័យ និងគ្រោះថ្នាក់នានា។

## ១.ពាក្យគន្លឹះ

ហានិភ័យ៖ សំដៅលើការខូចខាត ឬការបាត់បង់ ដែលអាចកើតឡើងពីសកម្មភាពព្រឹត្តិការណ៍ឬស្ថានភាពជាក់លាក់ណាមួយ។ វាជាផ្នែកមួយនៅក្នុងជីវិតប្រចាំថ្ងៃ ហើយអាចកើតឡើងក្នុងបញ្ហាហិរញ្ញវត្ថុ សុខភាព សុវត្ថិភាព ជាដើម។

ការកេងប្រវ័ញ្ចផ្លូវភេទ៖ សំដៅលើទង្វើនៃការទាញយកប្រយោជន៍ពីនរណាម្នាក់ ឬអ្វីមួយសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ដែលជារឿយៗប៉ះពាល់ដល់សុខុមាលភាព សិទ្ធិ ឬសេចក្ដីថ្លៃថ្នូររបស់អ្នកដទៃ។ ការកេងប្រវ័ញ្ចអាចកើតមានឡើងក្នុងបរិបទផ្សេងៗ។

ការរំលោភបំពាន៖ សំដៅទៅលើការធ្វើបាបឬអាកប្បកិរិយាបង្កគ្រោះថ្នាក់ដែលសំដៅទៅលើអ្នកដទៃ ហើយបណ្ដាលឱ្យមានផលប៉ះពាល់ដល់រាងកាយ អារម្មណ៍ ផ្លូវចិត្ត ឬផ្លូវភេទ។ ការរំលោភបំពានអាចកើតឡើងក្នុងទម្រង់ និងបរិបទផ្សេងៗ រួមទាំង ការរំលោភបំពានលើរូបរាងកាយ ការរំលោភបំពានផ្លូវអារម្មណ៍ ឬផ្លូវចិត្ត និងការរំលោភបំពានផ្លូវភេទ។

ជនល្មើស៖ គឺជាបុគ្គលដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋ ឬអំពើបំពានច្បាប់។ ពួកគេគឺជាមនុស្សដែលបានចូលរួមក្នុងសកម្មភាពដែលបានចាត់ទុកថាប្រឆាំងនឹងបទដ្ឋានសង្គម។

ជនរងគ្រោះ៖ គឺជាបុគ្គលដែលបានជួបប្រទះនូវគ្រោះថ្នាក់ របួស ការបាត់បង់ ឬការរំលោភបំពានដែលជាលទ្ធផលនៃសកម្មភាព អាកប្បកិរិយា ឬអំពើខុសឆ្គងរបស់អ្នកដទៃ។

## ២. អាកប្បកិរិយារបស់កុមារលើអនឡាញ

អាកប្បកិរិយារបស់កុមារនៅលើអ៊ីនធឺណិតមានភាពខុសៗគ្នា និងប្រែប្រួលពីពេលមួយទៅពេលមួយ ប៉ុន្តែវាជាការសំខាន់ណាស់ដែលត្រូវយល់ពីហានិភ័យដែលពួកគេអាចជួបប្រទះនៅក្នុងពិភពឌីជីថល។ ខាងក្រោមនេះជាអាកប្បកិរិយាទូទៅមួយចំនួន និងហានិភ័យដែលពាក់ព័ន្ធ៖

- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ កុមារជាច្រើនចូលរួមក្នុងវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ ចែករំលែកមាតិកា និងស្វែងរកចំណាប់អារម្មណ៍។ ហានិភ័យដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមរួមមាន ការគំរាមកំហែងតាមអ៊ីនធឺណិត ការរុកកួនឆាផៅតាមអនឡាញ ការប៉ះពាល់ដោយមាតិកាមិនសមរម្យ និងការព្រួយបារម្ភអំពីឯកជនភាពដែលអាចកើតមាន។

- **ការលេងហ្គេមអនឡាញ៖** កុមារជារឿយៗចូលរួមក្នុងសហគមន៍ហ្គេមអនឡាញ ដែលពួកគេធ្វើអន្តរទំនាក់ទំនងជាមួយអ្នកលេងផ្សេងទៀតចូលរួមក្រុម និងប្រកួតប្រជែងក្នុងហ្គេមដែលមានអ្នកលេងច្រើន។ ហានិភ័យដែលអាចកើតមានឡើងរួមមានការប៉ះពាល់ដោយភាសា ឬពាក្យសំដីវាយប្រហារ និងការលេងហ្គេមហួសហេតុដែលនាំទៅដល់ការភ្លេចកិច្ចការផ្សេងៗទៀត។

- **ការចែករំលែកព័ត៌មានផ្ទាល់ខ្លួន៖** កុមារអាចចូលចិត្តចែករំលែកព័ត៌មានផ្ទាល់ខ្លួនលើអ៊ីនធឺណិត ដូចជាឈ្មោះ អាសយដ្ឋាន គ្រួសារ សាលារៀន ឬលេខទូរសព្ទរបស់ពួកគេ។ ការចែករំលែកនេះអាចធ្វើឱ្យពួកគេងាយរងគ្រោះដោយសារការលួចអត្តសញ្ញាណ ការតាមដាន ឬការផ្សាយពាណិជ្ជកម្មមិនសមរម្យ។

- **ការចែករំលែកមាតិកាមិនសមរម្យ៖** កុមារអាចត្រូវបានគេលួងលោម ឬបង្ខំឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ ដូចជាការផ្ញើ ឬទទួលសារជារូបថត ឬវីដេអូអាក្រាត។ អាកប្បកិរិយាទាំងនេះអាចនាំឱ្យមានបញ្ហាផ្លូវចិត្ត ការគំរាមតាមអ៊ីនធឺណិតឬផលវិបាកផ្នែកច្បាប់ដែលអាចកើតមានប្រសិនបើចែករំលែកដោយគ្មានការយល់ព្រម ឬខុសច្បាប់។

- **អ្នកប្រមាញ់តាមអ៊ីនធឺណិត៖** កុមារអាចត្រូវបានកំណត់ជាគោលដៅនៃការកេងប្រវ័ញ្ចដោយនរណាម្នាក់។ ជនរំលោភបំពានតាមអ៊ីនធឺណិតអាចប្រើឧបាយកល បោកបញ្ឆោត ឬបច្ចេកទេសលួងលោម ដើម្បីបង្កើតការជឿទុកចិត្ត និងកេងប្រវ័ញ្ចលើកុមារដែលងាយរងគ្រោះ។

- **ការប្រាស្រ័យទាក់ទង និងការអប់រំ៖** និយាយជាមួយកូនរបស់អ្នកអំពីសុវត្ថិភាពអនឡាញ ការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយការទទួលខុសត្រូវ និងហានិភ័យដែលអាចកើតមានដែលពួកគេអាចជួបប្រទះ។ លើកទឹកចិត្តឱ្យមានការសន្ទនាបើកចំហ ហើយត្រូវប្រាកដថាពួកគេមានអារម្មណ៍ស្រួលក្នុងការពិភាក្សាអំពីកង្វល់ ឬឧប្បត្តិហេតុណាមួយ។

តាមរយៈការលើកកម្ពស់ចំណេះដឹងការជំរុញបរិយាកាសឌីជីថលប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ ឪពុកម្តាយ អាណាព្យាបាល អាចចូលរួមកាត់បន្ថយហានិភ័យ ដែលទាក់ទង នឹងអាកប្បកិរិយារបស់កុមារនៅលើអ៊ីនធឺណិតបាន។

### សកម្មភាពទី១៖ ករណីសិក្សា

ចូរប្អូនអានរឿង និងរកវិធីជួយអប់រំ ណែនាំដល់ណារ័ត្ន

ណារ័ត្នមានអាយុ១៤ឆ្នាំ។ នៅពេលដែលនាងទទួលបានទូរសព្ទថ្មីពីឪពុកម្តាយ នាងចាប់ផ្តើមភ្ជាប់បណ្តាញអ៊ីនធឺណិតហើយបានបង្កើតទំនាក់ទំនងក្នុងបណ្តាញសង្គម (Facebook) និងភ្ជាប់ទៅកម្មវិធី (App) ជាច្រើន។ ពេលដែលនាងប្រើប្រាស់កម្មវិធីកាន់តែច្រើន នាងសំងំនៅតែក្នុងបន្ទប់ ចុចលេងតែទូរសព្ទ។ នាងកើតមានអាកប្បកិរិយាស្ងៀមស្ងាត់ចូលចិត្តនៅម្នាក់ឯងឆាប់ខឹង

ឆេវឆាវ គេងមិនគ្រប់គ្រាន់ មិនយកចិត្តទុកដាក់អ្វីៗដែលនៅជុំវិញខ្លួន ដោយវក់នឹងបច្ចេកវិទ្យា។ នាងមិនបានទៅរៀនជាទៀងទាត់ទេ នាងលែងចង់អានសៀវភៅលោកនាយកសាលារៀនបានផ្ញើដំណឹងពីអវត្តមានរបស់ណារ័ត្ន មកជម្រាបឪពុកម្ដាយណារ័ត្ន។ ឪពុកម្ដាយណារ័ត្ន ក៏ចាប់តាមដានពីការសិក្សារបស់កូន ដូចអ្វីដែលលោកនាយកសាលារៀនបានប្រាប់មែន។ នាងមានកំហឹងខឹងញឹកញាប់ ហើយប្រាប់ឪពុកម្ដាយថាលោកនាយកផ្ញើព័ត៌មានមិនពិតពីនាង នាងដើរឈ្លោះជាមួយអ្នកដទៃ និងមានលេចចេញសញ្ញាណនៃជំងឺធ្លាក់ទឹកចិត្ត។ ដោយមានការតក់ស្លុត ភ័យខ្លាចនិងអស់សង្ឃឹមយ៉ាងខ្លាំងចំពោះខ្លួនឯង ណារ័ត្នលែងគិតអ្វីឃើញបានត្រឹមសម្រេចពួនសំងំលាក់ខ្លួននៅក្នុងបន្ទប់ គេចមិនចង់ជួបមុខក្រុមគ្រួសារ គេចមិនទៅសាលារៀន ដោយភូតភរម្ដាយឪពុកថានាងមានជំងឺ។ ក្នុងនាមជាឪពុកម្ដាយបានលើកទឹកចិត្តឱ្យកូននិយាយពីបញ្ហាដែលបានកើតឡើងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកើតមានចំពោះកូន។

- តើករណីសិក្សានេះ បានឆ្លុះបញ្ចាំងអំពីអ្វីខ្លះ ?
- ប្រសិនបើអ្នក បានជួបប្រទះរឿងដូចណារ័ត្ន តើអ្នកគួរធ្វើដូចម្ដេច ?

## ៣. ហានិភ័យលើប្រព័ន្ធអនឡាញ

ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងអ៊ីនធឺណិត អាចនឹងប្រឈមហានិភ័យមួយចំនួនលើប្រព័ន្ធអនឡាញ រួមមាន មាតិកា ទំនាក់ទំនង ការប្រព្រឹត្ត ពាណិជ្ជកម្ម ឬកិច្ចសន្យា។

### ៣.១ ហានិភ័យនៃមាតិកា

អ្នកប្រើប្រាស់ជាពិសេសកុមារ និងក្មេងវ័យជំទង់អាចមើលឃើញ និងចែករំលែកបន្តនូវមាតិកាដែលពួកគេមិនចង់ឃើញ ឬមានលក្ខណៈមិនសមរម្យ។ មាតិកាទាំងនេះរួមមាន អត្ថបទ រូបភាពវីដេអូ និងគេហទំព័រដែលមានលក្ខណៈហិង្សា ការនិយាយស្អប់ ឬមនោគមវិជ្ជាដែលបង្កគ្រោះថ្នាក់។ កុមារអាចជួបប្រទះមាតិកាបែបនេះដោយចៃដន្យ ឬដោយចេតនា ខណៈពេលកំពុងរុករកតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។




ឧទាហរណ៍៖ កុមារទទួលបានរូបភាព វីដេអូបែបផ្លូវភេទពីមនុស្សម្នាក់តាមរយៈកម្មវិធីផ្ញើសារ។

## ៣.២ ហានិភ័យនៃទំនាក់ទំនង

ហានិភ័យទំនាក់ទំនងសំដៅដល់ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃតាមអ៊ីនធឺណិត ដែលកុមារអាចទាក់ទងជាមួយមនុស្សប្លែកមុខ អ្នកប្រមាញ់តាមអ៊ីនធឺណិត ឬបុគ្គលដែលមានចេតនាព្យាបាទ។ បុគ្គលទាំងនេះអាចប្រើកលល្បិចលួងលោមស្វែងរកព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ គំរាមកំហែង ឬព្យាយាមកេងប្រវ័ញ្ចកុមារ ទាំងហិរញ្ញវត្ថុ និងផ្លូវភេទ។ ពេលខ្លះកុមារ និងក្មេងវ័យជំទង់បានចូលរួមក្នុងការប្រាស្រ័យទាក់ទង ដោយមិនបានដឹងខ្លួនប្រកបដោយគ្រោះថ្នាក់ ជាមួយអ្នកដទៃតាមអនឡាញ ហើយពួកគេអាចត្រូវបានគេបញ្ឆោតឱ្យមានទំនាក់ទំនងបែបផ្លូវភេទ។ វាចាំបាច់ណាស់ក្នុងការអប់រំកុមារអំពីគ្រោះថ្នាក់ដែលអាចកើតមាន លើកទឹកចិត្តពួកគេឱ្យប្រាស្រ័យទាក់ទងជាមួយបុគ្គលដែលស្គាល់ និងគួរឱ្យទុកចិត្តប៉ុណ្ណោះ ហើយបង្រៀនពួកគេឱ្យស្គាល់ និងរាយការណ៍អំពីអាកប្បកិរិយាគួរឱ្យសង្ស័យ ឬគ្រោះថ្នាក់ណាមួយ។ ជារួម ហានិភ័យនៃទំនាក់ទំនងអាចនាំឱ្យកើតមានការការលួងលោម ការជួញដូរកុមារ ការរំលោភបំពាន និងការកេងប្រវ័ញ្ច។




## ៣.៣ ហានិភ័យនៃការប្រព្រឹត្ត

ហានិភ័យនៃការប្រព្រឹត្តសំដៅលើសកម្មភាព និងអាកប្បកិរិយាដែលកុមារចូលរួម ឬប្រព្រឹត្តនៅលើអ៊ីនធឺណិត។ នេះរួមបញ្ចូលទាំងសកម្មភាពគំរាមតាមអ៊ីនធឺណិត រុកកួនឆាឆៅ ផ្សព្វផ្សាយពាក្យចចាមអារ៉ាម ចែករំលែកមាតិកាមិនសមរម្យ ឬចូលរួមក្នុងសកម្មភាពខុសច្បាប់។ ពេលខ្លះ កុមារអាចបង្ហាញអាកប្បកិរិយាអវិជ្ជមានលើអ៊ីនធឺណិត ដោយសារតែកង្វះការយល់ដឹងអំពីផលវិបាកនៃសកម្មភាពរបស់ពួកគេ។ វាមានសារៈសំខាន់ណាស់ក្នុងការបង្រៀនកុមារអំពីភាពជាពលរដ្ឋឌីជីថលដែលមានការទទួលខុសត្រូវ ការយល់ចិត្ត ការគោរព និងសារៈសំខាន់នៃការប្រព្រឹត្តចំពោះអ្នកដទៃតាមអ៊ីនធឺណិត។

ឧទាហរណ៍៖ កុមារថតរូបអាក្រាតកាយរបស់ខ្លួនឯង និងផ្ញើទៅឱ្យនរណាម្នាក់ផ្សេងទៀត ក្រោមការលួងលោម ឬការគំរាមកំហែង។ បន្ទាប់មករូបភាពរបស់ពួកគេត្រូវបានអ្នកដទៃបន្តផ្ញើទៅអ្នកផ្សេងទៀត ដោយគ្មានការយល់ព្រម។





## ៣.៤ ហានិភ័យនៃកិច្ចសន្យា

ហានិភ័យនៃកិច្ចសន្យាពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង និងកិច្ចសន្យាដែលកុមារអាចយល់ព្រម ខណៈពេលដែលកំពុងប្រើប្រាស់ប្រព័ន្ធអនឡាញ កម្មវិធី ឬគេហទំព័រ។ នេះរួមបញ្ចូលទាំងការទទួលយកលក្ខខណ្ឌនៃសេវាកម្ម គោលការណ៍ឯកជនភាព ឬការចែករំលែកព័ត៌មានផ្ទាល់ខ្លួនជាមួយភាគីទីបី។ កុមារប្រហែលជាមិនយល់ច្បាស់ពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងទាំងនេះ ឬហានិភ័យដែលអាចកើតមានទាក់ទងនឹងការចែករំលែកទិន្នន័យផ្ទាល់ខ្លួននោះទេ។ មាតាបិតា និងអាណាព្យាបាលគួរណែនាំកុមារអំពីការអាន និងការយល់ដឹងអំពីលក្ខខណ្ឌនៃសេវាកម្ម និងគោលការណ៍ឯកជនភាព ហើយជួយពួកគេធ្វើការសម្រេចចិត្ត ដើម្បីធានាភាពឯកជន និងសុវត្ថិភាពរបស់ពួកគេ។



នៅពេលកុមារ និងក្មេងវ័យជំទង់ទាញយកកម្មវិធីថ្មីៗមកប្រើប្រាស់ ដែលតម្រូវឱ្យពួកគាត់ចុចយល់ព្រមលើលក្ខខណ្ឌនៃការប្រើប្រាស់ ពេលខ្លះពួកគេមិនបានយល់ ឬអានមុនពេលសម្រេចចិត្តនោះទេ។ ការកំណត់បែបនេះអាចធ្វើឱ្យកុមារទទួលរងការកេងប្រវ័ញ្ចតាមរយៈការប្រើប្រាស់ទិន្នន័យព័ត៌មានផ្ទាល់ខ្លួន និងបង្កជាហានិភ័យដល់ឯកជនភាពរបស់ពួកគេជាដើម។

ក្នុងពេលចុះកិច្ចសន្យាប្រើប្រាស់កម្មវិធីអ្វីមួយ កុមារប្រហែលជាមិនបានអានគ្រប់លក្ខខណ្ឌទាំងអស់ទេ មុនធ្វើការសម្រេចចិត្តដែលបណ្ដាលឱ្យជួបហានិភ័យ។ ហានិភ័យនៃកិច្ចសន្យារួមមាន ការប្រមូលទិន្នន័យសម្រាប់ការផ្សាយពាណិជ្ជកម្ម ការបន្លំ ការបោកប្រាស់ និងការទទួលបានមាតិកាមិនសមរម្យ។

## ៤. គ្រោះថ្នាក់នៃការគេចប្រព័ន្ធលើប្រព័ន្ធអនឡាញ

នៅលើពិភពអនឡាញ អ្នកប្រើប្រាស់អាចប្រឈមនឹងការធ្វើបាប ការរុកកួនធាផៅ ការកេងប្រវ័ញ្ចផ្លូវភេទ និងការបំពានពីសំណាក់អ្នកប្រើប្រាស់ដទៃទៀត ឬអ្នកប្រមាញ់តាមអ៊ីនធឺណិត។ ដោយសារកត្តាអំណោយផល និងភាពអនាមិកដែលបច្ចេកវិទ្យាផ្តល់ឱ្យជនរំលោភបំពានប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យាផ្សេងៗ ដើម្បីទាក់ទាញ លួងលោម បោកបញ្ឆោត បង្ខិតបង្ខំកុមារ ក្នុងគោលបំណងកេងប្រវ័ញ្ចពួកគេ។ នៅលើប្រព័ន្ធអនឡាញ កុមារអាចប្រឈមនឹងគ្រោះថ្នាក់ជាក់លាក់មួយចំនួនដូចខាងក្រោម៖

### ៤.១ ការរុកកួនធាផៅតាមអនឡាញ (Cyberbullying)

ជារឿយៗ កុមារក្លាយជាជនរងគ្រោះនៃការរុកកួនធាផៅ ឬសម្លុតកំហែងតាមអនឡាញ ដែលអាចបង្កផលប៉ះពាល់ផ្លូវចិត្ត (ការថប់អារម្មណ៍ ការធ្លាក់ទឹកចិត្ត និងការប៉ុនប៉ងធ្វើអត្តឃាត) ដល់ពួកគេ។ ការរុកកួនធាផៅ ឬសម្លុតកំហែងតាមអនឡាញគឺជាទម្រង់នៃការគំរាមកំហែងដែលកើតឡើងតាមអនឡាញ ឬតាមរយៈវេទិកាប្រាស្រ័យទាក់ទងតាមអនឡាញ។ វាសំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាដូចជាទូរសព្ទ កុំព្យូទ័រ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបៀតបៀន បំភិតបំភ័យ ឬធ្វើបាបនរណាម្នាក់ដោយចេតនាម្តងហើយម្តងទៀត។

ឧទាហរណ៍មួយចំនួននៃការការរុកកួនធាផៅតាមអនឡាញរួមមាន៖

ក) ការផ្ញើសារដែលមានចេតនាបង្កការឈឺចាប់ទៅកាន់នរណាម្នាក់តាមរយៈកម្មវិធីផ្ញើសារ ឬបណ្តាញទំនាក់ទំនងសង្គម។

ខ) ការផ្សព្វផ្សាយពាក្យចចាមអារ៉ាម ឬការនិយាយដើមអំពីនរណាម្នាក់តាមរយៈអ៊ីមែល បន្ទប់ជជែកកម្សាន្ត (Chat Rooms) ឬវេទិកាអនឡាញ។

គ) ការបង្កើត Profile ក្លែងក្លាយ ឬក្លែងបន្លំជានរណាម្នាក់នៅលើបណ្តាញសង្គម ដើម្បីបង្អាប់ ឬចំអកអ្នកដទៃ។

ឃ) ការបង្ហោះ ឬចែករំលែករូបថត ឬវីដេអូ ដែលមានលក្ខណៈឈឺចាប់ ឬអាម៉ាស់របស់នរណាម្នាក់ដោយគ្មានការយល់ព្រមពីសាមីជន។

ង) ការមិនរាប់បញ្ចូល ឬចេតនាទុកនរណាម្នាក់ចេញពីក្រុមអនឡាញ ឬការសន្ទនាដោយចេតនាធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់ពួកគេ។

ច) ការចូលរួមក្នុងក្រុមបំផុសការស្អប់ខ្ពើមតាមអនឡាញ ដែលមានគោលដៅបៀតបៀនបុគ្គល ឬក្រុមណាមួយជាក់លាក់។

វាជារឿងសំខាន់ដែលអ្នកត្រូវយល់ដឹងអំពីការរុកកួនធាផៅតាមអនឡាញ ពីព្រោះវាអាចបង្កគ្រោះ

ថ្នាក់ខ្លាំង និងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់យើង។ ផលប៉ះពាល់មួយចំនួននៃការរុកកួនធាផៅតាមអនឡាញអាចរួមមាន៖

- ទុក្ខព្រួយ ដូចជាអារម្មណ៍សោកសៅ ខឹង ភ័យខ្លាច ឬអស់សង្ឃឹម
- ការធ្លាក់ចុះនៃការគោរពខ្លួនឯង និងទំនុកចិត្ត ដែលនាំឱ្យមានអារម្មណ៍អវិជ្ជមានមកលើខ្លួនឯង
- ការថប់អារម្មណ៍ ភាពតានតឹង និងការពិបាកក្នុងការផ្តោតអារម្មណ៍លើកិច្ចការសាលា
- ភាពឯកាក្នុងសង្គម និងអារម្មណ៍នៃភាពឯកាដោយសារត្រូវបានគេកំណត់ជាគោលដៅ ឬដកចេញពីទំនាក់ទំនងតាមអនឡាញ
- ផលប៉ះពាល់អវិជ្ជមានលើការសិក្សា និងសុខុមាលភាពទូទៅ
- ក្នុងករណីខ្លះ អាចបង្កផលវិបាកធ្ងន់ធ្ងរ ដូចជាជំងឺធ្លាក់ទឹកចិត្ត ឬគំនិតចង់ធ្វើអត្តឃាត ជាដើម

ដើម្បីបង្ការ និងទប់ស្កាត់ការរុកកួនធាផៅតាមអនឡាញ អ្នកគួរចងចាំនូវយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- កុំឆ្លើយតប ឬចូលរួមជាមួយការរុកកួនធាផៅតាមអនឡាញ។ វាអាចធ្វើឱ្យស្ថានការណ៍កាន់តែអាក្រក់ ហើយធ្វើឱ្យអ្នកប្រព្រឹត្តកាន់តែពេញចិត្ត។
- រក្សាទុកភ័ស្តុតាង ដូចជារូបថតអេក្រង់ (Screenshot) ឬសារ ជាភ័ស្តុតាងនៃការរុកកួនធាផៅតាមអនឡាញដែលអាចមានប្រយោជន៍នៅពេលរាយការណ៍អំពីហេតុការណ៍ទាំងនេះ។

## ៤.២ ការបោកប្រាស់តាមអនឡាញ (Online Scams)

ការបោកប្រាស់តាមអនឡាញ គឺជាទម្រង់នៃការបោកបញ្ឆោត ឬល្បិចដែលអ្នកបោកប្រាស់ប្រើដើម្បីទទួលបានព័ត៌មានផ្ទាល់ខ្លួន ប្រាក់កាស ឬទ្រព្យសម្បត្តិដ៏មានតម្លៃពីបុគ្គលណាម្នាក់។ ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួននៃការបោកប្រាស់តាមអនឡាញ ដែលអ្នកគួរយល់ដឹង៖

- ការបោកប្រាស់តាមរយៈការបញ្ឆោត (Phishing Scams)៖ នៅក្នុងការបោកប្រាស់ទាំងនេះ អ្នកក្លែងបន្លំធ្វើពុតជាអង្គភាពដែលអាចទុកចិត្តបាន ដូចជាធនាគារ ឬគេហទំព័រដ៏ពេញនិយម ហើយផ្ញើអ៊ីមែល ឬសារក្លែងក្លាយទៅកាន់នរណាម្នាក់ ដោយស្នើសុំព័ត៌មានផ្ទាល់ខ្លួន ដូចជាពាក្យសម្ងាត់ ព័ត៌មានលម្អិតអំពីកាតធនាគារ ឬលេខសន្តិសុខសង្គម ជាដើម។ ពួកគេប្រើប្រាស់ព័ត៌មាននេះដើម្បីប្រព្រឹត្តការលួចអត្តសញ្ញាណឬធ្វើប្រតិបត្តិការធនាគារដោយគ្មានការអនុញ្ញាត។

*ឧទាហរណ៍៖ អ៊ីមែលដែលអះអាងថា មកពីវេទិកាបណ្តាញទំនាក់ទំនងសង្គមដ៏ពេញនិយមមួយស្នើឱ្យអ្នកប្រើប្រាស់ចុចលើតំណភ្ជាប់ ហើយបញ្ចូលព័ត៌មានសម្ងាត់របស់ពួកគេ ដើម្បីផ្ទៀងផ្ទាត់គណនី។ តំណភ្ជាប់បែបនេះនឹងនាំពួកគេទៅកាន់គេហទំព័រក្លែងក្លាយដែលចាប់យកព័ត៌មានរបស់អ្នក នៅពេលអ្នកបញ្ចូលវា។*

- **ការបោកប្រាស់តាមរយៈការទិញទំនិញលើអ៊ីនធឺណិត (Online Shopping Scams)៖** ការបោកប្រាស់ទាំងនេះកើតឡើងនៅពេលដែលនរណាម្នាក់បង់ប្រាក់សម្រាប់ទិញផលិតផល ឬសេវាកម្មតាមអ៊ីនធឺណិត ប៉ុន្តែពួកគេមិនបានទទួលទំនិញ ឬសេវាកម្មទេ។ នេះអាចកើតឡើងតាមរយៈហាងអនឡាញក្លែងក្លាយ ទំនិញក្លែងក្លាយ ឬការដេញថ្លៃក្លែងបន្លំ។

*ឧទាហរណ៍៖ សិស្សម្នាក់ទិញស្បែកជើងប៉ាតាមួយគូពីហាងអនឡាញដែលផ្តល់តម្លៃដ៏ល្អអស្ចារ្យ។ ទោះជាយ៉ាងណាក៏ដោយ ហាងនេះបានបាត់ភ្លាមៗបន្ទាប់ពីការទូទាត់ប្រាក់ ហើយសិស្សនោះមិនដែលបានទទួលផលិតផលនោះទេ។*

- **ការបោកប្រាស់តាមការលេងឆ្នោត ឬត្រូវរង្វាន់ (Lottery or Prize Scams)៖** នេះកើតឡើងតាមរយៈជនបោកប្រាស់ប្រាប់ជនរងគ្រោះថា ពួកគេបានឈ្នះរង្វាន់ធំ ឆ្នោត ឬរង្វាន់ពិសេស ហើយដើម្បីទទួលបានរង្វាន់ ពួកគេទាមទារថ្លៃសេវា ឬសួរព័ត៌មានផ្ទាល់ខ្លួន។

*ឧទាហរណ៍៖ សារមួយនៅលើគណនីបណ្តាញទំនាក់ទំនងសង្គមរបស់សិស្សម្នាក់ប្រាប់ពួកគេថា ពួកគេបានឈ្នះវិស្សមកាលដោយឥតគិតថ្លៃទៅកាន់រមណីយដ្ឋានប្រណីតមួយកន្លែង។ ទោះយ៉ាងណាក៏ដោយ ដើម្បីទទួលបានរង្វាន់ ពួកគេត្រូវផ្តល់ព័ត៌មានលម្អិតអំពីប័ណ្ណឥណទានរបស់ពួកគេសម្រាប់ថ្លៃដំណើរការ។*

- **ការបោកប្រាស់តាមរយៈការងារក្លែងក្លាយ (Fake Job Scams) ៖** ការបោកប្រាស់ទាំងនេះកំណត់គោលដៅអ្នកដែលកំពុងស្វែងរកឱកាសការងារ សន្យាមុខតំណែងដែលមានប្រាក់ខែខ្ពស់ ឬឱកាសការងារពីផ្ទះ។ ជនរងគ្រោះអាចត្រូវបានគេស្នើសុំឱ្យបង់ប្រាក់ជាមុន ឬផ្តល់ព័ត៌មានផ្ទាល់ខ្លួន ដើម្បីទទួលបានឱកាសការងារ។

*ឧទាហរណ៍៖ សិស្សម្នាក់មើលការផ្សាយពាណិជ្ជកម្មតាមអ៊ីនធឺណិត ដើម្បីស្វែងរកឱកាសការងារពីចម្ងាយ ដែលផ្សព្វផ្សាយថានឹងរកលុយបានយ៉ាងងាយស្រួល។ ពួកគេត្រូវបានតម្រូវឱ្យបង់ថ្លៃចុះឈ្មោះ ឬទិញឧបករណ៍ មុនពេលពួកគេអាចចាប់ផ្តើមធ្វើការ ប៉ុន្តែការងារនោះបែរជាមិនមានទៅវិញ។*

- **ការបោកប្រាស់បែបស្នេហា (Romance Scams)៖** ក្នុងទម្រង់នេះ អ្នកបោកប្រាស់បង្កើតការណាត់ជួបតាមអនឡាញក្លែងក្លាយ និងបង្កើតទំនាក់ទំនងផ្លូវចិត្តជាមួយជនរងគ្រោះ។ ទីបំផុតពួកគេសុំលុយ ឬអំណោយ ដោយទាញយកប្រយោជន៍ពីអារម្មណ៍ស្រឡាញ់ ឬអាណិតអាសូររបស់ជនរងគ្រោះ។

ក្រៅពីគ្រោះថ្នាក់ខាងលើនេះ អ្នកប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិត ជាពិសេសកុមារក៏អាចជួបប្រទះនូវគ្រោះថ្នាក់នៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញក្នុងទម្រង់ផ្សេងៗរួមមាន៖សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ការលួងលោមតាមអនឡាញក្នុងគោលបំណងផ្លូវភេទ ការផ្ញើសារបែបផ្លូវភេទ ការគំរាមទាក់ទងនឹងផ្លូវភេទ និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ។

# ៥. ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើប្រព័ន្ធអនឡាញ

## ៥.១ សម្ភារៈរំលោភបំពានផ្លូវភេទកុមារ

សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (Child Sexual Abuse Material ) សំដៅលើរូបភាព ដូចជា រូបថត វីដេអូ ឬមាតិកាឌីជីថលផ្សេងទៀត រួមទាំងរូបភាពផ្សាយបន្តផ្ទាល់ ដែលបង្ហាញ ឬពណ៌នាពី រូបរាងអាក្រាត ឬកេរ្តិ៍ភេទរបស់កុមារ ឬរូបភាពបង្ហាញពីសកម្មភាពបំពានផ្លូវភេទពាក់ព័ន្ធកុមារក្រោម អាយុ ១៨ឆ្នាំ។

រូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ជាពាក្យដែលត្រូវបានប្រើជំនួសពាក្យ "**រូបភាពអាសអាភាសកុមារ**" ព្រោះពាក្យ "**រូបភាពអាសអាភាសកុមារ**" មិនអាចក្តោបបានទាំងស្រុង ពីទម្រង់នៃការកេងប្រវ័ញ្ចដែលពាក់ព័ន្ធនោះឡើយ ហើយជួនកាលអាចមានការយល់ខុសថា កុមារ មានការយល់ព្រមចំពោះការបង្កើតរូបភាពទាំងនោះ ។



សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងបង្កគ្រោះថ្នាក់ ដែលយើងត្រូវដឹង និង ចូលរួមទប់ស្កាត់។ ជាទូទៅ វាជារូបភាព ឬវីដេអូដែលបង្ហាញថា កុមារកំពុងរងការឈឺចាប់ ឬបង្ខំឱ្យធ្វើ រឿងផ្លូវភេទ ដែលពួកគេមិនបានដឹង ឬមិនយល់ព្រម។ មនុស្សពេញវ័យដែលបង្កើត ចែករំលែក រូបភាព ឬវីដេអូទាំងនេះកំពុងធ្វើទង្វើខុស និងផ្ទុយពីច្បាប់។

រូបភាពទាំងនេះអាចត្រូវបានបង្កើតឡើងតាមរយៈការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ ហើយវាក៏អាចបង្កើតឡើងតាមរយៈការល្បួងលោម ការបោកបញ្ឆោត ឬការគំរាមកុមារ ឱ្យបង្កើតឡើង ឬ ថតដោយខ្លួនឯង (ដែលគេហៅថា រូបភាពដែលថតដោយខ្លួនឯង ឬ Self-Generated Imagery )។

ការកាន់កាប់ ចែកចាយ ឬផលិត រូបភាពអាសអាភាសជាទង្វើខុសច្បាប់ ដែលមានចែងក្នុងច្បាប់នៅស្ទើរតែទូទាំងពិភពលោក រួមទាំង ប្រទេសកម្ពុជា។

សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារអាចត្រូវបានចែកចាយតាមរយៈមធ្យោបាយផ្សេងៗ រួមទាំងអ៊ីនធឺណិតវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម កម្មវិធីផ្ញើសារតាមអនឡាញ និងបណ្តាញចែករំលែកឯកសារផ្សេងទៀត រួមទាំងនៅលើគេហទំព័រខុសច្បាប់ ឬគេហទំព័រងងឹត (Dark Web)។

អ្នកប្រព្រឹត្តអាចទទួលបានរូបភាពទាំងនេះពីកុមារ ដោយប្រើវិធីសាស្ត្រផ្សេងៗ រួមទាំងការបង្ខិតបង្ខំ ការលួងលោម ការគំរាមកំហែងតាមអនឡាញ ឬការលួចចូលប្រើឧបករណ៍ឌីជីថលរបស់កុមារ។ ពួកគេក៏អាចផលិតរូបភាពទាំងនេះ ក្នុងគោលបំណងចែកចាយក្នុងគេហទំព័រផ្សេងៗ។

## ៥.២ ការលួងលោមតាមអនឡាញក្នុងគោលបំណងផ្លូវភេទ

ការលួងលោមសំដៅលើសកម្មភាព និងវិធីសាស្ត្រដែលជនរំលោភបំពានប្រើប្រាស់ ដើម្បីទាក់ទងកុមារតាមប្រព័ន្ធអនឡាញ កសាងទំនុកចិត្ត និងបង្កការភាន់ច្រឡំ ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទលើពួកគេ។ ជនលួងលោមអាចទទួលបានទំនុកចិត្តពីកុមារ ដោយធ្វើពុតជាមនុស្សគួរឱ្យទុកចិត្ត និងប្រើកលល្បិច ដើម្បីបង្កើនទំនាក់ទំនងរបស់ពួកគេបន្តិចម្តងៗឆ្ពោះទៅរកការកេងប្រវ័ញ្ច ឬទំនាក់ទំនងផ្លូវភេទ។ ជនលួងលោមព្យាយាមស្វែងយល់ និងបំពេញតម្រូវការរបស់កុមារ ផ្តល់ការយកចិត្តទុកដាក់ ដើម្បីទទួលបានការទុកចិត្តកាន់តែខ្លាំង។



ពេលខ្លះ ជនលួងលោមបង្ហាញរូបភាពបែផ្លូវភេទ បែបស្រើបស្រាល ឬអាសអាភាសតាមរយៈការផ្ញើសារ ទៅកាន់កុមារ។ ពួកគេយល់ថា វិធីទាំងនេះអាចជួយបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ កាត់បន្ថយភាពអៀនខ្មាសរបស់កុមារ និងធ្វើឱ្យកុមារហ៊ានបញ្ជូនរូបភាពអាក្រាតខ្លួនឯងទៅឱ្យជនលួងលោម។

ការលួងលោមតាមប្រព័ន្ធអនឡាញមានភាពងាយស្រួល និងទទួលបានទំនុកចិត្តពីកុមារច្រើនជាងការលួងលោមដោយផ្ទាល់។ ជាទូទៅ ជនលួងលោមទាក់ទងជាមួយកុមារ ដោយប្រើកម្មវិធីជជែកកម្សាន្ត ហ្គេមតាមអនឡាញ គេហទំព័រ ឬកម្មវិធីបណ្តាញទំនាក់ទំនងសង្គមនានា មុនពេលពួកគេចាប់ផ្តើមសុំឱ្យកុមារចូលប្រើកម្មវិធីផ្ញើសារជាលក្ខណៈឯកជនវិញ។

## ៥.៣ ការផ្ញើសារបែបផ្លូវភេទ

ការផ្ញើសារបែបផ្លូវភេទ (Sexting) សំដៅដល់សកម្មភាពផ្ញើ ឬទទួលសារជារូបថត ឬវីដេអូដែលបង្ហាញផ្នែករាងកាយឯកជន រូបរាងអាក្រាត ឬសំណេរដែលមានលក្ខណៈផ្លូវភេទ រវាងបុគ្គលពីរនាក់

ឬច្រើននាក់ តាមរយៈទូរសព្ទ ឬឧបករណ៍ផ្សេងទៀត ដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត។ ជាទូទៅ ការផ្ញើ ឬទទួលបានសារបែបនេះកើតឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើងបន្ទាប់ពីនរណាម្នាក់ទទួលរងការគំរាមកំហែង ដោយមានការដាក់សម្ពាធ និងការរៀបចំឡើងដោយនរណាម្នាក់ទៀត។



ការផ្ញើសារបែបផ្លូវភេទច្រើនកើតឡើងក្នុងចំណោមក្មេងជំទង់ ដែលកំពុងមានទំនាក់ទំនងជិតស្និទ្ធ ហើយស្ម័គ្រចិត្តចែករំលែករូបភាពឯកជនរបស់ខ្លួន ឬសារដែលមានលក្ខណៈផ្លូវភេទឱ្យគ្នាទៅវិញទៅមក។ ជារឿយៗ កុមារ និងក្មេងជំទង់មិនបានដឹងថា អ្វីដែលពួកគេចែករំលែកនៅលើអ៊ីនធឺណិត វាពិបាកនឹងយកមកវិញ ឬលុបចេញ ជាពិសេសនៅពេលដែលរូបភាពនោះត្រូវបានផ្ញើចេញ និងត្រូវបានគេចម្លង ឬចែករំលែកបន្តពីម្នាក់ទៅម្នាក់។

វាជាការសំខាន់ណាស់ដែលត្រូវដឹងថា កុមារមិនគួរពាក់ព័ន្ធនឹងការផ្ញើសារបែបផ្លូវភេទទេ ពីព្រោះវាជារឿងមិនសមស្របនឹងអាយុ និងការអភិវឌ្ឍរបស់ពួកគេ។ នៅពេលកុមារចូលរួមសកម្មភាពពាក់ព័ន្ធនឹងផ្លូវភេទ ពួកគេប្រហែលជាមិនយល់ច្បាស់ពីហានិភ័យ និងគ្រោះថ្នាក់ដែលអាចកើតឡើង។

នៅពេលដែលអ្នកផ្ញើរូបភាពឬសារបែបផ្លូវភេទអ្នកនឹងមិនអាចគ្រប់គ្រងកន្លែងដែលវាទៅឬនរណាមើលឃើញវាទេ។ រូបភាពទាំងនោះអាចត្រូវបានគេចែករំលែកជាមួយអ្នកដទៃដោយគ្មានការអនុញ្ញាតពីអ្នក ហើយវាពិតជាគួរឱ្យអាម៉ាស់ និងឈឺចាប់ណាស់។ វាក៏សំខាន់ផងដែរក្នុងការចងចាំថាការចែករំលែកមាតិកាដែលមានលក្ខណៈអាសអាភាសទោះបីជាវាជារបស់អ្នកក៏ដោយវាក៏អាចប្រឈមនឹងច្បាប់ផងដែរ។

## ៥.៤ ការគំរាមទាក់ទងនឹងផ្លូវភេទ

ការគំរាមទាក់ទងនឹងផ្លូវភេទតាមអនឡាញ ជាទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទដែលពាក់ព័ន្ធនឹងការគំរាមនរណាម្នាក់ឱ្យផ្ញើរូបថត ឬវីដេអូអាក្រាតរបស់ខ្លួន ឬគំរាមឱ្យនរណាម្នាក់ចូលរួមសកម្មភាពផ្លូវភេទ តាមអនឡាញ ឬដោយផ្ទាល់ ដោយគំរាមថា ខ្លួននឹងបង្ហោះរូបភាពទាំងនោះ ប្រសិនបើមិនធ្វើតាមការទាមទារចង់បានរបស់ពួកគេ។ អ្នកគំរាមក៏អាចទាមទារជនរងគ្រោះឱ្យផ្តល់រូបថត ឬវីដេអូផ្លូវភេទបន្ថែមទៀត ឬជំរិតទារប្រាក់ ជាថ្នូរនឹងការសន្យាមិនបង្ហោះរូបភាពទាំងនោះ។



ជាទូទៅ អ្នកគំរាមប្រើប្រាស់រូបភាពអាក្រាត ឬផ្លូវភេទ ដែលខ្លួនទទួលបានពីជនរងគ្រោះ តាមរយៈការផ្ញើ ឬបញ្ជូនសារដោយការស្ម័គ្រចិត្ត ដើម្បីគំរាមជនរងគ្រោះ។ ការគំរាមទាក់ទងនឹងផ្លូវភេទនេះ ជាធម្មតា កើតឡើងនៅលើវេទិកាអនឡាញ ហើយអាចបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ។

ដើម្បីទទួលបានទំនុកចិត្ត និងរូបភាពឯកជនរបស់ជនរងគ្រោះ ជនល្មើសនៃការគំរាមទាក់ទងនឹងផ្លូវភេទ អាចប្រើកលល្បិចផ្សេងៗ ដូខាងក្រោម ៖

- ស្វែងរកជនរងគ្រោះនៅលើវេទិកាអនឡាញ ដូចជាកម្មវិធីបណ្ដាញទំនាក់ទំនងសង្គម ហ្គេមអនឡាញ ឬកម្មវិធីផ្ញើសារ។
- បង្កើតគណនីក្លែងក្លាយ ឬបន្លំគណនីរបស់អ្នកដទៃ ដើម្បីទាក់ទងកុមារ ឬជនរងគ្រោះ។
- លួងលោមកុមារក្នុងចេតនាបង្កើតទំនាក់ទំនង និងការជឿទុកចិត្ត ហើយបញ្ចុះបញ្ចូលកុមារឱ្យយល់ព្រមផ្ញើរូបថត ឬវីដេអូអាក្រាតរបស់ខ្លួន។
- លួចចូលប្រើឧបករណ៍ផ្ទាល់ខ្លួន ឬគណនីបណ្ដាញទំនាក់ទំនងសង្គមរបស់កុមារតាមរយៈការផ្ញើតំណភ្ជាប់ដែលមានមេរោគបច្ចេកវិទ្យា។នៅពេលចុចលើតំណភ្ជាប់កម្មវិធីមេរោគនឹងដំឡើងដោយស្វ័យប្រវត្តិហើយលួចយកទិន្នន័យក្នុងឧបករណ៍ឬលួចបញ្ជាកាមេរ៉ាក្នុងឧបករណ៍ដើម្បីទទួលបានរូបភាពអាក្រាតរបស់កុមារ ដែលមាននៅក្នុងឧបករណ៍នោះ។

ជនរងគ្រោះនៃការគំរាមទាក់ទងនឹងផ្លូវភេទ អាចជាក្មេងស្រី ឬក្មេងប្រុស។ ពួកគេនឹងកើតមានអារម្មណ៍សោកសៅ បញ្ហាផ្លូវចិត្ត ការភ័យខ្លាច និងការអេស់សង្ឃឹម។ ក្នុងករណីខ្លះ ជនល្មើសក៏ទាមទារការធ្វើសកម្មភាពផ្លូវភេទលើជនរងគ្រោះដោយផ្ទាល់ ដែលអាចបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ។

## ៥.៥ ការផ្សាយផ្ទាល់នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារ




សំដៅលើការចាក់ផ្សាយផ្ទាល់ឬបង្ហាញវីដេអូបន្តផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទកុមារ ដែលអនុញ្ញាតឱ្យអ្នកដទៃចូលមើលឃើញក្នុងពេលតែមួយពីចម្ងាយ តាមរយៈកម្មវិធីអនឡាញដែលមានមុខងារអាចផ្សាយបន្តផ្ទាល់បាន។

កុមារត្រូវបានគេបង្ខំឱ្យសម្ដែងបែបផ្លូវភេទនៅមុខកាម៉េរា (អាចក្នុងសកម្មភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ ...) ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពីពួកគេ។ ជនល្មើសស្វែងរកអ្នកចូលមើលការចាក់ផ្សាយផ្ទាល់ ដើម្បីលក់ដូរវីដេអូបន្តផ្ទាល់ទាំងនោះ។ ពេលខ្លះជនល្មើស អាចផ្ដល់ជាប្រាក់ដល់កុមារ អ្នកសម្របសម្រួល ឬអន្តរការី ដើម្បីដោះដូរជាមួយនឹងការរៀបចំសកម្មភាពផ្លូវភេទទាំងនោះ។

ការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទកុមារ មិនត្រឹមតែជាទម្រង់នៃការកេងប្រវ័ញ្ចដ៏ធ្ងន់ធ្ងរមួយទេ វាក៏ជាទង្វើប្រឆាំងនឹងច្បាប់ជាតិដ៏ធ្ងន់ធ្ងរដែរ។

## ៦. ជនល្មើស និងជនរងគ្រោះ

### ៦.១ ជនល្មើសតាមអនឡាញ

ជនល្មើសតាមអនឡាញ គឺជាមនុស្សដែលប្រើប្រាស់អ៊ីនធឺណិត ដើម្បីព្យាយាមទាក់ទង និងទាញយកផលប្រយោជន៍ពីអ្នកដទៃ ជាពិសេសកុមារ។ ពួកគេអាចបន្លំខ្លួនជានរណាម្នាក់ ដូចជាមិត្តភក្តិរបស់កុមារ ដើម្បីទទួលបានការទុកចិត្ត និងមិត្តភាព។ ពួកគេអាចសួរនាំពីបញ្ហាផ្ទាល់ខ្លួន ចង់ជួបផ្ទាល់ ឬព្យាយាមបញ្ចុះបញ្ចូលអ្នកឱ្យធ្វើរឿងដែលធ្វើឱ្យអ្នកមិនមានអារម្មណ៍ស្រួល ឬមិនមានសុវត្ថិភាព។

ជនល្មើសអាចជាបុគ្គលណាម្នាក់ ដែលកុមារធ្លាប់បានស្គាល់ដោយផ្ទាល់ពីមុន ឬជាជនប្លែកមុខ។ ពួកគេច្រើនតែជាជនមានចំណាប់អារម្មណ៍ផ្លូវភេទចំពោះកុមារ ឬជាបុគ្គលដែលមានគោលដៅទាញយកចំណេញផ្នែកហិរញ្ញវត្ថុ។ ជនល្មើសទាំងនេះកំណត់រកជនរងគ្រោះតាមរយៈការស្វែងយល់ពីភាពងាយរងគ្រោះរបស់ពួកគេ (ឧទាហរណ៍ កុមាររងអំពើហិង្សា កុមារអនាថា កុមារមានពិការភាព...) ឬជ្រើសរើសជនរងគ្រោះដោយចៃដន្យ។

ជាញឹកញាប់ ជនល្មើសចាប់ផ្តើមទំនាក់ទំនងជាមួយកុមារនៅលើអ៊ីនធឺណិត តាមរយៈកម្មវិធីផ្ញើសារតាមអនឡាញ កម្មវិធីហ្គេម ឬវេទិកាបណ្តាញទំនាក់ទំនងសង្គម ជាដើម ដើម្បីបង្កើតភាពស្និទ្ធស្នាល និងកសាងទំនុកចិត្ត មុននឹងឈានដល់ការរំលោភបំពាន ឬកេងប្រវ័ញ្ច។ ជនល្មើសខ្លះអាចប្រើការបង្ខិតបង្ខំ ឬគំរាមកំហែងឱ្យកុមារចូលរួមក្នុងសកម្មភាពផ្លូវភេទតាមអនឡាញ ដើម្បីទទួលបានរូបភាព ឬវីដេអូអាក្រាតរបស់កុមារ ហើយប្រើប្រាស់រូបភាពទាំងនោះ ដើម្បីការកេងប្រវ័ញ្ច ឬជំរិតទាមទារប្រាក់កាស។

ជនល្មើសខ្លះទៀតអាចពាក់ព័ន្ធនឹងសកម្មភាពផ្សាយផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ ចែកចាយ ឬលក់ដូររូបភាពអាសអាភាសកុមារតាមវេទិកាអនឡាញ ដោយពួកគេជឿថា វាជាប្រភពចំណូលងាយស្រួលសម្រាប់ពួកគេ។

វាជារឿងសំខាន់ដែលត្រូវចងចាំថា មិនមែនមនុស្សគ្រប់គ្នាដែលអ្នកជួបតាមអ៊ីនធឺណិត ជាមនុស្សពិតប្រាកដ ដូចដែលគេបាននិយាយប្រាប់អ្នកនោះទេ។ មនុស្សខ្លះអាចធ្វើពុតជាល្អ ប៉ុន្តែពួកគេមានចេតនាអាក្រក់ និង ព្យាយាមធ្វើឱ្យអ្នកឈឺចាប់ទាំងផ្លូវចិត្ត ផ្លូវកាយ ឬសូម្បីតែផ្លូវភេទ។

ការចែករំលែកព័ត៌មានផ្ទាល់ខ្លួននៅលើអ៊ីនធឺណិត ដូចជាឈ្មោះ អាសយដ្ឋាន ឈ្មោះសាលា ឬលេខទូរសព្ទរបស់អ្នក អាចប្រឈមនឹងការកំណត់ជាគោលដៅរបស់ជនល្មើសតាមអ៊ីនធឺណិត។ លើសពីនេះ ការទទួលយកនរណាម្នាក់ដែលអ្នកមិនស្គាល់ជាមិត្តតាមអនឡាញ ក៏អាចបង្កហានិភ័យនៃការបង្កើតទំនាក់ទំនងជាមួយជនល្មើសតាមអ៊ីនធឺណិត ផងដែរ។

## ៦.២ ជនរងគ្រោះ

ជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញ គឺជាបុគ្គលដែលរងគ្រោះថ្នាក់ឬត្រូវបានគេទាញយកផលប្រយោជន៍នៅលើអ៊ីនធឺណិត។ ពួកគេអាចជាកុមារ ឬក្មេងជំទង់ ឬមនុស្សគ្រប់វ័យ ទាំងពីរភេទ ដែលប្រើប្រាស់ប្រព័ន្ធអនឡាញ។

ជាញឹកញាប់ ជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញ ច្រើនមានអាកប្បកិរិយាប្រថុយប្រថានលើអនឡាញ ឬជាកុមារដែលខ្វះភាពកក់ក្ដៅ ឬរងអំពើហិង្សាក្នុងគ្រួសារជាដើម។ លក្ខណៈរបស់ជនរងគ្រោះអាចខុសៗគ្នា ប៉ុន្តែកត្តាទូទៅមួយចំនួនរួមមាន៖

- **អាយុ៖** ជនរងគ្រោះអាចមានអាយុចាប់ពីវ័យកុមារ រហូតដល់ក្មេងជំទង់។ ជនល្មើសអាចកំណត់គោលដៅកុមារទាំងពីរភេទនៅដំណាក់កាលផ្សេងៗ នៃការអភិវឌ្ឍរបស់ពួកគេ ដោយផ្អែកលើចំណង់ចំណូលចិត្ត និងស្ថានភាពរបស់ពួកគេ។
- **វត្តមានលើអ៊ីនធឺណិត៖** ជនរងគ្រោះដែលចំណាយពេលច្រើនលើសកម្មភាពអនឡាញ ដូចជាការប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គម លេងហ្គេមអនឡាញ ជជែកលេងតាមវេទិកាអនឡាញផ្សេងៗ ឬបង្កើតទំនាក់ទំនងច្រើនជាមួយជនដែលពួកគេមិនធ្លាប់បានជួបផ្ទាល់។
- **ភាពងាយរងគ្រោះ៖** ជនល្មើសភាគច្រើនកំណត់គោលដៅជនរងគ្រោះដែលអាចជាកុមារងាយរងគ្រោះដោយសារកត្តាមួយចំនួនដូចជា កង្វះការត្រួតពិនិត្យពីមាតាបិតា ឬធ្លាប់មានប្រវត្តិនៃការរំលោភបំពាន។ ជនល្មើស ទាញយកភាពងាយរងគ្រោះទាំងនេះ ដើម្បីលួងលោម រៀបចំ និងគ្រប់គ្រងជនរងគ្រោះ។

កុមារដែលជាជនរងគ្រោះនៃការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ អាចជួបប្រទះនឹងទុក្ខព្រួយផ្លូវចិត្ត ការភ័យខ្លាច ឬការអាម៉ាស់។ វាជាការសំខាន់ណាស់ដែលត្រូវយល់ថា វាមិនដែលមានកំហុសរបស់ជនរងគ្រោះនោះទេ នៅពេលមានការកេងប្រវ័ញ្ចកើតឡើង។

ប្រសិនបើអ្នកបានដឹងថា នរណាម្នាក់គឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ វាជារឿងសំខាន់ក្នុងការនិយាយប្រាប់មនុស្សពេញវ័យដែលអ្នកទុកចិត្តភ្លាមៗ។ ពួកគេនឹងអាចផ្ដល់ការគាំទ្រជួយអ្នកឱ្យយល់ពីអ្វីដែលកំពុងកើតឡើង និងចាត់វិធានការសមស្របដើម្បីបញ្ឈប់ការកេងប្រវ័ញ្ច។

# ៧. សំណួរឆ្លុះបញ្ចាំង និងសកម្មភាពប្រតិបត្តិ

## សំណួរឆ្លុះបញ្ចាំង

១- តើទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ មានអ្វីខ្លះ?

២- តើអាកប្បកិរិយាបែបណាខ្លះ ដែលអាចធ្លាក់ខ្លួនជាជនរងគ្រោះតាមអនឡាញ?

៣- តើហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារណាមួយ ដែលមានគ្រោះថ្នាក់ខ្ពស់? ហេតុអ្វី?

## សកម្មភាពប្រតិបត្តិ

គ្រូបង្រៀនណែនាំសិស្សឱ្យធ្វើការអង្កេតសិស្សក្នុងសាលារៀនរបស់អ្នកតើមានសិស្សចំនួនប៉ុន្មាននាក់ ដែលមានអាកប្បកិរិយានាំឱ្យមានហានិភ័យ និងគ្រោះថ្នាក់នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ? រួចចងក្រងជារបាយការណ៍ផ្សព្វផ្សាយក្នុងសាលារៀនអ្នក និងរៀបចំជាគម្រោងផ្សព្វផ្សាយការរកឃើញសំខាន់ៗដល់សហគមន៍។

មេរៀនទី ៤

# វិធានសុវត្ថិភាពអនឡាញ និងការឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ

**រយៈពេល៖ ០២ម៉ោងសិក្សា**

## បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សអាច៖

- រៀបរាប់បានពីវិធានផ្សេងៗដើម្បីរក្សាសុវត្ថិភាពពីហានិភ័យ និងគ្រោះថ្នាក់លើប្រព័ន្ធអនឡាញ
- កំណត់បានពីវិធានសុវត្ថិភាពអ៊ីនធឺណិត ដើម្បីគេចផុតពីការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ
- ប្រុងប្រយ័ត្ន ឬដោះស្រាយបញ្ហាដែលកើតឡើងចំពោះខ្លួន ដើម្បីចៀសផុតពីការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ។



កុមារដែលមានការយល់ដឹងពីវិធានសុវត្ថិភាពតាមអនឡាញអាចស្គាល់ពីអាកប្បកិរិយាគួរឱ្យសង្ស័យ ឬសញ្ញានៃការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញ និងអាចការពារសុវត្ថិភាពខ្លួនពីគ្រោះថ្នាក់ណាមួយដែលអាចនឹងកើតឡើង ឬអាចស្វែងរកជំនួយពីមនុស្សពេញវ័យដែលគួរឱ្យទុកចិត្តនៅពេលចាំបាច់។

កុមារត្រូវបានអប់រំណែនាំឱ្យបានច្បាស់ពីឥរិយាបថតាមអនឡាញដែលប្រកបដោយសុវត្ថិភាពតាំងពីពេលដែលពួកគេចាប់ផ្ដើមប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិតដំបូង។ កុមារត្រូវបានអប់រំឱ្យយល់ដឹងអំពីវិធានសមស្រប ប្រកបដោយប្រសិទ្ធភាព ដើម្បីចៀសផុតការកេងប្រវ័ញ្ចផ្លូវភេទ។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាស្វែងយល់ពីវិធី និងវិធានផ្សេងៗ ដែលអាចជួយកុមារឱ្យមានសុវត្ថិភាពនៅពេលស្ថិតលើអនឡាញ អាចឆ្លើយតបក្នុងករណីមានការកេងប្រវ័ញ្ចក្នុងទម្រង់ណាមួយកើតឡើង និងអាចស្វែងរកជំនួយសមស្រប។

## ១.ពាក្យគន្លឹះ

គណនី៖ សំដៅដល់ព័ត៌មានផ្ទាល់ខ្លួន ដែលបានបង្កើតលើប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ប្រើប្រាស់ក្នុងបណ្ដាញទំនាក់ទំនង។

សុវត្ថិភាព៖ សុវត្ថិភាពសំដៅដល់ការរក្សាបានភាពសុខសាន្តក្នុងពេលប្រើប្រាស់បច្ចេកវិទ្យា។

ការរាំងខ្ទប់៖ សំដៅដល់ការបិទសកម្មភាពរបស់ជនណាម្នាក់ដែលមានបំណងមិនត្រឹមត្រូវបៀតបៀនមកលើគណនីរបស់ខ្លួន។

## ២. វិធានសុវត្ថិភាពលើអ៊ីនធឺណិត

អ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ចាំបាច់ត្រូវយល់ដឹងពីវិធានសុវត្ថិភាព នៅពេលតភ្ជាប់បណ្ដាញអ៊ីនធឺណិត ក្នុងការសិក្សាស្រាវជ្រាវ ការអប់រំ ការធ្វើទំនាក់ទំនង ការកម្សាន្ត ការធ្វើពាណិជ្ជកម្ម ។ល។ វិធានសុវត្ថិភាពមួយចំនួនអ្នកប្រើប្រាស់ត្រូវដឹងរួមមាន៖ការកំណត់ឯកជនភាព សុវត្ថិភាពនៃការស្វែងរកព័ត៌មាន ការរាំងខ្ទប់បុគ្គលណាម្នាក់ វិធីសាស្ត្រការពារខ្លួនពីការលួងលោម និងរបៀបប្រាស្រ័យទាក់ទងប្រកបដោយសុវត្ថិភាពលើប្រព័ន្ធអនឡាញ។

### ២.១ ការកំណត់ឯកជនភាព

ឯកជនភាព និងសុវត្ថិភាពតាមអនឡាញមានសារៈសំខាន់ដូចគ្នា។ កម្មវិធីអនឡាញភាគច្រើនផ្ដល់មធ្យោបាយឱ្យយើងអាចកំណត់ឯកជនភាពដើម្បីគ្រប់គ្រងព័ត៌មានដែលយើងកំពុងប្រើប្រាស់ និងចែករំលែក។

អ្នកអាចកំណត់ឯកជនភាពនៅលើកម្មវិធីអនឡាញ ឬគេហទំព័រ ដោយរកមើល និងជ្រើសរើសយកពាក្យដូចជា "គណនីរបស់ខ្ញុំ (My Account)" ឬ "ការកំណត់ (Settings)"។ ពាក្យទាំងពីរនេះ ជាកន្លែងដែលអ្នកនឹងធ្វើការកំណត់ឯកជនភាពតាមការសម្រេចចិត្ត ដូចជា៖

➢ ព័ត៌មានដែលអ្នកចង់ឱ្យគេមើលឃើញនៅលើទំព័រ (Page) ឬប្រវត្តិរូប (Profile) របស់អ្នក
➢ អ្នកអាចចែករំលែកឱ្យអ្នកផ្សេងទៀត មើលឃើញការបង្ហោះ រូបថត វីដេអូ ឬមាតិកាផ្សេងៗ

ក្រោយពីបានធ្វើការកំណត់ឯកជនភាពលើគណនីរួចរាល់ហើយអ្នកត្រូវធ្វើបច្ចុប្បន្នភាពលើការកំណត់ទាំងនេះឱ្យបានទៀងទាត់។

ក្រៅពីការកំណត់ខាងលើ អ្នកក៏ត្រូវគិតថា នរណាគួរទទួលយកធ្វើជាមិត្ត (Friend) ឬអ្នកតាមដាន (Follower) នៅលើអនឡាញ។ ជម្រើសដែលមានសុវត្ថិភាពបំផុតគឺមានតែមិត្តភក្តិ និងក្រុមគ្រួសារដែលអ្នកបានស្គាល់ដោយផ្ទាល់។ ប្រសិនបើអ្នកអនុញ្ញាតឱ្យអ្នកដទៃមើលឃើញ ព័ត៌មានដែលអ្នកបង្ហោះចែករំលែកនោះ អាចនឹងត្រូវបានមើលឃើញដោយអ្នកមិនធ្លាប់ជួប ឬស្គាល់។ ចូរនិយាយជាមួយមនុស្សពេញវ័យដែលអ្នកទុកចិត្ត ដើម្បីស្វែងរកអ្វីដែលធ្វើឱ្យអ្នកមានសុវត្ថិភាពបំផុត។




## ២.២ ការកំណត់សុវត្ថិភាពនៃការស្វែងរកតាមអនឡាញ

អ៊ីនធឺណិតគឺជាកន្លែងមួយដែលផ្ទុកព័ត៌មានល្អៗយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលអ្នកអាចស្វែងរកបាន។ កម្មវិធីស្វែងរកតាមអ៊ីនធឺណិត ឬគេហៅថា ម៉ាស៊ីនស្វែងរក (Search Engine) ជួយយើងប្រមូល និងបង្រួមចំនួនព័ត៌មានដែលមកពីប្រភពផ្សេងៗគ្នា ជុំវិញពិភពលោក។ វាជាឧបករណ៍ដែលមនុស្សប្រើដើម្បីស្វែងរកព័ត៌មានលើប្រធានបទគ្រប់ប្រភេទ។

អ្នកប្រហែលជាដឹងរួចហើយថា ដើម្បីប្រើឧបករណ៍នេះ អ្នកត្រូវវាយសំណួរ ឬពាក្យគន្លឹះទៅក្នុងរបារ ឬប្រអប់ទទេនៅលើម៉ាស៊ីនស្វែងរក ឬនៅក្នុងកម្មវិធីរុករក (Browser) របស់អ្នក (កន្លែងដែលអ្នកវាយអាសយដ្ឋានគេហទំព័រ) ដើម្បីទទួលបានព័ត៌មានអំពីប្រធានបទដែលអ្នកចង់ដឹងបន្ថែម។ បន្ទាប់មក អ្នកចុច Return ឬ Search key ហើយម៉ាស៊ីនស្វែងរកនឹងធ្វើដំណើរការរបស់វា។ ប៉ុន្តែអ្វីដែលសំខាន់អ្នកត្រូវដឹងថា ម៉ាស៊ីនស្វែងរកណាមួយដែលជួយអ្នកស្វែងរកព័ត៌មានប្រកបដោយសុវត្ថិភាព និងអាចទុកចិត្តបាន។

### សកម្មភាពទី៤៖ ប្រមាញ់អ្នករុករកតាមអ៊ីនធឺណិត

ចូរអ្នកស្វែងរកព័ត៌មានជាក់លាក់តាមរយៈវេទិកាអនឡាញផ្សេងៗគ្នា ដោយប្រើប្រាស់តារាងភារកិច្ច ឬសំណួរដែលចែកជូន។ បន្ទាប់មក ចូរពន្យល់ប្រាប់អំពីសារៈសំខាន់នៃការផ្ទៀងផ្ទាត់ព័ត៌មាន ការកំណត់ប្រភពដែលអាចទុកចិត្តបាន និងការប្រុងប្រយ័ត្នរបស់អ្នកក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន។

ម៉ាស៊ីនស្វែងរកមួយចំនួនបានបំពាក់មុខងារបន្ថែម ដើម្បីជួយដល់ការស្វែងរកប្រកបដោយសុវត្ថិភាព។ ជម្រើសនៃការស្វែងរកមួយដែលមានសុវត្ថិភាព គឺការប្រើមុខងារ Safe Search ដែលម៉ាស៊ីនស្វែងរកមួយចំនួនបានបំពាក់មកជាមួយ ដូចជា Google Chrome Firefox Safari ជាដើម។ Safe Search អាចជួយច្រោះមាតិកាមិនសមរម្យចេញ ជាពិសេសមាតិកាដែលមានលក្ខណៈហិង្សា អាសអាភាស អាក្រាត ។ល។ ហើយវាបង្ហាញតែមាតិកាដែលល្អ សមស្របនឹងអាយុ និងមានប្រយោជន៍។

ដើម្បីធ្វើការកំណត់លើសុវត្ថិភាព និងសន្តិសុខនៅលើម៉ាស៊ីនស្វែងរក ឬកម្មវិធីរុករកតាមអ៊ីនធឺណិត អ្នកត្រូវអនុវត្តវិធីដូចខាងក្រោម៖

- នៅលើកម្មវិធី ហ្គូហ្គល ក្រូម (Google Chrome)៖ នៅរបារខាងលើ សូមចុចលើសញ្ញា (⁝) ចុចលើ "ការកំណត់" (Settings) បន្ទាប់មកទៀត ចុចលើពាក្យឯកជនភាព និងសន្តិសុខ (Privacy and Security)។ បន្ទាប់មក ចុចលើពាក្យ សន្តិសុខ (Security) និងចុចយកពាក្យ ការពារប្រកបដោយស្តង់ដា (Standard Protection)
- នៅលើកម្មវិធីហ្វៃអឺហ្វក (Firefox)៖ នៅរបារខាងលើ សូមចុចលើសញ្ញា (⁝) បន្ទាប់មកទៀតចុចលើសញ្ញា ផ្ទាំងឯកជនថ្មី (New Private Window) បន្ទាប់មកចុចលើពាក្យជម្រើស (Options) និង បន្ទាប់មកទៀតចុចលើពាក្យ ឯកជនភាព (Privacy)។
- នៅលើកម្មវិធីសាហ្វារី (Safari)៖ 1. ចុចលើ ពាក្យ ហ្វាល់ (File) បន្ទាប់មកចុចលើពាក្យ ផ្ទាំងឯកជនថ្មី (New Private Window) 2. ចុចលើពាក្យ កុំតាមដាន (Do Not Track) បន្ទាប់មកចុចលើពាក្យ ចំណូលចិត្ត (Preferences) និងជ្រើសរើសពាក្យ ឯកជនភាព (Privacy Tab)។

ការរុករកប្រកបដោយសុវត្ថិភាពមានន័យថាការប្រើប្រាស់អ៊ីនធឺណិតតាមរបៀបដែលអាចការពារអ្នកពីគ្រោះថ្នាក់ដែលអាចកើតមាន។ អ្នកគួរតែអនុវត្តវិធីដូចខាងក្រោម ដើម្បីធ្វើការរុករកប្រកបដោយសុវត្ថិភាពនៅលើអ៊ីនធឺណិត៖

- ប្រើតែគេហទំព័រណាដែលអាចទុកចិត្តបាន៖ វាដូចជាការដែលអ្នកទៅកន្លែងដែលអ្នកដឹងថាមានសុវត្ថិភាពដូច្នេះដែរ។ បើអ្នកជាកុមារ អ្នកគួរចូលទៅប្រើគេហទំព័រដែលបង្កើតឡើងសម្រាប់កុមារ ឬដែលត្រូវបានណែនាំដោយមនុស្សពេញវ័យ ដែលអ្នកជឿទុកចិត្ត ដូចជា ឪពុកម្តាយ គ្រូបង្រៀន ឬបណ្ណារក្សជាដើម។
- រក្សាព័ត៌មានផ្ទាល់ខ្លួនឯកជន៖ វាដូចជាការមិនប្រាប់មនុស្សប្លែកមុខអំពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងជីវិតពិតដែរ។ អ្នកមិនត្រូវចែករំលែកព័ត៌មានផ្ទាល់ខ្លួន ដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ ឬឈ្មោះសាលារៀនតាមអ៊ីនធឺណិតទេ ព្រោះវាជួយការពារឯកជនភាពរបស់អ្នក និងរក្សាសុវត្ថិភាពអ្នក។
- ប្រុងប្រយ័ត្នលើតំណភ្ជាប់ និងការផ្សាយពាណិជ្ជកម្ម៖ តំណភ្ជាប់គឺដូចជាច្រកទ្វារទៅកាន់កន្លែងផ្សេងទៀតនៅលើអ៊ីនធឺណិត។ សូមប្រយ័ត្នចំពោះការចុចលើតំណភ្ជាប់ ឬការផ្សាយពាណិជ្ជកម្ម

ដែលមើលទៅចម្លែក ល្អពេកហួសពីការពិត ឬធ្វើឱ្យអ្នកមានអារម្មណ៍មិនស្រួល។ តំណភ្ជាប់មួយចំនួនអាចនាំអ្នកទៅកាន់គេហទំព័រដែលមិនមានសុវត្ថិភាព មាតិកាមិនសមរម្យ ឬទាញយករបស់មិនល្អដាក់លើកុំព្យូទ័រ ឬឧបករណ៍របស់អ្នក។

- ប្រយ័ត្នចំពោះមនុស្សប្លែកមុខ៖ នៅលើអ៊ីនធឺណិត វាជារឿងសំខាន់ដែលអ្នកត្រូវប្រយ័ត្នពេលនិយាយជាមួយមនុស្សដែលអ្នកមិនធ្លាប់ស្គាល់។ មិនមែនគ្រប់គ្នាលើអនឡាញសុទ្ធតែជាមនុស្សពិតប្រាកដដូចដែលពួកគេនិយាយប្រាប់អ្នកនោះទេ។ ចៀសវាងការផ្តល់ព័ត៌មានផ្ទាល់ខ្លួន ហើយកុំយល់ព្រមជួបនរណាម្នាក់ដែលអ្នកទើបតែបានជួប ឬស្គាល់តាមអ៊ីនធឺណិត។ និយាយជាមួយមនុស្សពេញវ័យ ប្រសិនបើនរណាម្នាក់នៅលើអ៊ីនធឺណិតធ្វើឱ្យអ្នកមានអារម្មណ៍មិនមានសុវត្ថិភាព។

- ប្រាប់មនុស្សពេញវ័យប្រសិនបើមានអ្វីមួយខុសឆ្គង៖ ប្រសិនបើអ្នកឃើញអ្វីមួយនៅលើអ៊ីនធឺណិតដែលធ្វើឱ្យអ្នកមានអារម្មណ៍ភ័យខ្លាច មិនស្រួល ឬច្របូកច្របល់ អ្នកគួរនិយាយជាមួយមនុស្សពេញវ័យដែលអ្នកទុកចិត្ត។ ពួកគេអាចជួយអ្នកឱ្យយល់ពីអ្វីដែលកំពុងកើតឡើង និងចាត់វិធានការត្រឹមត្រូវដើម្បីឱ្យអ្នកមានសុវត្ថិភាព។

## ២.៣ ការរាំងខ្ទប់នរណាម្នាក់លើអនឡាញ(block)

កុមារត្រូវយល់ដឹងពីរបៀបរាំងខ្ទប់ (Block) នរណាម្នាក់ ឬគណនីណាមួយដែលប៉ុនប៉ងលួងលោម ឬធ្វើការគំរាមកំហែងខ្លួន។ កម្មវិធីអនឡាញភាគច្រើនមានមុខងារទប់ស្កាត់ការពារទំនាក់ទំនងជាមួយនរណាម្នាក់ ឬគណនីណាមួយដែលយើងមិនចង់មានទំនាក់ទំនងជាមួយ។ អ្នកត្រូវរាយការណ៍ពីការគំរាមកំហែងជូនសមត្ថកិច្ច ដើម្បីមានចំណាត់ការសមស្របទៅនឹងជនល្មើស។

- ការរាំងខ្ទប់នរណាម្នាក់នៅលើអ៊ីនធឺណិតគឺជាមធ្យោបាយដ៏មានប្រយោជន៍មួយ ដើម្បីការពារពួកគេពីការទាក់ទងអ្នក ឬមើលឃើញមាតិការបស់អ្នក។ អ្នកគួរអនុវត្តជំហានងាយៗដូចខាងក្រោម ដើម្បីរាំងខ្ទប់ នរណាម្នាក់នៅលើអ៊ីនធឺណិត។

- កំណត់អត្តសញ្ញាណបុគ្គល៖ ជាដំបូង អ្នកត្រូវប្រាកដថាអ្នកដឹងថាអ្នកចង់រាំងខ្ទប់អ្នកណា។ នេះអាចជាអ្នកដែលផ្ញើសារដែលមិនសមរម្យមកអ្នក គំរាមអ្នកតាមអនឡាញ ឬរុករកខ្លួនធាផៅអ្នក ឬនរណាម្នាក់ដែលអ្នកមិនចង់ទាក់ទងជាមួយទៀតទេ។

- ស្វែងរកជម្រើសរាំងខ្ទប់៖ វេទិកាផ្សេងគ្នាមានវិធីផ្សេងគ្នាដើម្បីរាំងខ្ទប់នរណាម្នាក់ ដូច្នេះអ្នកត្រូវកំណត់កន្លែងនៃជម្រើសរាំងខ្ទប់នៅក្នុងវេទិកានោះ។ ជាធម្មតា អ្នកអាចរកឃើញវានៅក្នុងប្រវត្តិរូប (Profile) នៅក្នុងម៉ឺនុយនៃការកំណត់ឯកជនភាព (Privacy Settings) ឬនៅក្នុងការកំណត់របស់អ្នក (My Settings) ឬដោយចុចខាងស្តាំលើឈ្មោះឬសាររបស់ពួកគេ។ បន្ទាប់មក ចុចលើពាក្យ "Block" ឬ "Block User"។

- ពិនិត្យមើលការកំណត់ការរាំងខ្ទប់៖ វេទិកាមួយចំនួនផ្តល់នូវជម្រើសរាំងខ្ទប់បន្ថែម ដូចជាការ

រាំងខ្ទប់នរណាម្នាក់ពីការមើលឃើញ Profile របស់អ្នក ឬដាក់កម្រិតលទ្ធភាពរបស់ពួកគេក្នុងការទាក់ទងអ្នក។ សូមចំណាយធ្វើការកំណត់ការរាំងខ្ទប់ ដើម្បីពិនិត្យមើលការកំណត់ទាំងនេះ ហើយកែតម្រូវវាទៅតាមចំណូលចិត្តរបស់អ្នក។

- **រាយការណ៍ប្រសិនបើចាំបាច់៖** ប្រសិនបើនរណាម្នាក់មានអាកប្បកិរិយាមិនសមរម្យ ឬបំពានច្បាប់របស់វេទិកា អ្នកគួររាយការណ៍ពីសកម្មភាពរបស់ពួកគេ។ វានឹងជួយឱ្យវេទិកាចាត់វិធានការសមស្រប និងធានាសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្សេងទៀត។
- **រក្សាសុវត្ថិភាព និងស្វែងរកការគាំទ្រ៖** ការរាំងខ្ទប់នរណាម្នាក់អាចផ្តល់នូវអារម្មណ៍ធូរស្រាល ប៉ុន្តែវាជារឿងសំខាន់ដែលត្រូវចងចាំថាសុវត្ថិភាពតាមអ៊ីនធឺណិតគឺជាអាទិភាពមួយ។ ប្រសិនបើអ្នកមានអារម្មណ៍ថាមានការគំរាមកំហែង ឬត្រូវការជំនួយបន្ថែម អ្នកគួរប្រាប់មនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត ដូចជាឪពុកម្តាយ គ្រូបង្រៀន ឬអ្នកប្រឹក្សា ដែលអាចណែនាំអ្នកឱ្យដោះស្រាយការលំបាកនោះបាន។




## ២.៤ វិធីសាស្ត្រការពារខ្លួនពីការលួងលោមតាមប្រព័ន្ធអនឡាញ

កុមារត្រូវយល់ដឹងអំពីសញ្ញានៃការលួងលោមតាមអនឡាញដូចជាការនិយាយចំអកហួសហេតុការស្នើសុំព័ត៌មានផ្ទាល់ខ្លួន ការព្យាយាមបង្កើតទំនាក់ទំនងផ្លូវចិត្ត ឬអារម្មណ៍ ពីព្រោះវាជារឿងចាំបាច់បំផុតសម្រាប់ការពារសុវត្ថិភាពរបស់ពួកគេ។

អ្នកគួរមានការប្រុងប្រយ័ត្នពេលមានទំនាក់ទំនងជាមួយបុគ្គលប្លែកមុខតាមអនឡាញ ហើយមិនគួរឆ្លើយតបនឹងការប៉ុនប៉ងលួងលោមទេដើម្បីចៀសវាងការផ្តល់ព័ត៌មានផ្ទាល់ខ្លួនរូបថត ឬវីដេអូណាមួយ។ ការចូលរួម ឬឆ្លើយឆ្លងជាមួយជនដែលលួងលោមយើង អាចធ្វើឱ្យយើងប្រឈមនឹងហានិភ័យ និងគ្រោះថ្នាក់នៅលើអនឡាញ។



ប្រសិនជាអាចធ្វើបាន អ្នកគួរព្យាយាមរក្សាទុកព័ស្តុតាងណាមួយនៃការលួងលោម ដូចជារូបថតអេក្រង់ ឬសារជាដើម ពីព្រោះវាគឺជាព័ស្តុតាងសំខាន់នៅពេលរាយការណ៍អំពីឧប្បត្តិហេតុនេះទៅអាជ្ញាធរ ឬមនុស្សពេញវ័យដែលជឿទុកចិត្ត។

## ២.៥ របៀបប្រាស្រ័យទាក់ទងប្រកបដោយសុវត្ថិភាពលើអនឡាញ

ការប្រាស្រ័យទាក់ទងគ្នាតាមអ៊ីនធឺណិតប្រកបដោយសុវត្ថិភាពមានន័យថាការប្រើប្រាស់អ៊ីនធឺណិតតាមរបៀបដែលការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងធានាថាអន្តរទំនាក់ទំនងរបស់អ្នកមានភាពវិជ្ជមាន និងសុវត្ថិភាព។ ខាងក្រោមគឺជាជំហានងាយស្រួលមួយចំនួនអ្នកគួរអនុវត្ត ដើម្បីទំនាក់ទំនងប្រកបដោយសុវត្ថិភាពតាមអ៊ីនធឺណិត៖

- ការកំណត់ឯកជនភាពនៅលើកម្មវិធីបណ្ដាញទំនាក់ទំនងសង្គម កម្មវិធីផ្ញើសារ និងកម្មវិធីអនឡាញផ្សេងទៀត គឺជាចំណែកដ៏សំខាន់មួយក្នុងការរក្សាសុវត្ថិភាព និងគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។
- ការប្រុងប្រយ័ត្នក្នុងការទទួលយកសំណើជាមិត្ត ឬទំនាក់ទំនងពីមនុស្សដែលយើងមិនស្គាល់ក្នុងជីវិតពិត។ វាជារឿងសំខាន់ក្នុងការរំលឹកខ្លួនឯងថា មិនមែនគ្រប់គ្នានៅលើអ៊ីនធឺណិតសុទ្ធតែមានចេតនាល្អនោះទេ។ អ្នកគួរពិចារណាអំពីផលវិបាកដែលអាចកើតមានមុនពេលចែករំលែកព័ត៌មានផ្ទាល់ខ្លួន រូបថត ឬវីដេអូនៅលើអ៊ីនធឺណិត។
- អ្នកមិនគួរចែករំលែកទីតាំងពិតប្រាកដរបស់ខ្លួនតាមអ៊ីនធឺណិតទេ ជាពិសេសនៅក្នុងការបង្ហោះជាសាធារណៈ ឬជាមួយបុគ្គលដែលអ្នកមិនស្គាល់ការចែករំលែកទីតាំងអាចប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នក។
- អ្នកត្រូវយល់ដឹងពីការបោកប្រាស់ និងការប៉ុនប៉ងបន្លំ ហើយត្រូវប្រុងប្រយ័ត្នចំពោះសារ ឬអ៊ីមែលដែលស្នើសុំព័ត៌មានផ្ទាល់ខ្លួនឬប្រាក់។ អ្នកបោកប្រាស់អាចព្យាយាមបញ្ឆោតអ្នកឱ្យបង្ហាញព័ត៌មានលម្អិត។ ប្រសិនបើមានអ្វីមួយហាក់ដូចជាគួរឱ្យសង្ស័យ អ្នកមិនគួរចុចលើតំណភ្ជាប់ណាមួយ ហើយរាយការណ៍វាទៅវេទិកា ឬអ្នកផ្ដល់សេវា។
- ស្វែងយល់អំពីហានិភ័យ និងគ្រោះថ្នាក់នៅលើអ៊ីនធឺណិតនិងរបៀបការពារខ្លួនអ្នកតាមរយៈការសិក្សាស្រាវជ្រាវខ្លួនឯង។ អ្នកអាចរុករកពិភពអនឡាញប្រកបដោយទំនុកចិត្ត និងសុវត្ថិភាពកាន់តែច្រើន ប្រសិនបើអ្នកមានចំណេះដឹង និងសមត្ថភាពគ្រប់គ្រងហានិភ័យទាំងនេះបាន។

# ៣. ការឆ្លើយតបនឹងការគេចប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ

## ៣.១ ការកំណត់អំពីគ្រោះថ្នាក់ និងការរាយការណ៍

កុមារត្រូវបានអប់រំអំពីប្រភេទផ្សេងៗនៃគ្រោះថ្នាក់លើប្រព័ន្ធអនឡាញ និងអំពីរបៀបសម្គាល់សញ្ញាព្រមានដែលអាចបង្កគ្រោះថ្នាក់។ ពួកគេត្រូវយល់ដឹងពីវិធីរាយការណ៍អំពីអាកប្បកិរិយាដែលគួរឱ្យសង្ស័យទៅឪពុកម្តាយ អាណាព្យាបាល គ្រូបង្រៀន ឬអាជ្ញាធរមានសមត្ថកិច្ច។

## ៣.២ ការការពារព័ត៌មានផ្ទាល់ខ្លួន

កុមារត្រូវយល់ដឹងអំពីសារៈសំខាន់នៃការការពារព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេតាមអ៊ីនធឺណិត និងអំពីហានិភ័យដែលទាក់ទងនឹងការចែករំលែកព័ត៌មានលម្អិតសំខាន់ៗដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ ឬព័ត៌មានសាលា។ កុមារក៏ត្រូវប្រុងប្រយ័ត្ននៅពេលមានទំនាក់ទំនងជាមួយមនុស្សប្លែកមុខនៅលើកម្មវិធីអនឡាញ ដែលខ្លួនមិនធ្លាប់បានជួបផ្ទាល់ ហើយមិនគួរចែករំលែកព័ត៌មានផ្ទាល់ខ្លួនជាមួយមនុស្សទាំងនោះ ដោយគ្មានការយល់ព្រមពីឪពុកម្តាយ ឬមនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត។

## ៣.៣ ការកំណត់ឯកជនភាព និងឧបករណ៍សុវត្ថិភាពអនឡាញ

កុមារត្រូវយល់ដឹងពីសារៈសំខាន់នៃការកំណត់ឯកជនភាពនៅលើកម្មវិធីអនឡាញដូចជា បណ្តាញទំនាក់ទំនងសង្គម គេហទំព័រហ្គេម និងកម្មវិធីអនឡាញផ្សេងទៀត។ ពួកគេត្រូវចេះពីរបៀបកែតម្រូវការកំណត់ឯកជនភាពដើម្បីគ្រប់គ្រងអ្នកដែលអាចមើលឃើញព័ត៌មានរបស់ពួកគេនិងទំនាក់ទំនងជាមួយពួកគេ។ កុមារត្រូវបានណែនាំអំពីឧបករណ៍សុវត្ថិភាពតាមអ៊ីនធឺណិតដូចជា កម្មវិធីគ្រប់គ្រងដោយមាតាបិតា (Parental Control) កម្មវិធីចម្រោះមាតិកា (Content Filters) និងកម្មវិធីកំចាត់មេរោគ (Antivirus Software) ដែលអាចពង្រឹងសុវត្ថិភាពអនឡាញរបស់ពួកគេបាន។

## ៣.៤ អក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថល

កុមារត្រូវចេះគិតពិចារណា និងវាយតម្លៃព័ត៌មានតាមអ៊ីនធឺណិត ដើម្បីកំណត់ពីភាពខុសគ្នារវាងប្រភពព័ត៌មានដែលអាចទុកចិត្តបាន និងប្រភពព័ត៌មានមិនគួរទុកចិត្ត ហើយស្គាល់ពីរបៀបផ្ទៀងផ្ទាត់ព័ត៌មាន មុនពេលទទួលយកវាថាជាការពិត។ តាមរយៈការអភិវឌ្ឍជំនាញ ចំណេះដឹងអំពីបច្ចេកវិទ្យាឌីជីថល កុមារអាចរុករកនៅលើអនឡាញបានប្រសើរជាងមុន និងចៀសផុតពីការបោកប្រាស់ ឬព័ត៌មានមិនពិត។ ឪពុកម្តាយត្រូវបង្រៀនកូនអំពីសីលធម៌លើអ៊ីនធឺណិត ការគោរពចំពោះអ្នកដទៃ និងផលវិបាកដែលអាចកើតមានពីសកម្មភាពរបស់ពួកគេនៅលើអ៊ីនធឺណិត។

## ៣.៥ អាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ

កុមារត្រូវបានលើកទឹកចិត្តឱ្យគិតមុននឹងបង្ហោះឬចែករំលែកព័ត៌មានហើយត្រូវយកចិត្តទុកដាក់លើសារៈសំខាន់នៃការប្រព្រឹត្តចំពោះអ្នកដទៃដោយការគោរព ការយោគយល់ និងការទទួលខុសត្រូវ។

## ៣.៦ ការស្វែងរកជំនួយពីមនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត

លើកទឹកចិត្តកុមារឱ្យទាក់ទងជាមួយមនុស្សពេញវ័យដែលគួរឱ្យទុកចិត្តដូចជាឪពុកម្ដាយគ្រូបង្រៀន ឬអាជ្ញាធរមានសមត្ថកិច្ច នៅពេលប្រឈមមុខនឹងការគំរាមកំហែងតាមអ៊ីនធឺណិត។ មនុស្សពេញវ័យអាចផ្ដល់ការណែនាំ ការគាំទ្រ និងជួយកំណត់វិធីឆ្លើយតបដ៏ល្អបំផុត។ ធានាថាកុមារមិននៅម្នាក់ឯងធ្វើឱ្យពួកគេមានអារម្មណ៍ថា មានភាពកក់ក្ដៅដោយមានមនុស្សត្រៀមខ្លួនរួចជាស្រេចដើម្បីជួយពួកគេក្នុងករណីចាំបាច់។

## ៤. សំណួរឆ្លុះបញ្ចាំង និងសកម្មភាពប្រតិបត្តិ

### សំណួរឆ្លុះបញ្ចាំង

១. ចូរពន្យល់វិធានសុវត្ថិភាព នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ?

២. បើអ្នកជួបការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ តើត្រូវដោះស្រាយបញ្ហាដោយរបៀបណា?

៣. តើត្រូវធ្វើដូចម្ដេចដើម្បីរក្សាសុវត្ថិភាពរបស់ខ្លួនក្នុងពេលប្រើប្រាស់ប្រព័ន្ធអនឡាញ?

៤. តើអ្នកត្រូវធ្វើដូចម្ដេចដើម្បីទាញផលប្រយោជន៍ពីប្រព័ន្ធអនឡាញ?

### សកម្មភាពប្រតិបត្តិ

ផ្សព្វផ្សាយសារៈសំខាន់ៗ នៅក្នុងសាលារៀន និងសហគមន៍ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីមានទំនាក់ទំនងក្នុងសង្គម និងធ្វើជំនួញប្រកបដោយសុវត្ថិភាពនិងការទទួលខុសត្រូវ។

# មេរៀនទី ៥ ការរាយការណ៍ និងស្វែងរកជំនួយគាំទ្រសមស្រប

**រយៈពេល៖ ០៣ម៉ោងសិក្សា**

## បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សអាច៖

- បង្ហាញបានពីរបៀបរាយការណ៍ និងស្វែងរកជំនួយគាំទ្រពីភ្នាក់ងារមានសមត្ថកិច្ច
- កំណត់បានពីសកម្មភាពការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ
- មានបម្រុងប្រយ័ត្នខ្ពស់ និងដំណោះស្រាយទាន់ពេលវេលាប្រកបដោយសុវត្ថិភាព។



ការរាយការណ៍ពីសម្ភារៈរំលោភបំពានផ្លូវភេទកុមារអាចជួយលុបបំបាត់មាតិកាទាំងនោះចេញពីគេហទំព័រ ឬកម្មវិធីអនឡាញ បញ្ឈប់ការរំលោភបំពានដែលកំពុងកើតឡើង ឬស្វែងរកជនល្មើសផ្លូវភេទមកទទួលការផ្តន្ទាទោសតាមផ្លូវច្បាប់។ កុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទត្រូវទទួលបានការគាំពារសមស្របពីមនុស្សពេញវ័យ និងអ្នកផ្តល់សេវា ទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈ។

## ១. ការសន្ទនាដោយបើកចំហជាមួយឪពុកម្ដាយ ឬមនុស្សពេញវ័យ

ឪពុកម្ដាយ ឬអាណាព្យាបាល គប្បីជជែក ឬសន្ទនាជាចំហជាមួយកូន ឬអ្នករស់នៅក្នុងបន្ទុកអំពីទំនាក់ទំនងស្នេហា ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ។ ការសន្ទនាជាចំហ ផ្ដល់ដំបូន្មានពិតជាមានសារៈសំខាន់ណាស់ព្រោះវាអាចផ្ដល់ឱ្យពួកគេនូវចំណេះដឹង ដែលអាចជួយការពារពួកគេពីបញ្ហាទាំងនោះ និងកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការស្គាល់ពីស្ថានភាពដែលអាចឱ្យពួកគេប្រឈមហានិភ័យ។ ម្យ៉ាងទៀតការសន្ទនាជាចំហអាចឱ្យមានការពន្យល់ដោយប្រើប្រាស់ភាសាទន់ភ្លន់ប្រកបដោយទំនុកចិត្ត និងការជ្រើសរើសប្រធានបទបានតាមវ័យ និងអាយុរបស់កុមារជារឿងសំខាន់បំផុត និងត្រូវគិតពិចារណាមុនពេលជជែកពិភាក្សា។

សុវត្ថិភាពកុមារតាមអនឡាញសម្រាប់កុមារមិនអាចធ្វើទៅជាគោលគំនិតដោយគ្មានការអប់រំគ្រប់ជ្រុងជ្រោយអំពីបញ្ហាផ្លូវភេទបានឡើយ។ នៅពេលដែលអ្នកប្រើប្រាស់ប្រព័ន្ធអនឡាញ សូមបង្ហាញអាកប្បកិរិយាដូចគ្នានឹងអាកប្បកិរិយាដែលអ្នកចង់ឱ្យកុមារធ្វើ ហើយកុមាររៀនតាមរយៈការចម្លងតាមមនុស្សដទៃទៀត ហេតុនេះសូមដឹកនាំដោយធ្វើជាឧទាហរណ៍។ អាណាព្យាបាលគ្រប់រូបត្រូវនិយាយជាមួយកូនៗរបស់អ្នកអំពី អ្វីដែលពួកគេកំពុងធ្វើនៅតាមប្រព័ន្ធអនឡាញអំពីសុវត្ថិភាព និងវេទិកាគេហទំព័រ និងបណ្ដាញទំនាក់ទំនង ដែលសមស្របទៅតាមអាយុ និងជំហាននានាដែលពួកគេអាចធ្វើបាន ដើម្បីរក្សាសុវត្ថិភាពនៅលើប្រព័ន្ធអ៊ីនធឺណិត មិនត្រឹមតែប៉ុណ្ណោះការជជែកជាមួយកូនពីសុវត្ថិភាពតាមអនឡាញ អ្នកត្រូវមានភាពវិជ្ជមាន និងបើកចំហជានិច្ច។ ពួកគេចេះធ្វើការបែងចែកពីអ្វីដែលល្អនិងអ្វីដែលមិនល្អ ហើយជាពិសេសនឹងធ្វើឱ្យពួកគេមានទំនុកចិត្តក្នុងការប្រាប់ពីក្ដីព្រួយបារម្ភ និងប្រាកដថាកុមារ ឬក្មេងវ័យជំទង់យល់ថាការបង្ហាញអំពីការរំលោភបំពានមិនមែនជាការអាម៉ាស់ឡើយ ហើយជានិច្ចកាលជនល្មើសជាអ្នកដែលត្រូវអាម៉ាស់។

នៅពេលដែលអ្នកដឹងថាមានហានិភ័យមួយចំនួនដែលកូនរបស់អ្នកអាចជួបប្រទះក្នុងពេលដែលពួកគេប្រើប្រាស់ប្រព័ន្ធអនឡាញ អ្នកចាំបាច់ត្រូវកត់សម្គាល់មើលអាកប្បកិរិយា និងការផ្លាស់ប្ដូរអាកប្បកិរិយារបស់កូន។ ការធ្វើបែបនេះអាចជួយអ្នកយល់ថាកូនរបស់អ្នកគឺជាជនរងគ្រោះ ឬការរុកកួនឆាឆៅតាមប្រព័ន្ធបច្ចេកវិទ្យាដែរឬទេ ដោយការឆ្លុះបញ្ចាំងពី ការបង្កការឈឺចាប់ចំពោះខ្លួនឯង អាកប្បកិរិយាបំផ្លិចបំផ្លាញ ឬហិង្សា លែងចាប់អារម្មណ៍ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិត ឬឆាប់ខឹងខ្លាំង និងមានភាពអាថ៌កំបាំងច្រើន អំពីសកម្មភាពរបស់ពួកគេនៅតាមប្រព័ន្ធអនឡាញ។

ការសន្ទនាជាចំហគឺជាជម្រើសមួយដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំងពីតថភាពជាក់ស្ដែង ដែលកើតមានឡើងអំពីរឿងរ៉ាវការរំលោភបំពានការកេងប្រវ័ញ្ចផ្លូវភេទ និងជាឱកាសមួយ ដែលឪពុកម្ដាយឬអណាព្យាបាលបានផ្ដល់នូវដំបូន្មានល្អៗដល់កូនៗ ឬអ្នកដែលជាទីស្រឡាញ់ ដើម្បីការពារពួកគេពីបញ្ហាទាំងនេះ និងកាត់បន្ថយភាពងាយរងគ្រោះ និងការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយសុវត្ថិភាព។

ខណៈពេលដែលកុមារ និងក្មេងវ័យជំទង់ចំណាយពេលច្រើនជាងមុនតាមប្រព័ន្ធអនឡាញសូមចាំថា មិនមែនពេលវេលាដែលចំណាយតាមប្រព័ន្ធអនឡាញនៅខាងមុខអេក្រង់កុំព្យូទ័រ ឬទូរសព្ទសុទ្ធតែដូចគ្នានោះទេ។ អ្នកស្ទើរតែមិនអាចហាមឃាត់កូនមិនឱ្យប្រើប្រាស់ប្រព័ន្ធអនឡាញក្នុងរយៈពេលយូរនោះឡើយនៅពេលដែលពួកគេគ្មានជម្រើសផ្សេងទៀត ដើម្បីទាក់ទងជាមួយមនុស្សនៅក្រៅផ្ទះជាពិសេសប្រសិនបើអ្នកគិតថា កុមារមិនងប់ងុលជាមួយនឹងបច្ចេកវិទ្យាខ្លាំងពេកទេនោះ ហើយពួកគេបែរជារីករាយជាមួយ នឹងឱកាសដែលបច្ចេកវិទ្យាផ្តល់ឱ្យ។

ដូចនេះ វាពិតជាមានសារៈសំខាន់ណាស់ដែលឪពុកម្តាយ អ្នកថែទាំត្រូវមានការយកចិត្តទុកដាក់ខ្ពស់ចំពោះ សុវត្ថិភាពកូនៗតាមអនឡាញ ជាពិសេសផ្តល់ការគាំទ្រដែលសមស្រប និងបង្កើតទំនាក់ទំនងដែលល្អប្រសើរ។ ខាងក្រោមនេះគឺជាចំណុចមួយចំនួនដែលអាចជួយឱ្យអ្នករក្សាសុវត្ថិភាពកូនរបស់អ្នកក្នុងពេលដែលពួកគេចំណាយពេលលើប្រព័ន្ធអនឡាញ៖

### ១.១ ការឯកភាពលើដែនកំណត់ និងការរំពឹងទុក

ការចំណាយពេលបន្ថែមតាមប្រព័ន្ធអនឡាញ មិនមានន័យថាជាការចំណាយពេលដោយគ្មានការត្រួតពិនិត្យនោះទេ។ ឪពុកម្តាយអ្នកថែទាំត្រូវពិភាក្សាគ្នាពីថេរវេលាដែលកូនរបស់អ្នកអាចប្រើប្រាស់ប្រព័ន្ធអនឡាញបាន ដូចជា៖

- ឯកភាពចំពោះរយៈពេលដែលពួកគេអាចលេងហ្គេម ឬប្រើប្រាស់កម្មវិធីតាមអនឡាញ
- ឯកភាពចំពោះរយៈពេលសម្រាប់ពួកគេជជែកលេងជាមួយមិត្តភក្តិ(ឆាតលេង)
- ឯកភាពចំពោះរយៈពេលដែលពួកគេធ្វើការងារសាលារៀន ឬកិច្ចការគ្រូដាក់ឱ្យធ្វើនៅផ្ទះ
- ឯកភាពមិនប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនៅពេលញ៉ាំបាយ (សម្រាប់ឪពុកម្តាយ ឬសម្រាប់កូន)
- មិនកាន់ឧបករណ៍ទាំងនោះនៅក្នុងអំឡុងពេលណាមួយដែលលោកអ្នកកំពុងនៅជាមួយកូនៗ។

### ១.២.ការសន្ទនាជាមួយកូនរបស់អ្នក អំពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ

ការជជែកជាមួយកូនពីសុវត្ថិភាពតាមអនឡាញ នឹងធ្វើឱ្យពួកគេអាចចេះបែងចែកពីអ្វីដែលល្អ និងមិនល្អហើយជាពិសេសនឹងធ្វើឱ្យពួកគេមានទំនុកចិត្តក្នុងការប្រាប់ពីក្តីព្រួយបារម្ភតាមអនឡាញជាមួយអ្នក។

ដូចនេះ វាពិតជាឱកាសដ៏សំខាន់ ដើម្បីចូលរួមជាមួយកូនរបស់អ្នក និងនិយាយជាមួយពួកគេអំពីអ្វីដែលពួកគេ កំពុងធ្វើនៅលើប្រព័ន្ធអនឡាញដូចជាអំពីមាតិកាគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមនានា ដែលមាន សុវត្ថិភាពសមស្របទៅតាមអាយុរបស់ពួកគេ និងជំហានដែលពួកគេអាចធ្វើបានដើម្បីរក្សាសុវត្ថិភាពនៅពេលប្រើប្រាស់អ៊ីនធឺណិត។

ឧទាហរណ៍៖

- ការចំណាយពេលតាមអនឡាញរបស់ពួកគេ ជានិច្ចជាកាលអ្នកត្រូវប្រកាន់ខ្ជាប់នូវភាពវិជ្ជមាន និងនិយាយដោយចំហ
- កុំបង្ហាញនូវប្រតិកម្មអវិជ្ជមានចំពោះអ្វីដែលកូនរបស់អ្នកបានប្រាប់រឿងរ៉ាវដែលពួកគេបាន ជួបប្រទះលើប្រព័ន្ធអនឡាញ
- សួរទៅពួកគេថា តើពួកគេមានការព្រួយបារម្ភអំពីអ្វីដែរឬទេ ?
- បង្ហាញថាអ្នកមានពេលដើម្បីស្តាប់អ្វីដែលពួកគេចង់និយាយ និងដឹងពីមិត្តភក្តិនៅលើអនឡាញ របស់ពួកគេ។

## ១.៣.ការប្រកាន់ខ្ជាប់នូវគុណតម្លៃសង្គមបែបវិជ្ជមាន

ឪពុកម្តាយ និងអ្នកថែទាំត្រូវមានការយល់ដឹង និងការលើកទឹកចិត្តដល់កូនឱ្យមានការប្រកាន់យក នូវគុណតម្លៃសង្គមបែបវិជ្ជមាន ដូចជា ការគោរព ការយល់ចិត្តគ្នា ប្រាស្រ័យទាក់ទងដែលល្អនិង ការដោះស្រាយជម្លោះតាមបែបវិជ្ជមាន។ ទាំងនេះសុទ្ធតែអាចជួយរក្សានូវសុវត្ថិភាពរបស់កុមារតាម ប្រព័ន្ធអនឡាញ ហើយចំណុចទាំងនេះគឺជាអ្វីដែលឪពុកម្តាយអាចនិយាយជាមួយកូនៗបាន ដោយ មិនចាំបាច់ចេះជំនាញបច្ចេកវិទ្យានោះឡើយ។

ឧទាហរណ៍៖ ឪពុកម្តាយ និងអ្នកថែទាំអាចនិយាយជាមួយកូនអ្នកអំពីរបៀបដែលសកម្មភាព និង ឥរិយាបថតាមប្រព័ន្ធអនឡាញរបស់ពួកគេអាចប៉ះពាល់ដល់មនុស្សផ្សេងទៀត និងអំពីឥរិយាបថរបស់ មនុស្សផ្សេងទៀត អាចប៉ះពាល់ដល់កូនៗពួកគេ។

## ១.៤.ការជជែកជាមួយមនុស្សដែលអាចជឿទុកចិត្តបាន



ឪពុកម្តាយ និងអ្នកថែទាំត្រូវដឹងថាកូនរបស់អ្នកមិនមែន ចេះតែមានអារម្មណ៍ងាយស្រួលក្នុងការនិយាយជាមួយអ្នក ឡើយបើទោះជាអ្នកជាឪពុកម្តាយអ្នកថែទាំរបស់គេក៏ដោយ ជាពិសេសនិយាយអំពីបញ្ហា ឬអ្វីដែលពួកគេបានជួបប្រទះ នៅពេលប្រើប្រាស់ប្រព័ន្ធអនឡាញ។ ដូច្នេះអ្នកត្រូវឧស្សាហ៍ ជជែកលេងជាមួយកូន អំពីការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា និងអ៊ីនធឺណិត ឱ្យទៅជាប្រយោជន៍និងមានសុវត្ថិភាព។

## ១.៥ ការប្រើប្រាស់ប្រព័ន្ធអនឡាញជាមួយកូនរបស់អ្នក

សូមកុំគិតថាការលេងហ្គេមអនឡាញជាការកម្សាន្តសម្រាប់កុមារ។ ប៉ុន្តែក៏ជាឱកាសសម្រាប់ឱ្យអ្នក លេងហ្គេមជាមួយកូនរបស់អ្នកផងដែរ ពោលគឺមិនមែនត្រឹមតែការប្រើប្រាស់ប្រព័ន្ធអនឡាញតាម ធម្មតានោះឡើយ។ នេះគឺជាឱកាសដ៏មានប្រយោជន៍ ដើម្បីនិយាយទៅកាន់កូន និងជំរុញឱ្យមានការ

ចូលរួមពីកូនរបស់អ្នក ដើម្បីឱ្យពួកគេដឹងពីពិភពលោកដែលនៅជុំវិញពួកគេ និងពីអ្វីដែលសំខាន់សម្រាប់ពួកគេ។

កម្មវិធីអនឡាញ និងគេហទំព័រក៏អាចផ្តល់ជាគំនិត និងឱកាសសម្រាប់លេងហ្គេមអនឡាញបង្កើតភាពច្នៃប្រតិដ្ឋនៅខាងក្រៅ និងធ្វើលំហាត់ប្រាណនៅក្នុងផ្ទះ ដោយប្រើប្រាស់វីដេអូ ដែលបង្ហាត់ពីការហាត់ប្រាណ ដែលនាំឱ្យមានការបង្កើនទំនាក់ទំនងជាវិជ្ជមានជាមួយគ្នា។

ជាការសខាន់ណាស់ដែលអ្នកត្រូវលៃលករកពេលធ្វើសកម្មភាពនៅខាងក្រៅជាមួយកូនៗរបស់អ្នកឱ្យបានច្រើន និងលើកទឹកចិត្តឱ្យពួកគេធ្វើអ្វីដែលពួកគេពុំមានឱកាសធ្វើនៅក្នុងយុគសម័យឌីជីថល ដូចជាអានសៀវភៅ ឬលេងហ្គេមនៅក្នុងផ្ទះជាដើម។

### ១.៦ ការទាញយកអត្ថប្រយោជន៍ពីប្រព័ន្ធអនឡាញ

ឪពុកម្តាយ និងអ្នកថៃទាំ ត្រូវចេះអប់រំណែនាំ និងចង្អុលបង្ហាញដល់កូនអំពីកម្មវិធីផ្សេងៗដែលមានប្រយោជន៍ជាច្រើនដែលអ៊ីនធឺណិត និងបច្ចេកវិទ្យាអាចផ្តល់ឱ្យ ឧទាហរណ៍ ឧបករណ៍ជួយស្តារសុខភាពផ្លូវចិត្តដោយសមស្រប។ លើសពីនេះទៅទៀត ឪពុកម្តាយ និងអ្នកថៃទាំ ត្រូវបង្រៀនកូនឱ្យមានភាពឆ្លាតវៃនៅពេលអនឡាញ។ ភាពឆ្លាតវៃទាំងនោះរួមមាន ការមិនចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួនការមិនជួបផ្ទាល់ជាមួយនរណាម្នាក់ដែលគ្រាន់តែស្គាល់តាមអនឡាញ ការមិនទទួលយករូបភាព ឬតំណភ្ជាប់ពីមនុស្សមិនស្គាល់ ការពិនិត្យមើលព័ត៌មាន ដើម្បីប្រាកដថាអាចជឿទុកចិត្តបាន ជាពិសេសការប្រាប់ដល់មនុស្សដែលទុកចិត្តបំផុត ប្រសិនបើមានអ្វីមិនល្អកើតឡើង។ ការដឹងពីរបៀបរក្សាសុវត្ថិភាព មិនថាពួកគេធ្វើអ្វីតាមប្រព័ន្ធអនឡាញគឺជារឿងសំខាន់ដែលការនេះតម្រូវឱ្យមានការបំពេញតួនាទីសម្របសម្រួលយ៉ាងសកម្មពីសំណាក់ឪពុកម្តាយនិងអ្នកថៃទាំ មិនថាពួកគេមានជំនាញបច្ចេកទេស ឬអត់ជំនាញឡើយ។

## ២. ការរាយការណ៍

ការរាយការណ៍ពីអាកប្បកិរិយាមិនសមរម្យ ឬគួរឱ្យសង្ស័យណាមួយនៅលើអនឡាញ អាចធ្វើឱ្យអ្នកមានសុវត្ថិភាព និងជួយទប់ស្កាត់គ្រោះថ្នាក់ណាមួយចំពោះអ្នកដទៃ។ វេទិកាភាគច្រើនមានមុខងាររាយការណ៍ ដើម្បីដោះស្រាយបញ្ហាបែបនេះ ហើយអ្នកគួរប្រើមុខងារទាំងនោះដើម្បីរាយការណ៍ករណីណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទ ឬការរុកកួនឆាឆៅតាមអនឡាញ។

ហេតុអ្វីបានជាអ្នកគួររាយការណ៍? ការរាយការណ៍គឺជាវិធីមួយបានបង្កើនលទ្ធភាពនៃការលុបបំបាត់មាតិការំលោភបំពានពីគេហទំព័រ និងជួយបញ្ឈប់ការរំលោភបំពានដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។ វេទិកានិងកម្មវិធីបណ្តាញទំនាក់ទំនងសង្គមភាគច្រើនមានឧបករណ៍ ឬមុខងាររាយការណ៍នៅក្នុងនោះប្រសិនបើអ្នកឃើញមាតិកាផ្លូវភេទ ឬមិនសមរម្យនៅលើអនឡាញ ឬមានអារម្មណ៍ថា កុមារអាចស្ថិតនៅក្នុងស្ថានភាពមួយដែលធ្វើឱ្យពួកគេជួបគ្រោះថ្នាក់នៅលើអនឡាញ អ្នកត្រូវដឹងអំពីទីកន្លែងដើម្បីរាយការណ៍អំពីបញ្ហាទាំងនោះ។

ការធ្វើឱ្យការរាយការណ៍ទៅជារឿងធម្មតាអាចផ្តល់ដល់កុមារដែលរងផលប៉ះពាល់ពីការកេងប្រវ័ញ្ចផ្លូវភេទ នូវជំនឿចិត្តក្នុងការនិយាយអំពីបញ្ហានៅពេលវាកើតឡើង និងបង្កើនឱកាសក្នុងការស្វែងរកជនល្មើស។ បើសិនអ្នកគិតថាមានបទល្មើសផ្លូវភេទមួយបានកើតឡើង ហើយអ្នកចង់ដាក់ពាក្យបណ្តឹងនោះ អ្នកអាចស្វែងរកជំនួយបន្ថែមទៀតបាន តាមរយៈការទាក់ទងទៅអាជ្ញាធរនៅទីកន្លែងដែលអ្នករស់នៅ ទាក់ទងទៅនគរបាលជំនាញ គ្រូបង្រៀន ឬបុគ្គលិកសង្គមកិច្ច។ ពួកគេអាចផ្តល់ព័ត៌មានអំពីសិទ្ធិ សេវា និងជម្រើសនានា ដើម្បីនាំជនល្មើសទៅផ្តន្ទាទោស។ នៅពេលមនុស្សកាន់តែច្រើនរាយការណ៍ ជនល្មើសកាន់តែភ័យខ្លាច និងមិនហ៊ានប្រព្រឹត្តខុស។




## ២.១ ប្រព័ន្ធរាយការណ៍របស់នគរបាល ឬអាជ្ញាធរ

បើសិនអ្នកបានទទួលរងនូវការរំលោភបំពាននៅលើអនឡាញ អ្នកអាចរាយការណ៍ផ្ទាល់ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតអ្នកបំផុត ឬទាក់ទងទៅលេខទូរសព្ទទាន់ហេតុការណ៍របស់នគរបាលជាតិ១២៨៨ (២៤ម៉ោង/៧ថ្ងៃក្នុងមួយសប្តាហ៍) ដោយមិនអស់កម្រៃ។

## ២.២ ប្រព័ន្ធរាយការណ៍តាមអនឡាញ

អង្គការសកម្មភាពដើម្បីកុមារ (APLE) បានដាក់ឱ្យដំណើរការប្រព័ន្ធរាយការណ៍តាមរយៈគេហទំព័រ និងលេខទូរសព្ទរាយការណ៍បន្ទាន់ (Hotline) របស់ខ្លួន សម្រាប់ទទួលការរាយការណ៍អំពីរាល់ទម្រង់នៃការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលសង្ស័យថាបានកើតឡើង។ រាល់ការរាយការណ៍ទៅកាន់ប្រព័ន្ធរាយការណ៍នេះនឹងត្រូវបានរក្សាការសម្ងាត់ ឬអាចធ្វើបានដោយអនាមិក (មិនតម្រូវឱ្យបង្ហាញអត្តសញ្ញាណ)។ អង្គការសកម្មភាពដើម្បីកុមារ (APLE) សហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនគរបាលជាតិ និងអ្នកផ្តល់សេវាគាំទ្រដល់កុមាររងគ្រោះផ្សេងៗ ដើម្បីឆ្លើយតបនឹងការរាយការណ៍របស់អ្នក។

ប្រសិនបើអ្នកជាជនរងគ្រោះឬសង្ស័យថានរណាម្នាក់ជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទអ្នកអាចទាក់ទងមកអង្គការសកម្មភាពដើម្បីកុមារ (APLE) តាមរយៈលេខទូរសព្ទ

រាយការណ៍បន្ទាន់ ០៩២ ៣១១ ៥១១ ឬតាមរយៈគេហទំព័រ www.aplecambodia.org ដោយអនុវត្តតាមជំហានងាយៗដូចខាងក្រោម៖

- ជំហានទី១៖ ចូលទៅកាន់គេហទំព័រ www.aplecambodia.org ។
- ជំហានទី២៖ ស្វែងរក និងចុចប៊ូតុង 'រាយការណ៍ការរំលោភបំពាន' ឬ Report Abuse ។
- ជំហានទី៣៖ ជ្រើសរើសយកប្រភេទករណីនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទណាមួយដែលអ្នកចង់រាយការណ៍ រួចបំពេញទម្រង់ ឬឆ្លើយសំណួរដែលមាន ឱ្យបានត្រឹមត្រូវ។
- ជំហានទី៤៖ ចុចប៊ូតុងបញ្ជូនទម្រង់របាយការណ៍ ជាការស្រេច។

ត្រូវចងចាំថា ក្នុងករណីដែលអ្នក ឬនរណាម្នាក់កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់បន្ទាន់ ហើយទាមទារការអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ អ្នកត្រូវទាក់ទងទៅអាជ្ញាធរនៅទីកន្លែងដែលនៅជិតអ្នកបំផុត។ ការសង្គ្រោះ និងផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះពីការរំលោភបំពានផ្លូវភេទទាន់ពេលវេលា ជារឿងសំខាន់បំផុតនៅពេលវាកើតឡើង។

## ៣. ការស្វែងរក និងទទួលបានសេវាគាំទ្រ

អ្នកគួរពិចារណាទាក់ទងទៅអង្គភាពដែលមានជំនាញក្នុងការជួយជនរងគ្រោះពីការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ ពីព្រោះពួកគេអាចផ្តល់ការណែនាំ ប្រឹក្សាយោបល់ និងធនធានគាំទ្រជាច្រើន ដើម្បីជួយអ្នក និងគ្រួសារ ដោះស្រាយបញ្ហាដែលបានកើតឡើង។ ប្រសិនបើអ្នក ឬកុមារណាម្នាក់ប្រឈមមុខនឹងការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ វាចាំបាច់ត្រូវធ្វើការស្វែងរកជំនួយភ្លាមៗ។

### ៣.១ ការប្រឹក្សាយោបល់ និងការថែទាំផ្លូវចិត្ត

ការស្វែងរកការប្រឹក្សាយោបល់ និងការថែទាំផ្លូវចិត្ត មានសារៈសំខាន់ណាស់ក្នុងការដោះស្រាយជាមួយបទពិសោធន៍រងគ្រោះពីការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ ពីព្រោះការរងគ្រោះទាក់ទងនឹងផ្លូវភេទអាចបង្កផលប៉ះទង្គិចផ្លូវចិត្ត ឬរបួសផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ក្រៅពីរបួសផ្នែករាងកាយ ដូច្នេះវាចាំបាច់ណាស់ក្នុងការស្វែងរកសេវាប្រឹក្សាយោបល់ ឬជំនួយគាំទ្រសមស្រប ដើម្បីជួយអ្នកក្នុងការទប់ទល់នឹងផលប៉ះទង្គិចដែលអាចកើតមាន។ ឪពុកម្តាយ បុគ្គលិកសង្គមកិច្ច បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល គ្រូបង្រៀន ឬមនុស្សពេញវ័យផ្សេងទៀតដែលអ្នកទុកចិត្ត អាចជួយអ្នកស្វែងរកជំនួយ ឬការគាំពារសមស្រប។

### ៣.២ សេវាផ្លូវច្បាប់

ជំនួយផ្នែកច្បាប់ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការស្វែងរកយុត្តិធម៌របស់ជនរងគ្រោះ និងការស្តារឡើងវិញនូវកុមារដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញ។ វាអនុញ្ញាតឱ្យកុមាររងគ្រោះអាចចូលរួមក្នុងដំណើរការផ្លូវច្បាប់ និងទទួលបានសំណងតាមផ្លូវច្បាប់។ វា

ក៏ជួយកុមាររងគ្រោះទទួលបានការព្យាបាលពីអ្នកជំនាញ ការប្រឹក្សាយោបល់ ជម្រកសុវត្ថិភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម។

ជំនួយផ្នែកច្បាប់ក៏ផ្តល់នូវការធានាមួយដល់ការការពារ និងគាំទ្រដល់ជនរងគ្រោះ។ វាជួយបង្កើតវិធានការដើម្បីការពារសុខុមាលភាពរបស់ពួកគេ ដូចជាការទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារឡើងវិញ។ អ្នកជំនាញផ្នែកច្បាប់អាចណែនាំជនរងគ្រោះអំពីដំណើរការផ្លូវច្បាប់ តស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេ និងធានាថា សម្លេងរបស់ពួកគេត្រូវបានស្តាប់ឮ។

ដូច្នេះជំនួយផ្នែកច្បាប់គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កុមាររងគ្រោះពីការរំលោភបំពានផ្លូវភេទព្រោះវាអាចធ្វើឱ្យមានការកាត់ទោសជនល្មើស ការគាំពារជនរងគ្រោះ ការសង្គ្រោះ និងការស្តារនីតិសម្បទា និងក៏រួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់បទល្មើសរបស់អាជ្ញាធរផងដែរ។

ប្រសិនបើកុមារត្រូវបានគេកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ ហើយត្រូវការជំនួយផ្នែកច្បាប់ នេះជាជំហាន មួយចំនួនដែលពួកគេអាចអនុវត្តបាន៖

- **និយាយជាមួយមនុស្សពេញវ័យដែលអ្នកអាចទុកចិត្តបាន៖** ទាក់ទងមនុស្សពេញវ័យណាម្នាក់ដែលគួរឱ្យទុកចិត្តដូចជាឪពុកម្តាយអាណាព្យាបាលគ្រូបង្រៀនឬអ្នកប្រឹក្សាយោបល់ជាដើម។ ប្រាប់ពួកគេអំពីរឿងរ៉ាវនៃការកេងប្រវ័ញ្ចហើយអ្នកត្រូវការជំនួយផ្នែកច្បាប់។ពួកគេអាចណែនាំអ្នកអំពីដំណើរការ និងជួយអ្នកស្វែងរកជំនួយផ្នែកច្បាប់ត្រឹមត្រូវ។
- **ទាក់ទងអ្នកអនុវត្តច្បាប់៖** រាយការណ៍អំពីការកេងប្រវ័ញ្ចលើអ៊ីនធឺណិតទៅភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់របស់អ្នក។ ពួកគេមានសមត្ថកិច្ចស៊ើបអង្កេត និងចាត់វិធានការចំពោះជនល្មើស។ ផ្តល់ឱ្យពួកគេនូវព័ស្តុតាង ឬព័ត៌មានណាមួយដែលអ្នកមាន ដូចជារូបថតអេក្រង់ ឬសារជាដើម។
- **ចូលរួមជាមួយមេធាវី៖** ស្វែងរកជំនួយពីមេធាវីដែលមានជំនាញក្នុងការកេងប្រវ័ញ្ចលើអ៊ីនធឺណិត ឬការការពារកុមារ។ មនុស្សពេញវ័យដែលជឿទុកចិត្តរបស់អ្នកអាចជួយអ្នកស្វែងរកមេធាវីសមរម្យដែលអាចផ្តល់ដំបូន្មានផ្នែកច្បាប់ និងតំណាងឱ្យផលប្រយោជន៍របស់អ្នកក្នុងដំណើរការផ្លូវច្បាប់។
- **ព័ស្តុតាងឯកសារ៖** រក្សាទុកព័ស្តុតាងដែលទាក់ទងនឹងការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ។ វាអាចរួមបញ្ចូលរូបថតអេក្រង់ សារ ឬទម្រង់ទំនាក់ទំនងផ្សេងទៀតណាមួយ។ មេធាវីរបស់អ្នកនឹងត្រូវការព័ស្តុតាងទាំងនេះដើម្បីកសាងសំណុំរឿងប្រឆាំងនឹងជនល្មើស។
- **ស្វែងយល់អំពីសិទ្ធិរបស់អ្នក៖** មេធាវីរបស់អ្នកនឹងពន្យល់អំពីសិទ្ធិ និងជម្រើសផ្លូវច្បាប់របស់អ្នក។

ពួកគេនឹងណែនាំអ្នកអំពីដំណើរការនេះ ដោយធានាថាសិទ្ធិរបស់អ្នកត្រូវបានការពារ ហើយថាអ្នកទទួលបានការគាំទ្រផ្នែកច្បាប់សមស្រប។

## ៤. សំណួរឆ្លុះបញ្ចាំង និងសកម្មភាពប្រតិបត្តិ

### សំណួរឆ្លុះបញ្ចាំង

១. តើការសន្ទនាជាចំហ រវាងឪពុកម្តាយ ជាមួយកូនៗ ឬអ្នកជាទីស្រឡាញ់ មានសារៈសំខាន់អ្វីខ្លះ?

២. ដើម្បីរកជំនួយអំពីបទល្មើសផ្លូវភេទមួយបានកើតឡើង តើអ្នកត្រូវរាយការណ៍ទៅអង្គភាពណាខ្លះ?

៣. តើយើងត្រូវគាំទ្រដល់អ្នកដែលរងគ្រោះដោយការរំលោភបំពានផ្លូវភេទយ៉ាងដូចម្តេចខ្លះ?

### សកម្មភាពប្រតិបត្តិ

សិស្សរៀបចំសកម្មភាពផ្សព្វផ្សាយពីសារៈសំខាន់ៗ ដល់សហគមន៍ ឱ្យបានយល់ដឹងច្បាស់អំពីការរំលោភបំពានផ្លូវភេទទាំងផ្ទាល់ និងអនឡាញ ពីវិធានការពារ រាយការណ៍ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

# ជំពូក ២

## លំនាំនៃការបង្រៀននិងរៀន និងវាយតម្លៃ



## ១. លំនាំនៃការបង្រៀន និងរៀន

ការអនុវត្តកម្មវិធីអប់រំបំណិនជីវិត ស្តីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ គប្បីតម្រូវឱ្យអ្នកសិក្សាសិក្សាទ្រឹស្តីទាំង ៥មេរៀន និងត្រៀមសកម្មភាពដោយបង្កើតជាសំណួរត្រិះរិះ និងស្រាវជ្រាវ បន្ទាប់មកអនុវត្តជាក់ស្តែងនៃខ្លឹមសារ និងវិធានគន្លឹះក្នុងការរក្សាសុវត្ថិភាពអនឡាញនៅក្នុងវេទិកាសាលារៀន និងសហគមន៍ ដោយផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងការប្រតិបត្តិ ឬជីវភាពរស់នៅប្រចាំថ្ងៃ។ គ្រូបង្រៀនអាចប្រើប្រាស់វិធីសាស្ត្រចម្រុះ ដើម្បីជំរុញឱ្យការសិក្សាមានភាពសកម្ម និងមានភាពជាក់ស្តែង។ គ្រូបង្រៀនអាចឱ្យសិស្សធ្វើការងារជាបុគ្គល ឬជាក្រុម ដើម្បីពិភាក្សា ស្រាវជ្រាវ វិភាគ និងរិះរកវិធានថ្មីៗ ដែលត្រូវការជួយការពារដល់សហគមន៍ផ្ទាល់។

ការបង្រៀន និងរៀន ផ្នែកអប់រំបំណិនជីវិត ត្រូវប្រើតាមគោលវិធីសិស្សមជ្ឈមណ្ឌលដែលជាវិធី ឬរបៀបមួយនៃការរៀន ដែលគ្រូទុកឱកាសឱ្យសិស្សធ្វើសកម្មភាពបានច្រើន ឬដោយផ្ទាល់ដើម្បីសម្រេចវត្ថុបំណងនៃមេរៀន តាមលំនាំនៃការបង្រៀននិងរៀនបំណិនជីវិត និងមានសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ដាក់ចំណោទបញ្ហាដល់សិស្ស សម្របសម្រួល ផ្តល់ឱកាស និងលើកទឹកចិត្តសិស្សក្នុងការប្រើប្រាស់សក្តានុពលដែលសិស្សមានឱ្យអស់លទ្ធភាពក្នុងការស្រាវជ្រាវ រុករក បកស្រាយ និងសំយោគ
- បង្កលក្ខណៈឱ្យសិស្សមានសកម្មភាព ឬចូលរួមក្នុងការសិក្សាដោយរីករាយ និងមានទំនាក់ទំនងជាមួយក្រុមគោលដៅជាក់លាក់ប្រកបដោយអត្ថន័យត្រឹមត្រូវដែលជា គន្លឹះនាំឱ្យសិស្សយល់និងមានបទពិសោធន៍ ច្បាស់លាស់ក្នុងការសិក្សា និងការរស់នៅ
- បង្កលក្ខណៈឱ្យសិស្សមានការអភិវឌ្ឍពេញលេញលើបំណិនក្នុងការគិត ការស្វែងយល់ពីសង្គម និងឥរិយាបថផ្ទាល់ខ្លួន ព្រមទាំងផ្តល់ការសិក្សាប្រកបដោយការពន្យល់ត្រឹមត្រូវ សមហេតុផល
- បង្កលក្ខណៈឱ្យសិស្សធ្វើសកម្មភាពជាបុគ្គលនិងជាក្រុម ដើម្បីបង្កើតជាគម្រោងនានា ដោយជួយសង្ខេបគំនិតសំខាន់ៗដែលបានធ្វើនោះ រួចហើយបង្ហាញការអនុវត្តក្នុងសាលារៀន និងសហគមន៍
- ជួយសិស្សរៀនរួមគ្នាជាក្រុម ដែលមានការចាត់ចែងភារកិច្ចច្បាស់លាស់ បង្កលក្ខណៈឱ្យការរៀនមានភាពសកម្ម ជួយគ្នាទៅវិញទៅមកក្នុងក្រុម ដោយមានការគាំទ្រការសិក្សារបស់សិស្សពូកែដល់សិស្សខ្សោយ សិស្សច្បងនិងសិស្សប្អូន និងស្ម័គ្រចិត្តចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់សាលារៀននិងសហគមន៍ដទៃ។

ដើម្បីឱ្យការរៀនមានភាពសកម្ម វិធីសាស្ត្របង្រៀន និងរៀន ៦ដំណាក់កាល ត្រូវបានអនុវត្តដូចខាងក្រោម៖

### ❖ ដំណាក់កាលទី១. ការស្វែងយល់ពីប្រធានបទសិក្សា

គ្រូបង្រៀន ត្រូវបែងចែកសិស្សជាក្រុម ដើម្បីឱ្យពួកគេពិភាក្សា លើខ្លឹមសារមេរៀននីមួយៗ ព្រមទាំងបង្ហាត់បង្ហាញ និងណែនាំសិស្សឱ្យយល់ដឹងច្បាស់លាស់នូវខ្លឹមសារមេរៀននីមួយៗ ដោយបំផុសសំណួរលើចំណេះដឹងដែលមានស្រាប់ ការអានឯកសារពាក់ព័ន្ធ និងករណីសិក្សា។

### ❖ ដំណាក់កាលទី២. ការស្រង់ព័ត៌មានពីសហគមន៍ឬអ្នកពាក់ព័ន្ធ

គ្រូបង្រៀន ត្រូវណែនាំសិស្សឱ្យចេះបង្កើតកម្រងសំណួរតាមខ្លឹមសារមេរៀន ហាត់សមការសម្ភាសន៍ និងចេះសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ និងចេះធ្វើរបាយការណ៍ពីដំណើរការប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធ។

### ❖ ដំណាក់កាលទី៣. ការវិភាគព័ត៌មាន និងកំណត់ដំណោះស្រាយ

គ្រូបង្រៀន ត្រូវណែនាំសិស្សឱ្យចេះវិភាគព័ត៌មានបានពីការស្រាវជ្រាវ ចេះបង្ហាញពីលទ្ធផលស្រាវជ្រាវ ចេះកំណត់ដំណោះស្រាយ និងសង្ខេបខ្លឹមសារចងក្រងជាអាទិភាពដំណោះស្រាយដោយបង្ហាញពីអ្នកពាក់ព័ន្ធ។

### ❖ ដំណាក់កាលទី៤. ការរៀបចំគម្រោងផ្សព្វផ្សាយ

ណែនាំសិស្សឱ្យចេះជ្រើសរើសយកដំណោះស្រាយអាទិភាព ចេះរៀបចំផែនការផ្សព្វផ្សាយ បង្ហាញផែនការ និងហ្វឹកហាត់ និងរៀបចំផែនការអនុវត្ត តាមរយៈការអនុវត្តការងារជាក្រុម។

### ❖ ដំណាក់កាលទី៥. ការផ្សព្វផ្សាយគម្រោង

គ្រូបង្រៀន ត្រូវណែនាំសិស្សឱ្យចេះអនុវត្តផែនការសកម្មភាពដែលបានលើកឡើង ដោយមានផ្តល់ការណែនាំពីនាយកសាលា ចេះដឹកនាំសកម្មភាពជាក់ស្តែងអនុវត្តនៅក្នុងសាលារៀន និងតាមមូលដ្ឋាន ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ ដើម្បីកែលម្អសកម្មភាព និងខ្លឹមសារផ្សព្វផ្សាយ ព្រមទាំងកំណត់ក្រុមគោលដៅ។

### ❖ ដំណាក់កាលទី៦. ការឆ្លុះបញ្ចាំងសកម្មភាព

គ្រូបង្រៀន ត្រូវណែនាំសិស្សឱ្យចេះឆ្លុះបញ្ចាំងលើសកម្មភាពដែលបានអនុវត្តតាមមូលដ្ឋាន និងចេះសរសេររបាយការណ៍បញ្ចប់សកម្មភាព (ការសម្រេចបាន ការប្រឈម ចំណុចកែលម្អ និងសំណូមពរ)។

លំនាំនៃការបង្រៀនលម្អិតទាំង៦ដំណាក់កាលមានក្នុងឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន បោះពុម្ពឆ្នាំ ២០១៩ ដែលបានចែកជូនដល់សាលារៀន និងអាចសិក្សាលម្អិតនៅលើគេហទំព័រថ្នាលអភិវឌ្ឍសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានតំណភ្ជាប់នៅក្នុងឧបសម្ព័ន្ធ៤។

## ល្បិចបង្រៀន

គ្រូបង្រៀនមិនគ្រាន់តែយកសកម្មភាពទាំងអស់ទៅបង្រៀននោះទេ។ គ្រូត្រូវដឹងច្បាស់ថាតើត្រូវរៀបចំសកម្មភាពណាខ្លះដើម្បីឱ្យសិស្សយល់ច្បាស់ពីប្រធានបទសិក្សា ។

គ្រូបង្រៀនត្រូវសិក្សាលម្អិតលើខ្លឹមសារមេរៀននីមួយៗ សារសុវត្ថិភាពក្នុងឧបសម្ព័ន្ធ១ និងករណីសិក្សាដូចមានក្នុងឧបសម្ព័ន្ធ២ ឬករណីដែលកើតមានជាក់ស្តែងនៅតាមសហគមន៍ ដើម្បីដឹកនាំការពិភាក្សាក្រុមសិស្សឱ្យបានកាន់តែស៊ីជម្រៅថែមទៀត។ ក្រៅពីនេះគ្រូបង្រៀនត្រូវបង្ហាញវីដេអូករណីសិក្សាដែលបានបង្កើតឡើងដោយភាគីពាក់ព័ន្ធ ដូចមានតំណភ្ជាប់ក្នុងឧបសម្ព័ន្ធ៤។

## ២- វាយតម្លៃការបង្រៀន និងរៀន

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ត្រូវធ្វើឡើងចំពោះវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាដំណើរការជានិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងព័ស្តុតាងអំពីកម្រិតនៃសមត្ថភាពរបស់សិស្សក្រោយពីដំណើរការរៀន និងបង្រៀនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ ការវាយតម្លៃគឺសំដៅរកព័ត៌មាន ឬព័ស្តុតាង ដើម្បីសន្និដ្ឋានក្នុងការសម្រេចចិត្តរកវិធី និងផ្តល់ជាតុចូលជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ ឱ្យឆ្លើយតបនឹងស្តង់ដាលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។

ការវាយតម្លៃដើម្បីផ្តល់ពិន្ទុសម្រាប់ប្រធានបទសិក្សានេះគ្រូត្រូវផ្តោតលើទិដ្ឋភាព២ដូចខាងក្រោម៖

**១. ពិន្ទុវិជ្ជាសម្បទា** ត្រូវបានអនុវត្តដោយយកការឆ្លើយនឹងចំណេះដឹងខ្លឹមសារប្រធានបទដែលបានរៀនតាមមេរៀននីមួយៗ ស្មើនឹង ៤០% នៃពិន្ទុសរុបមុខវិជ្ជា។ គ្រូបង្រៀនត្រូវបង្កើតសំណួរប្រឡងប្រចាំខែ និងឆមាស តាមខ្លឹមសារមេរៀននីមួយៗ។

**២. ពិន្ទុបំណិនសម្បទានិងចរិយាសម្បទា** ត្រូវបានវាយតម្លៃដោយផ្តោតលើបំណិនសំខាន់ៗមាន៖១.ការត្រិះរិះពិចារណា ២.ការច្នៃប្រតិដ្ឋ ៣.កិច្ចសហការ ៤.ប្រាស្រ័យទាក់ទង និង វិន័យសីលធម៌ គុណធម៌ និងឥរិយាបថ រួមទាំងការចូលរួមក្នុងសកម្មភាពសង្គម ស្មើនឹង ៦០%នៃពិន្ទុសរុបមុខវិជ្ជា។ គ្រូបង្រៀនត្រូវផ្តោតលើសកម្មភាពប្រតិបត្តិជាបុគ្គល និងជាក្រុម ព្រមទាំងការងារគម្រោងដោយបង្កើតតារាងវាយតម្លៃលម្អិតលើបំណិននិងចរិយាសម្បទានេះ ។

មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ត្រូវបានផ្តល់ពិន្ទុ ៥០ ដូចមុខវិជ្ជាគោលដទៃ ហើយត្រូវបានបែងចែកដូចខាងក្រោម៖

- **ចំណេះដឹង៖** ៤០% ស្មើនឹង ២០គ្រូបង្រៀនត្រូវផ្តល់ជូនសិស្សអតិបរមា ២០ពិន្ទុ។
- **សកម្មភាពប្រតិបត្តិ (បំណិន និងចរិយា)៖** ៦០% ស្មើនឹង៣០គ្រូបង្រៀនត្រូវផ្តល់ជូនសិស្សអតិបរមា៣០ពិន្ទុ ។

ការវាយតម្លៃនេះ ត្រូវអនុវត្តតាមឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ឆ្នាំ២០១៩។

# ឧបសម្ព័ន្ធ ១៖ សារសុវត្ថិភាពអនឡាញ

- វាមិនមានបញ្ហាអ្វីដែលនិយាយថា "ទេ" ចំពោះនរណាម្នាក់ដែលកំពុងតែសុំឱ្យអ្នកធ្វើអ្វីមួយដែលអ្នកមិនមានផាសុកភាពតាមប្រព័ន្ធអ៊ីនធឺណិត។
- មិត្តល្អមិនដែលនាំនរណាម្នាក់ឱ្យជួបគ្រោះថ្នាក់តាមអនឡាញ៖ ក្នុងនាមជាមិត្តល្អគឺមានន័យថាលោកអ្នកមិនដែលស្នើសុំរូបភាពអាក្រាតកាយរបស់នរណាម្នាក់ដែលអាចឱ្យពួកគេមានគ្រោះថ្នាក់ ហើយធ្វើឱ្យពួកគេមានអារម្មណ៍មិនស្រួល។ មិត្តល្អពិតប្រាកដមិនដែលដាក់ឱ្យនរណាម្នាក់មានហានិភ័យបែបនោះទេ។
- សូមជឿទុកចិត្តលើសភាវគតិរបស់អ្នកនៅលើអ៊ីនធឺណិត។ ប្រសិនបើស្ថានភាពមិនមានអារម្មណ៍ត្រឹមត្រូវទេនោះវាមិនត្រឹមត្រូវទេ!
- សូមកុំចាប់អារម្មណ៍ ឬរាំងខ្ទប់ ឬរាយការណ៍អំពីជនណាដែលរំខានអ្នកតាមប្រព័ន្ធអ៊ីនធឺណិត៖ ប្រសិនបើមាននរណាម្នាក់ផ្ញើសារមកអ្នកដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនស្រួលពេលខ្លះការដែលមិនឆ្លើយតបទៅវិញគឺជាជម្រើសដ៏ល្អបំផុត។ ទោះយ៉ាងណាក៏ដោយប្រសិនបើពួកគេរំខានអ្នក អ្នកត្រូវបិទចោល ឬ រាយការណ៍ពីបុគ្គលនោះ។
- សូមចៀសវាងរូបភាពអាសអាភាស វាធ្វើឱ្យអ្នកមានការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖ ការមើលរូបអាសអាភាសមនុស្សពេញវ័យមិនគួរធ្វើជាមធ្យោបាយដើម្បីរៀនពីការរួមភេទទេ។ វាពិពណ៌នាអំពីទំនាក់ទំនងមិនប្រាកដប្រជាដែលជារឿយៗមានអាកប្បកិរិយាបំពាន និងបង្កើនហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទ។ ប្រសិនបើអ្នកចង់ដឹងអំពីទំនាក់ទំនងផ្លូវភេទ វាជាការល្អបំផុតដើម្បីសាកសួរមនុស្សពេញវ័យដែលអាចទុកចិត្តបាន ឬរៀនពីប្រភពដែលមានសុវត្ថិភាពនិងគួរឱ្យទុកចិត្ត។
- នៅពេលរាប់អានមនុស្សថ្មីតាមអ៊ីនធឺណិតជាមិត្ត សូមមានការប្រុងប្រយ័ត្ន និងគិតគូឱ្យម៉ត់ចត់ មិនមែនជនចម្លែកទាំងអស់ដែលអ្នកជួបតាមអ៊ីនធឺណិតសុទ្ធតែមានចេតនាល្អនោះទេ។
- សូមកំណត់ចំនួនអ្នកដែលអាចមើលឃើញព័ត៌មានរបស់អ្នកតាមប្រព័ន្ធអ៊ីនធឺណិត៖ មានមិត្តភក្តិច្រើនតាមប្រព័ន្ធអ៊ីនធឺណិតអាចធ្វើឱ្យអ្នកសប្បាយរីករាយ ក៏ប៉ុន្តែ វាក៏មានហានិភ័យផងដែរ។ សូមកត់សម្គាល់ថានរណាខ្លះដែលអ្នកបានស្នើសុំធ្វើជាមិត្តភក្តិរបស់អ្នក មិនមែនគ្រប់គ្នាសុទ្ធតែអាចចូលមើលព័ត៌មានអំពីអ្នកបានទេ។
- ប្រសិនបើការស្នើសុំជាមិត្តមើលទៅគួរឱ្យសង្ស័យវាជាការល្អប្រសើរកុំទទួលយកពួកគេជាមិត្ត៖ នៅពេលណាដែលអ្នកទទួលបានការស្នើសុំពីជាមិត្តតាមអ៊ីនធឺណិត សូមពិនិត្យមើលសាវតារបស់ពួកគេមុនពេលទទួលយក។ ជនល្មើសផ្លូវភេទតាមអ៊ីនធឺណិតមួយចំនួននឹងប្រើប្រវត្តិរូបក្លែងក្លាយដើម្បីទទួលបានការទុកចិត្តពីអ្នក។

- ត្រូវអនុវត្តការប្រុងប្រយ័ត្នជាចាំបាច់ ប្រសិនបើអ្នកសម្រេចចិត្តជួបមិត្តភក្តិតាមអ៊ីនធឺណិតដោយផ្ទាល់ ការជួបមនុស្សម្នាក់ដែលអ្នកទើបតែជួបតាមអ៊ីនធឺណិតអាចមានគ្រោះថ្នាក់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបានពិនិត្យមើលស្ថានភាព ហើយសម្រេចថាវាមានសុវត្ថិភាពក្នុងការជួបពួកគេ សូមប្រាកដថាអ្នកប្រាប់មនុស្សពេញវ័យដែលអ្នកទុកចិត្តអំពីរឿងនោះ ជួបគ្នានៅកន្លែងសាធារណៈ និងគួរមាននរណាម្នាក់ទៅជាមួយអ្នក។

- សូម្បីតែអ្នកផ្ញើរូបភាពដែលមានស្លៀកពាក់ពេញលេញក៏ដោយ ក៏ជនល្មើសខ្លះអាចប្រើកម្មវិធីកាត់តផ្សេងៗ ដើម្បីកែប្រែរូបភាពដើមទៅជារូបភាពបែបអាក្រាតបានដែរ។

- ចូរអ្នកដឹងអំពីគេហទំព័រដែលអ្នកកំពុងរុករកគេហទំព័រនានា៖ គេហទំព័រមួយចំនួនមានផ្ទុកឯកសារដែលអាចបង្កគ្រោះថ្នាក់ និងធ្វើឱ្យអ្នកប្រឈមនឹងការរំលោភបំពានផ្លូវភេទ។ សូមប្រុងប្រយ័ត្ននៅពេលស្វែងរកលើអ៊ីនធឺណិត ហើយកុំចូលគេហទំព័រដែលមើលទៅគួរឱ្យសង្ស័យ ឬទាញយកឯកសារដែលមិនបានបញ្ជាក់ត្រឹមត្រូវ។

- លេខសម្ងាត់ និងឈ្មោះអ្នកប្រើប្រាស់គួរតែរក្សាជាការសម្ងាត់៖ រក្សាលេខសម្ងាត់ និងឈ្មោះអ្នកប្រើប្រាស់ គឺជាការរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកឱ្យមានសុវត្ថិភាពហើយសូមកុំចែកចាយវាទៅកាន់អ្នកដទៃ សូម្បីតែមិត្តភក្តិរបស់អ្នកក៏ដោយ។

- ត្រូវប្រាកដថា អ្នកបានកំណត់ឯកជនភាពរបស់អ្នកដើម្បីអនុញ្ញាតឱ្យតែមនុស្សត្រឹមត្រូវអាចចូលមើលអ្វីដែលអ្នកបានបង្ហោះលើអ៊ីនធឺណិត។

- សូមរក្សាខ្លួនអ្នកឱ្យទាន់សភាពការណ៍ជាមួយនឹងនីតិវិធីសុវត្ថិភាពតាមអ៊ីនធឺណិត៖ ការយល់ដឹងអំពី ហានិភ័យដែលកើតមានជាមួយនឹងការប្រើប្រាស់អ៊ីនធឺណិតនឹងនាំឱ្យអ្នកមានបទពិសោធន៍ដែលមាន សុវត្ថិភាពនិងល្អប្រសើរ។

- ចូរកត់សំគាល់ពីសកម្មភាពរបស់អ្នកតាមអ៊ីនធឺណិត និងការបង្ហោះនានាដែលអ្នកសម្រេចផ្តល់យោបល់ ឬចែករំលែកបន្ត។

- អ្វីៗគ្រប់យ៉ាងដែលអ្នកធ្វើតាមអ៊ីនធឺណិតមានដានឌីជីថលហើយអាចតាមដានបាន។

- ត្រូវចាំថាត្រូវបិទគណនីរបស់អ្នកបន្ទាប់ពីប្រើប្រាស់រួច ដើម្បីរក្សាព័ត៌មានរបស់អ្នកឱ្យមានសុវត្ថិភាព។

- ចៀសវាងបង្ហោះព័ត៌មានផ្ទាល់ខ្លួន និងការកំណត់អត្តសញ្ញាណរបស់អ្នកលើអ៊ីនធឺណិត៖ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកអាចត្រូវបានទាញយកប្រយោជន៍ ប្រសិនបើមើលឃើញដោយមនុស្សមិនល្អ ហើយធ្វើឱ្យអ្នកមានគ្រោះថ្នាក់។ ប្រសិនបើអ្នកសម្រេចចិត្តបញ្ចូលព័ត៌មានតាមអ៊ីនធឺណិតសូមប្រាកដថា វាមិនមែនជារឿងផ្ទាល់ខ្លួនទេ ហើយវាអាចត្រូវបានគេប្រើដើម្បីប្រឆាំងនឹងអ្នក។

- សូមធ្វើឱ្យប្រាកដថា អ្នកមានផាសុកភាពជាមួយនឹងអ្វីដែលអ្នកផ្ញើ ឬបញ្ចូលលើប្រព័ន្ធអ៊ីនធឺណិត៖ អ្វីដែលអ្នកបញ្ចូលទៅលើប្រព័ន្ធអ៊ីនធឺណិតគឺស្ទើរតែមិនអាចដកចេញវិញបានឡើយ។ ប្រសិនបើអ្នកសម្រេចចិត្តបង្ហោះអ្វីមួយលើប្រព័ន្ធអ៊ីនធឺណិត អ្នកត្រូវប្រាកដថាវាជាអ្វីដែលមិនបង្កឱ្យអ្នកមានវិប្បដិសារីនៅពេលខាងមុខ។
- សូមចាត់ទុករាល់សកម្មភាពតាមប្រព័ន្ធអ៊ីនធឺណិតដូចនឹងសកម្មភាពជាសាធារណៈដែរ៖ ទោះបីជាការប្រាស្រ័យទាក់ទងគ្នាតាមរយៈកម្មវិធីផ្សេងៗលើប្រព័ន្ធអ៊ីនធឺណិតមានលក្ខណៈដូចជាឯកជនក៏ដោយ វាមានលទ្ធភាពខ្ពស់ដែលថាខ្លឹមសារទាំងនោះនឹងត្រូវបានកត់ត្រាទុក និងចែកចាយជាសាធារណៈនៅថ្ងៃណាមួយ។ សូមបង្ហោះតែអ្វីដែលមានសុវត្ថិភាពលើប្រព័ន្ធអ៊ីនធឺណិត។

# ឧបសម្ព័ន្ធ ២៖ ករណីសិក្សា

## ករណីសិក្សា ក៖ ការលួចលោមតាមអនឡាញក្នុងគោលបំណងផ្លូវភេទ

ម្តាយរបស់ក្មេងប្រុសអាយុ១៤ឆ្នាំម្នាក់បានទាក់ទងមកអ្នក។ គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីឥរិយាបថ ថ្មីៗរបស់កូនប្រុសគាត់ ដោយសារគាត់មានភាពស្ងប់ស្ងាត់ប្លែក និងដកខ្លួនចេញ ហើយចំណាយពេលច្រើននៅតែក្នុងបន្ទប់ជាមួយកុំព្យូទ័រយួរដៃរបស់គាត់។ គាត់មិនសូវចាប់អារម្មណ៍ជាមួយមិត្តភក្តិ និងក្រុមគ្រួសារទេ ហើយពិន្ទុនៅសាលារបស់គាត់ក៏មិនសូវល្អប៉ុន្មានដែរខែចុងក្រោយនេះ។ ជាធម្មតាគាត់ជាសិស្សទទួលបាននិទ្ទេសA។

ថ្ងៃមួយ ឪពុកចុងរបស់ក្មេងប្រុសនេះបានចូលមើលទូរសព្ទកូនប្រុសគាត់ ពេលគាត់កំពុងដេកលក់ ហើយបានរកឃើញថា កូនប្រុសគាត់បានទាក់ទងជាមួយស្ត្រីខ្មែរពេញវ័យម្នាក់ ដែលរស់នៅក្នុងទីក្រុងមួយផ្សេងទៀត អស់រយៈពេលជាច្រើនខែមកហើយ។ វាពិបាកក្នុងការដឹងពីអាយុពិតប្រាកដរបស់ស្ត្រីម្នាក់នេះតាមរយៈរូបថតរបស់នាង ប៉ុន្តែនាងមើលទៅទំនងជាមានអាយុចន្លោះពី៣០ទៅ៤០ឆ្នាំ។

ស្ត្រីម្នាក់នេះបានផ្ញើសារមកកូនប្រុសគាត់ ហើយសារខ្លះទាក់ទងនឹងការរួមភេទ។ នាងក៏បានផ្ញើរូបថតអាក្រាតរបស់នាងមកឱ្យគាត់ ហើយសុំគាត់ឱ្យធ្វើដូចគ្នា ហើយគាត់ក៏បានធ្វើដូច្នេះដែរ។ ស្ត្រីម្នាក់នោះបានប្រាប់ថានាងស្រឡាញ់ក្មេងប្រុសនោះ ហើយមានគម្រោងនឹងមកស្រុកកំណើតក្នុងពេលឆាប់ៗនេះ ដើម្បីពួកគេអាចជួបគ្នា និងរួមភេទជាមួយគ្នា។

ម្តាយរបស់ក្មេងប្រុសនេះមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអ្វីដែលគាត់បានរកឃើញហើយស្ថានភាពនេះកាន់តែស្មុគស្មាញ ដោយសារប្តីរបស់គាត់ ដែលជាឪពុកចុងរបស់ក្មេងប្រុសនេះ បានប្រាប់គាត់ថាកុំឱ្យធ្វើអ្វីទាំងអស់។ គាត់ជឿថាវាជារឿងធម្មតាទេដែលក្មេងប្រុសចាប់អារម្មណ៍នឹងមនុស្សស្រី ហើយគិតថាវាជាការល្អដែលកូនប្រុសគាត់អាចរួមរ័ក្សជាមួយមនុស្សស្រី ព្រោះគាត់អាចរៀនពីរបៀបក្លាយជា «បុរសពិត»។ គាត់បាននិយាយថាក្មេងប្រុសនេះ «សំណាង»ហើយ ហើយគាត់គិតថាវាមានសុខភាពល្អសម្រាប់កូនប្រុសគាត់។

## ករណីសិក្សា ខ៖ សម្ពាធរំលោភបំពានផ្លូវភេទកុមារ

ក្មេងស្រីអាយុ១៥ឆ្នាំម្នាក់ និងមិត្តប្រុសអាយុ១៧ឆ្នាំរបស់នាង មានទំនាក់ទំនងជិតស្និទ្ធ និងយកចិត្តទុកដាក់ចំពោះគ្នាអស់រយៈពេលជាងមួយឆ្នាំមកហើយ។ ពេលខ្លះពួកគេចែករំលែកសារផ្លូវភេទ និងរូបថតតាមកម្មវិធី WhatsApp ហើយតែងតែយកចិត្តទុកដាក់មិនឱ្យនរណាម្នាក់ឃើញសារ និងការសន្ទនារបស់ពួកគេទេ។

ថ្ងៃមួយ មិត្តភក្តិរបស់ក្មេងប្រុសនោះបានប្រើទូរសព្ទគាត់ ហើយដោយមានគោលបំណងចង់លេងសើចក៏សម្រេចចិត្តបង្ហោះរូបថតពួកគេលើប្រព័ន្ធអនឡាញ។ មិនយូរប៉ុន្មានរូបភាពនេះត្រូវបានគេចែករំលែក ហើយចែករំលែកបន្តទៀតដោយក្រុមសង្គមជាច្រើន ហើយយុវជនទាំងពីរនាក់នោះបានសម្រេចចិត្ត

ចាកចេញពី សាលា ដោយសារពួកគេត្រូវបានគេសើចចំអក និងធ្វើបាប។ ក្មេងប្រុសខឹងខ្លាំងណាស់ ចង់សងសឹកនឹងមិត្តភក្តិខ្លួន ហើយនារីរងគ្រោះបានប្រាប់មិត្តភក្តិរបស់នាងថា នាងមានអារម្មណ៍ថា កេរ្តិ៍ឈ្មោះ និងជីវិតរបស់នាងត្រូវបានគេបំផ្លាញ ហើយមានអារម្មណ៍ថាចង់បញ្ចប់ជីវិតនាង។ យុវជនទាំងពីរបានមកប៉ុស្តិ៍ប៉ូលីសជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយ។

## ករណីសិក្សា គ៖ ការគំរាមទាក់ទងនឹងផ្លូវភេទ

ឆៃ ជាក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ រស់នៅជាមួយជីដូន ខណៈពេលដែលម្តាយរបស់គាត់ធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ។ ឪពុករបស់គាត់បានធ្វើអត្តឃាតកាលពីប៉ុន្មានឆ្នាំមុននេះ។ គាត់មានបងប្អូនប្រុសស្រី ផ្សេងទៀត ប៉ុន្តែពួកគេរស់នៅជាមួយសាច់ញាតិដទៃទៀតនៅខេត្តផ្សេង។ ចាប់តាំងពីឪពុករបស់គាត់បានទទួលមរណភាពមក ឆៃបានក្លាយជាក្មេងប្រុសម្នាក់ដែលមានភាពអៀនខ្មាស់ និងមានមិត្តភក្តិតិចតួចណាស់ ហើយគាត់តែងតែត្រូវបានគេធ្វើបាបនៅសាលា ព្រោះគាត់ជាក្មេងប្រុសដែលស្លូតបូត ហើយគាត់ក៏ត្រូវបានគេសើចចំអកឌីដងឱ្យផងដែរ។

ក្មេងខ្លះនិយាយលេងសើចថា ឆៃជាខ្ទើយ (ស្រឡាញ់ភេទដូចគ្នា) ហើយខ្លះទៀតនិយាយអាក្រក់អំពីឪពុកគាត់ ដោយនិយាយថា ឪពុកឆៃបានសម្លាប់ខ្លួនព្រោះគាត់មិនស្រឡាញ់ឆៃទៀតទេ។ ឆៃស្រឡាញ់ជីដូនគាត់ខ្លាំងណាស់ ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយគាត់ ប៉ុន្តែឆៃមិនដែលប្រាប់គាត់អំពីបញ្ហារបស់ខ្លួននៅសាលា ឬថាខ្លួនមានអារម្មណ៍ថាឯកោទេ។ ជីដូនរបស់ឆៃមានវ័យចំណាស់ ហើយមានបញ្ហាសុខភាពមួយចំនួនទៀត ដូច្នេះឆៃមិនចង់ធ្វើឱ្យជីដូនមានការព្រួយបារម្ភឡើយ។ ពេលខ្លះគាត់មានអារម្មណ៍ក្រៀមក្រំ ហើយបានប្រើកាំបិតកាត់ខ្លួនឯង ការធ្វើបែបនេះធ្វើឱ្យគាត់បន្ធូរភាពតានតឹងបានខ្លះ។

ចាប់តាំងពីការរាតត្បាតជំងឺកូវីដ១៩ គាត់គ្មានជម្រើសអ្វីផ្សេង ក្រៅពីការសិក្សាតាមប្រព័ន្ធអនឡាញទេ គាត់ចូលចិត្តចំណាយពេលនៅតែម្នាក់ឯងពេលនៅផ្ទះ នៅក្នុងបន្ទប់របស់គាត់ជាមួយកុំព្យូទ័រយួរដៃរបស់គាត់។ គាត់លេងហ្គេមច្រើន ហើយប្រើកម្មវិធីផ្ញើសារ និងគេហទំព័របង្កើតមិត្តភក្តិជាច្រើនទៀត។ គាត់មានអារម្មណ៍ថាវាងាយស្រួលជួបមនុស្សតាមប្រព័ន្ធអនឡាញជាងក្នុងជីវិតពិត ហើយជារឿយៗគាត់ចែករំលែកបញ្ហារបស់គាត់ជាមួយមនុស្សដែលគាត់បានជួបនៅក្នុងការជជែកគ្នាតាមប្រព័ន្ធអនឡាញ។ គាត់មានអារម្មណ៍ថាវាងាយស្រួល និងមានសុវត្ថិភាពជាងមុនក្នុងការជឿទុកចិត្តមនុស្សតាមប្រព័ន្ធអនឡាញ។

មនុស្សម្នាក់ដែលគាត់បានជួបតាមប្រព័ន្ធអនឡាញ ដែលគាត់ជឿថាស្រីខ្មែរ បាននិយាយប្រាប់គាត់ថានាងមានអាយុ២១ឆ្នាំ។ ពួកគេចែករំលែករឿងរ៉ាវជាច្រើនតាមរយៈសារ ហើយបានផ្ញើសារឱ្យគ្នាទៅវិញទៅមកអំពីបញ្ហារបស់ពួកគេ។ យូរៗទៅ គាត់មានអារម្មណ៍ថាគាត់អាចទុកចិត្តនាងបាន ហើយទំនាក់ទំនងរបស់ពួកគេក៏កាន់តែជិតស្និទ្ធជាងមុន។ គាត់មិនដែលឃើញមុខនាងតាមប្រព័ន្ធអនឡាញទេ ប៉ុន្តែនាងបានចែករំលែករូបថតដែលនាងនិយាយថាជារូបរបស់នាង។ នាងសន្យាថាថ្ងៃណាមួយនឹងជួបតាមវីដេអូខល (video messenger) ហើយបានពន្យល់ថានាងក៏ដូចជាគាត់ដែរ នាងក៏អៀនដែរ។

## ករណីសិក្សា គ៖ ការរុករកឆ្លងកាត់តាមអនឡាញ

ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ បានទាក់ទងអ្នកកំពុងធ្វើការនៅការិយាល័យ បន្ទាប់ពីទទួលបានសារនៅលើបណ្តាញសង្គម ដែលចោទប្រកាន់ថាគាត់ជាមនុស្សស្រឡាញ់ភេទដូចគ្នា។ បុគ្គល ឬអ្នកដែលបានផ្ញើសារនោះ បានយករូបថតគាត់ចេញពីគណនី Facebook គាត់ ហើយបានកាត់តក្បាលរបស់គាត់ដាក់លើរូបភាពបុរសវ័យក្មេងកំពុងរួមភេទ។ គាត់មានមិត្តភក្តិ Facebook ជាច្រើន ហើយមិនដឹងពីរបៀបកំណត់ឯកជនភាពរបស់គាត់ទេ ដូច្នេះរូបភាពនេះត្រូវបានគេចែករំលែក ហើយចែករំលែកបន្តទៀតជាច្រើនដង។

គាត់ពិតជាអាក់អន់ចិត្ត និងពិបាកចិត្តណាស់ ដោយសារការបង្ហោះរូបនេះ និងពាក្យសម្តីអាក្រក់ៗ ហើយជាពិសេស ក៏មានមហាជនជាច្រើនទៀតបានបង្ហោះរូបសញ្ញាអារម្មណ៍សើចក្អាកក្អាយ និងបញ្ចេញមតិយោបល់លេងសើចផ្សេងទៀតផងដែរ។

## ករណីសិក្សា ឃ៖ ការរុករកឆ្លងកាត់តាមអនឡាញ

អង្គការមិនមែនរដ្ឋាភិបាលមួយបានទាក់ទងមកអ្នកបន្ទាប់ពីក្មេងប្រុសអាយុ១៦ឆ្នាំម្នាក់បានទាក់ទងមកពួកគេបន្ទាប់ពីឧប្បត្តិហេតុមួយកាលពីសប្តាហ៍មុន។ ក្មេងប្រុសម្នាក់នេះមិនចង់បញ្ចេញឈ្មោះគាត់ឱ្យគេស្គាល់ទេនៅពេលនេះ។ គាត់បានពន្យល់ថា គាត់បានចូលរួមពិធីជប់លៀងមួយជាមួយមិត្តភក្តិនៅមហាវិទ្យាល័យ។ គាត់ស្រវឹងខ្លាំងណាស់ ហើយក៏សន្លប់បាត់ទៅ។ ពេលដឹងខ្លួនឡើងវិញនៅថ្ងៃបន្ទាប់ គាត់បានត្រឡប់ទៅផ្ទះវិញ ហើយបានដេកច្រើនម៉ោងព្រោះគាត់ឈឺក្បាលខ្លាំង។

ក្រោយមកនៅថ្ងៃដដែលនោះគាត់បានទទួលសារពីមិត្តម្នាក់របស់គាត់ដែលបង្ហាញការព្រួយបារម្ភអំពីវីដេអូរួមភេទរបស់គាត់ជាមួយបុរសពេញវ័យពីរនាក់ទៀត ដែលត្រូវបានគេបង្ហោះលើប្រព័ន្ធអនឡាញ។ មិត្តភក្តិម្នាក់នោះបានសន្មតថាក្មេងប្រុសនោះបានបង្ហោះវីដេអូនោះដោយខ្លួនឯង ប៉ុន្តែគាត់មិនបានធ្វើដូច្នេះទេ។

## ករណីសិក្សា ខ៖ ការផ្សាយផ្ទាល់នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារ

អ្នកទទួលបានព័ត៌មានទាក់ទងនឹងក្រុមតេលេក្រាមមួយ ដែលវីដេអូរបស់កុមារត្រូវបានគេរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ និងត្រូវបានបង្ហោះផ្សាយយ៉ាងទៀងទាត់ និងចែករំលែកលើប្រព័ន្ធអនឡាញ។ ការរុករកដំបូងនៃការផ្សាយបន្តផ្ទាល់នេះ ហាក់ដូចជាបង្ហាញកុមារមកពីជុំវិញពិភពលោករួមទាំងកុមារមួយចំនួនដែលជាជនជាតិអាស៊ី និងអាចជាជនជាតិខ្មែរផងដែរ។ ក្រុមនេះមានសមាជិកជាង ៤០០០នាក់ (មានសមាជិកខ្មែរមួយចំនួន និងបរទេសជាច្រើននាក់)។ វាមិនតែងតែច្បាស់លាស់ទេ ប៉ុន្តែ«ការផ្សាយផ្ទាល់» មួយចំនួនហាក់ដូចជាវីដេអូដែលត្រូវបានគេថតកាលពីពេលមុន ហើយត្រូវបានគេចាក់ផ្សាយ។

# ឧបសម្ព័ន្ធ ៣៖ ការឈ្វេងយល់ពីច្បាប់និងទោសបញ្ញត្តិ

## យោងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨,

### ជំពូកទី៥ រូបភាព និងសម្ភារៈអាសអាភាស

### មាត្រា ៣៨. និយមន័យនៃរូបភាពនិងសម្ភារៈអាសអាភាស

រូបភាព និងសម្ភារៈអាសអាភាស សំដៅដល់សម្ភារៈដែលអាចមើលឃើញនឹងភ្នែក ដូចជារូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិក ដែលពិពណ៌នាអំពីកេរ្តិ៍ភេទ ឬ ភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។

មាត្រា ៣៩.ជនណាចែកចាយ លក់ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ)ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ២០០.០០០ (ពីរសែន)រៀល។

ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ ខាងលើ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ២០០.០០០ (ពីរសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល។

### មាត្រា៤១. រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ

ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល។

ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសខាងលើត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ ខាងលើ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ដល់ ២០ (ម្ភៃ)ឆ្នាំ ។

# ឧបសម្ព័ន្ធ ៤៖ តំណភ្ជាប់ និងធនធានសិក្សាបន្ថែម

គេហទំព័រក្រសួងអប់រំ យុវជន និង កីឡា៖
https://moeys.gov.kh/

---

- គេហទំព័រអង្គការយូនីសេហ្វ (UNICEF)៖ https://www.unicef.org/cambodia/research-and-reports
- គេហទំព័រអង្គការសកម្មភាពដើម្បីកុមារ (APLE)៖ https://aplecambodia.org/resources/
- គេហទំព័រអ៊ីសេហ្វធី (eSafety)៖ https://www.esafety.gov.au/communities/cultural-linguistic/translations/cambodian/
- វីដេអូ វិធីសាស្ត្របង្រៀនបំណិនជីវិតតាមមូលដ្ឋាន ដែលថតដោយអង្គការអាក់សិនអេតកម្ពុជា៖ https://www.youtube.com/watch?v=lMqG1xyfIuQ
- គេហទំព័រថ្នាលអភិវឌ្ឍសមត្ថភាព ៖ https://cdp.moeys.gov.kh/enrol/cpdlist/view.php?id=7
- វីដេអូអប់រំ រឿងស្នេហ៍តាមអនឡាញ https://www.a21.org/content/can-you-see-me-cambodia/gv3o0g
- វីដេអូអំពីរបៀបរាយការណ៍ TakeItDown https://www.youtube.com/missingkids
- វីដេអូអប់រំអំពី Play Like & Share

  https://www.google.com/search?q=thinkyouknow+video&oq=thinkyouknow+video&gs_lcrp=EgZjaHJvbWUyBggAEEUYOTIJCAEQABgNGIAEMggIAhAAGBYYHjIICAMQABgWGB7SAQg2NDYxajBqNKgCALACAA&sourceid=chrome&ie=UTF-8#fpstate=ive&vld=cid:75ea4a2a,vid:WpngtGyc_ec,st:0
- គេហទំព័រធនធានបន្ថែម: https://www.nspcc.org.uk/keeping-children-safe/online-safety/inappropriate-explicit-content/#resources

unicef
for every child

End Violence
Against Children

APLE